01239141



ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 29-April-2016, 11:10
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី៣៩២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms.Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក សៅ សារុន (2-TCW-1012) | ខ្មែរ |
| លោក សុន វុត (2-TCCP-1016) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សៅ សារុន** (2-TCW-1012)


សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ............ ទំព័រ ៣

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី ............ ទំព័រ ២៨


**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក សុន ទុត** (2-TCCP-1016)


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ............ ទំព័រ ៤១

សួរដោយលោក ឡោ ជុនធី ផ្ដើមពី ............ ទំព័រ ៤៤

សួរដោយលោក ពេជ អង្គ ផ្ដើមពី ............ ទំព័រ ៥៥

សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ............ ទំព័រ ៦៣

សួរបន្តដោយប្រធានអង្គជំនុំ ផ្ដើមពី ............ ទំព័រ ៧៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី សៅ សារុន តាមរយៈប្រព័ន្ធសោតទស្សន៍បញ្ចប់ ហើយនិងផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1016 ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់មន្ទីរសន្តិសុខភ្នំក្រោល។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក សៅ សារុន តាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តឧត្ដរមានជ័យ។ តាមការបញ្ជាក់ពីផ្នែកបច្ចេកទេសសោតទស្សន៍បានជូនដំណឹងថា ការរៀបចំផ្នែកបច្ចេកទេសសម្រាប់ការស្ដាប់សក្ខីកម្មនៅពេលនេះបានរៀបចំរួចរាល់ហើយ រីឯសាក្សី និងមេធាវីប្រឹក្សារបស់លោកគឺ លោក មឿន សុវណ្ណ បានត្រៀមខ្លួនជាស្រេចសម្រាប់ការផ្ដល់សក្ខីកម្ម។ នៅថ្ងៃនេះដែរ មានដើមបណ្ដឹងរដ្ឋប្បវេណីបម្រុងមួយរូបដែលមានរហស្សនាម 2-TCCP-1016។ សូមអរគុណលោកប្រធាន។

[០៩:០៥:០១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោក ឯម ហ៊ុយ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះ បានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអការៈឈឺចង្កេះជាប្រចាំ អង្គុយយូរមិនបាន និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ស្ថិតខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ គឺពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

សួស្តីលោក សៅ សារុន តើលោកបានត្រៀមខ្លួនរួចរាល់ហើយឬនៅ?

**លោក សៅ សារុន៖**

ខ្ញុំរៀបចំត្រៀមខ្លួនរួចស្រេចហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីដើម្បីមានឱកាសសួរដេញដោលសាក្សី។ ហើយដំបូងនេះ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី សៅ សារុន។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រី ចៅក្រម ភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំជាមេធាវីការពារក្ដីលោក នួន ជា ខ្ញុំសួរសំណួរលោកខ្លះៗ បន្ថែមទៀតនៅព្រឹកនេះ។ ខ្ញុំសូមសួរបន្តពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញនៅប្រហែលជាម៉ោង ១៥:១៤នាទី <គេបានសួរ>លោក<អំពីកិច្ចប្រជុំមួយ រវាង>លោក <និង>ប៉ុល ពត និង នួន ជា ហើយពេលនោះ<គេបានសួរលោក អំពីអ្វីដែលអ្នកទាំងពីរនោះបាន>ប្រាប់លោក<> អំពីវៀតណាម <ហើយនៅពេលមួយនោះ លោកបានឆ្លើយដូចតទៅ> ខ្ញុំសូមដកស្រង់ត្រង់ៗតែម្ដង ចេញពីចម្លើយរបស់លោក "ឆ្លើយ៖ បាទ ពួកគាត់បានប្រាប់ខ្ញុំអំពីប្រទេសវៀតណាម។ ខ្លួនខ្ញុំផ្ទាល់បានឃើញការឈ្លានពាននៅតាមព្រំដែនដោយផ្ទាល់ភ្នែក" បញ្ចប់ការដកស្រង់។ តើលោកអាចពន្យល់ជូនតុលាការបានទេ ដែលលោកឆ្លើយថាលោកបានឃើញការឈ្លានពានដោយផ្ទាល់ភ្នែក។ តើការឈ្លានពានពីសំណាក់កងទ័ព<វៀតណាម>នេះជាការឈ្លានពានដូចម្ដេចដែរ ដែលលោកថាលោកបានឃើញដោយផ្ទាល់ភ្នែកនោះ?

[០៩:០៨:៣៦]

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺខ្ញុំ ដូចបានឆ្លើយម្សិលមិញហើយ ការឈ្លានពានហ្នឹងគឺវាពិតប្រាកដតាមព្រំដែន ពីព្រោះខ្ញុំនៅព្រំដែន។ ចូលមកវាយតាមព្រំដែន នេះមួយ។ ពីរ មិនចេះឈប់ មិនចេះឈរទេ គឺវាចូលមកវ៉ៃសម្រុកយើងរហូតដល់វាវាយទ្រង់ទ្រាយធំ។ បាទ សូមអស់។

**ស៖** តើលោកអាចនិយាយបានទេ បញ្ជាក់ប្រាប់បានទេ អ្នកណាជាអ្នកចាប់ផ្ដើមវាយប្រយុទ្ធមុននៅក្នុងខេត្តមណ្ឌលគិរី <នៅឆ្នាំ១៩៧៦> និងការវាយប្រយុទ្ធបន្តបន្ទាប់មកទៀត? អ្នកណាជាអ្នកចាប់ផ្ដើមបើកការវាយប្រហារមុន?

**ឆ៖** គឺពួកវៀតណាមនេះអស់លោក វាយតាមព្រំដែន គេវាយមុនរហូតគេបើកវាយទ្រង់ទ្រាយធំរំដោះថ្ងៃ០៧ មករានេះ។

**ស៖** ការដែលវៀតណាមជាអ្នក<>បើកការវាយប្រហារមុនមកលើកម្ពុជាប្រជាធិបតេយ្យ តើ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការវាយប្រហារបែបនេះ លោកឃើញដោយផ្ទាល់ ឬក៏មានគេរាយការណ៍មកលោកក្នុងឋានៈលោកជា <ជាលេខាស្រុក ឬ>លេខាតំបន់១០៥?

**ឆ៖** បាទ សូមឆ្លើយ ទី១ គេរាយការណ៍, ទី២ វាឃើញនឹងភ្នែកហ្នឹង ចូលវាយ។

**ស៖** តើលោកអាចលើកជូនជាឧទាហរណ៍មួយបានទេ នូវអ្វីដែលលោកបានឃើញដោយផ្ទាល់ តើទ្រង់ទ្រាយនៃការឈ្លានពានរបស់វៀតណាមដែលលោកឃើញដោយផ្ទាល់ភ្នែកនេះ មានលក្ខណៈដូចម្តេចដែរ?

**ឆ៖** បាទ សូមឆ្លើយ ថ្ងៃវាចូលទ្រង់ទ្រាយធំហ្នឹង ពួកខ្ញុំនៅមិនទាន់ដឹងទេ មុនដំបូងវា ពីព្រោះវាចេញផុតពីកងទ័ពការពារព្រំដែន វាចូលមកអែបមកខាងទន្លេស្រែពក គឺចល័ត ខ្ញុំក៏បានទៅរៀបចំកងទ័ពទៅទប់ទល់គ្នា។ គេចូលមករហូតហ្នឹង ពីព្រោះយើងកងទ័ពពួកមណ្ឌលគិរីយើង កងទ័ពតំបន់តិចទេ ពីរបីនាក់ហ្នឹងឯង ប៉ុន្តែជាចំនួនប្រហែលជា២០០នាក់ទេ។ កងទ័ពកងពលទេ គេច្រើន ពីព្រោះគេកងទ័ពធំ។

**ស៖** លោកសាក្សីនៅពេលនោះ លោកយល់ទេថា មានមូលហេតុអ្វីបាននាំឲ្យមានការឈ្លានពានពីសំណាក់កងទ័ពវៀតណាមលុកលុយ ឬក៏ឈ្លានពានចូលមកទឹកដីកម្ពុជានោះ? តើលោកមានយល់អំពីមូលហេតុដែលនាំឲ្យមានការលុកលុយឈ្លានពាននេះដែរទេ?

**ឆ៖** បាទ សូមឆ្លើយ រឿងមូលហេតុនេះ ខ្ញុំអត់យល់ដែរ មិនដឹងគេមានមូលហេតុយ៉ាងម៉េចបានគេវាយកម្ពុជាយើង។ ខ្ញុំអត់យល់មូលហេតុហ្នឹង ឬក៏គេមានមូលហេតុពិតដោយគ្រប់គ្រងនិងកាន់កាប់កម្ពុជាក៏មិនដឹង បានគេហ៊ានវាយអ៊ីចឹង។ អាហ្នឹងខ្ញុំមិនសូវយល់ដែរ។

[០៩:១២:៤០]

**ស៖** ខ្ញុំសូមអានសម្រង់ខ្លីមួយនូវអ្វីដែល សុន សេន បាន<>រាយការណ៍ទៅសមមិត្តជា<> សមាជិកគណៈអចិន្ត្រៃយ៍នៅកិច្ចប្រជុំមួយដើមឆ្នាំ១៩៧៦ និងសួរទៅលោកថា តើលោកយល់ស្របជាមួយនឹងរបាយការណ៍នេះក៏អត់គឺ E3/221 ជាកំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ជាពិសេស ERN ជាអង់គ្លេស 00182696, បារាំង 00386178, ខ្មែរ 00000813។ សុន សេន បានលើកឡើងដូចតទៅ សូមដកស្រង់៖ "នៅតាមព្រំដែន ពួកវា<(វៀតណាម)>ចេះតែចូលមកឥតឈប់ឈរ។ យើងមិនដែលចង់បង្កបញ្ហាជាមួយពួកវាទេ។ យោងតាមបទពិសោធន៍របស់យើង ពេលពួកវាចូលមក ហើយយើងមិនដេញ វាមិនទៅទេ។ ដល់តែយើងតឹងតែង ទើបវាទៅវិញ។ នេះនៅខាងរតនគិរី។ ឯនៅខាង

មណ្ឌលគិរី យើងអត់វាយវាសោះ គឺយើងគោរពការណែនាំរបស់បក្សជាដាច់ខាតមិនឲ្យតឹងតែងនោះទេ។” តាមបទពិសោធន៍របស់លោកផ្ទាល់ តើលោកយល់ស្របជាមួយនឹងរបាយការណ៍មួយនេះទេ?

**ឆ៖** បាទ គឺខ្ញុំសូមឆ្លើយ។ នៅខាងមណ្ឌលគិរីហ្នឹងគឺមែនដូចលោក សុន សេន ថាហ្នឹង។ ប៉ុន្តែគេចេះតែរ៉ៃយើង ផ្ទក់រ៉ៃយើងជាបន្តបន្ទាប់។ យើងចេះតែ អាហ្នឹងខាងមានភារកិច្ចទាក់ទងនឹងវៀតណាមចូល ចេះតែចរចាគ្នារហូត។ គេចេះតែរ៉ៃរហូតអ៊ីចឹង។

[០៩:១៤:៥៨]

**ស៖** អ្នកណាជាអ្នកធ្វើការចរចា នៅដើមដំបូងឡើយ តើ យ៉ា ឬ<>?

**ឆ៖** បាទ អាហ្នឹងខាងកងពលទេ ៩២០ ទេ។ ពីដើមពីមុនហ្នឹង គឺតាយ៉ា មកចរចាម្តង ហើយរួចហ្នឹង ក៏កងពល៩២០។

**ស៖** ខ្ញុំសូមសង្កត់ធ្ងន់ត្រង់ចំណុចមួយ លោកសាក្សីមានសារទូរលេខ ច្រើនណាស់ពាក់ព័ន្ធទៅនឹងការឈ្លានពាន និងការចរចាជាមួយវៀតណាម។ មើលទៅពាក្យប្រើប្រាស់សម្រាប់កងទ័ពវៀតណាម យើងហៅថា ក្រុម៧ <ឬ> ៧<> ឬក៏ក្រុមទី៧។ តើពាក្យថា “ក្រុមទី៧” នេះ គេសំដៅទៅលើអ្វីដែរ?

**ឆ៖** សូម -- អាហ្នឹងគឺខ្ញុំមិន សួរ ចម្លើយហ្នឹងអត់យល់ទេ អត់យល់ ឲ្យនិយាយឲ្យម្តងទៀត។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី ដោយសារថាមានសារទូរលេខច្រើន លោកអាចផ្តល់លេខយោងទៅលើសារទូរលេខណាមួយបានទេ <ដើម្បីប្រតិចារឹក>?

**លោក សៅ សារុន៖**

**ឆ៖** អ៊ីចឹង គឺបញ្ហាទូរលេខហ្នឹង ទូរលេខហ្នឹងគឺមានមែន មានមួយ គេរាយការណ៍ខាង គេកាន់កាប់តាមព្រំដែន ចេះតែលុកលុយរ៉ៃគេជាបន្តបន្ទាប់--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់សាក្សី កុំអាលទាន់ ចាំៗបញ្ជាក់សាជាថ្មីឡើងវិញ ព្រោះចង់បញ្ជាក់អត្តសញ្ញាណឯកសារច្បាស់លាស់សិន ហើយនិងចំណុចពាក់ព័ន្ធណា៎!

**លោក សៅ សារុន៖**

**ឆ៖** បាទ។ អត្តសញ្ញាណឯកសាររាយការណ៍នេះ គឺ--

**ប្រធានអង្គជំនុំ៖**

ខាងៗមេធាវីទេៗ ត្រូវបង្ហាញ មិនមែនលោកទេ លោកចាំស្ដាប់ណ៎ះ! លោកស្ដាប់សំណួរឱ្យច្បាស់ សូមឆ្លើយតប។ ឆ្លើយតបកម្រិតត្រឹមតែពេញលេញ ចាំបាច់ តបទៅនឹងសំណួរ ដែលសួរបានហើយ ក្នុងករណីសំណួរណាដែលមិនច្បាស់លាស់គឺលោក កុំអាលឆ្លើយ ហើយលោកសួរ សុំឱ្យអ្នកតាំងសំណួរចំពោះលោកហ្នឹង សួរលោកសាជាថ្មីសាឡើងវិញ។ លោកយល់ទេ?

**លោក សៅ សារុន៖**

បាទ យល់។

[០៩:១៧:៥០]

**លោក វ៉ិចទ័រ កូប៉េ៖**

ឆ្លើយទៅនឹងសំណួររបស់លោកស្រីចៅក្រម ហ្វេនស៍ គឺឯកសារ E3/923 ដែលនិយាយថា៖ “បងប្អូនយើង បានវាយទៅលើ<ក្រុម>៧<ម្ដងទៀត>”។ គឺ ឯកសារ E3/1101៖ “<តាមដាន>អ្នកដែលមានការជាប់ពាក់ព័ន្ធជាមួយពួកអាក្រុម៧ <ឬមាននិន្នាការជាមួយក្រុម៧>”។ គឺឯកសារ E3/1118 និយាយពី“ពួកអាក្រុម៧” <E3/8377> និយាយអំពី<ក្រុម៧>ឈ្លានពានចូល<ជាដើម។>

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកយល់ពាក្យថា “ពួកអា៧” ឬក៏ “ពួកអាក្រុម៧” មានន័យថាម្ដេចទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ អត់យល់ទេ ក្រុម៧ ក្រុមអីហ្នឹង ខ្ញុំការពិត ខ្ញុំអត់ដែលឮគេហៅអ៊ីចឹង។

**ស៖** ខ្ញុំសូមព្យាយាមអានឯកសារមួយជាចុងក្រោយ ដែលទស្សនវិទូអាមេរិកាំងបាននិយាយអំពីការប្រើប្រាស់ថា “ពួកអា៧” នេះ គឺខ្ញុំយោងទៅលើឯកសារ E3/1664 មានតែអង់គ្លេសទេ គឺត្រង់ទំព័រ៩១ នៃសៀវភៅរបស់ទស្សនវិទូ<>នេះ និយាយអំពី “ការបោសសម្អាតរបស់ខ្មែរក្រហមនៅខេត្តមណ្ឌលគិរី” ERN ជាអង់គ្លេស 00397664។ លោកសាក្សីទស្សនវិទូជនជាតិអាមេរិកាំងមួយរូបនេះបាននិយាយ -- គាត់ឈ្មោះ ស្ទីវហ្វិន ហេដឌ័រ <គាត់និយាយថា> “ពួកអា៧ (សូមដកស្រង់) តាមធម្មតាតែងតែប្រើពាក្យសម្ងាត់សម្រាប់សំដៅទៅលើវៀតណាមជាទូទៅ មិនយោងទៅលើប្រជាជន ឬក៏កងទ័ព<កងពលទី៧>ណាមួយ ឬក៏<>កងទ័ពភូមិភាគទី៧ របស់វៀតណាមនោះទេ។” បញ្ចប់ការដកស្រង់។ ទស្សនវិទូរូបនេះ ហាក់ចង់សំដៅនិយាយទៅលើ<កងទ័ព>វៀតណាមជាទូទៅ<>”។ តើចំណុចនេះ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

01239151



ជួយរំឭកដល់ការចងចាំរបស់លោកដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! អញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

អ្វីដែលមេធាវីការពារក្តី<អាន>មិនសំដៅទៅលើកងទ័ពនោះទេ។ <>លេខយោងជើងទំព័រ <ដែលគាត់អាននោះ>និយាយ<ថា> "<>៧នេះ គឺសំដៅទៅលើប្រជាជនវៀតណាមជាទូទៅ" មិនសំដៅទៅលើកងទ័ពនោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនច្បាស់ ខ្ញុំដកស្រង់នេះត្រង់ៗតែម្តង។ ហើយជាថ្មីម្តងទៀតលោកសាក្សី ទស្សនវិទូអាមេរិកាំងនេះ គាត់និយាយថា <"ក្រុម>ប្រាំពីរ ឬក៏ពួកអាប្រាំពីរនេះ គឺ<ជា>កងទ័ពវៀតណាម។ <មិនមែន>កងពលទី៧ ឬក៏កងទ័ពភូមិភាគទី៧<ទេ ប៉ុន្តែជាកងទ័ព>វៀតណាម<ទូទៅ>។

**លោក នីកូឡាស គូមជែន៖**

សូមជំទាស់ម្តងទៀត។ មេធាវីការពារក្តី <សួរសំណួរតាមការយល់ឃើញរបស់គាត់>។ ទស្សនវិទូប្រើពាក្យថា "<ជនជាតិ>វៀតណាម"។ <គាត់មិនបាននិយាយអ្វីទាំងអស់ពាក់ព័ន្ធទៅនឹង> កងទ័ព <ឬទាហាន>នោះ <គឺគាត់គ្រាន់តែទទួលស្គាល់អ៊ីចឹង ហើយខ្ញុំអត់យល់សំណួរនោះទេ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ត្រង់នេះគឺហាក់បីដូចជា ស្ទីវ ហេដឌ័រ ហ្នឹង <មិន>សំដៅទៅលើការវាយប្រហារ<ពីជនស៊ីវិលវៀតណាម>នេះ<ទេ>។ ខ្ញុំសូមអានសារទូរលេខនេះសាជាថ្មីឡើងវិញ។ សារទូរលេខច្បាស់ណាស់ សំដៅទៅលើកងទ័ពវៀតណាម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដើម្បី -- ដោយសារតែពេលវេលា លោកសាក្សីតើចំណុចនេះវារំឭកដល់ការចងចាំរបស់លោកខ្លះដែរទេ ការប្រើពាក្យថា "<ក្រុម៧ ឬក៏>ពួក៧" បាទ?

[០៩:២២:២១]

**លោក សៅ សារុន៖**

**ឆ៖** បាទ ខ្ញុំអត់ទេ។ កាលពីជំនាន់ខ្ញុំនៅស្រុក ឮគេហៅ ពួក៧ ពួកអី ខ្ញុំអត់ឮ។ អត់ដឹង អត់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យល់ មិនដឹងគេហៅ សំដៅកងទ័ព ឬហៅសំដៅលើប្រជាជន អត់យល់។

**ស៖** ដើម្បីឲ្យច្បាស់សម្រាប់ប្រតិចារឹក កុំឲ្យមានការជំទាស់ពីសហព្រះរាជអាជ្ញា។ នៅត្រង់ទំព័រដដែលនេះ អ្នកនិពន្ធនិយាយថា ពួក៧ <គឺជាទាហាន។ "ទាហានពួក៧>បានចូលមក<២> គីឡូម៉ែត្រមកខាងក្នុង។ នេះមិនមែនជាប្រជាជនវៀតណាមទេ គឺកងទ័ពវៀតណាមហើយ មិនអាចជំទាស់បានទេ កន្លែងនេះ។ ខ្ញុំសូមអានសម្រង់មួយទៀតចេញពីការផ្សាយវិទ្យុសំឡេងពីភ្នំពេញទាក់ទងទៅនឹងស្ថានភាពនៅមណ្ឌលគិរី គឺស្ថានភាពនៅក្នុងខែមីនា ៧៨ នៅពេលដែលលោកគឺជា ប្រធានតំបន់ ១០៥ ជាតំបន់ឯករាជ្យនេះ ហើយខ្ញុំសូមអានឲ្យលោកស្តាប់សិន ហើយខ្ញុំសួរទៅលោកមើល ថាតើការផ្សាយសំឡេងតាមវិទ្យុនេះ វាឆ្លើយតបទៅហ្នឹងបទពិសោធន៍ប្រចាំថ្ងៃរបស់លោកដែរឬក៏យ៉ាងណា? លោកប្រធានខ្ញុំអានសម្រង់ដែលមានតែអង់គ្លេសទេ E3/1360, ERN ជាភាសាអង់គ្លេស 00169884 មានតែជាភាសាអង់គ្លេសទេ។ ឯកសារនេះហៅថាជារបាយការណ៍ចុះថ្ងៃទី០២ មីនា ៧៨ គឺការឈ្លានពានពីសំណាក់សាធារណរដ្ឋសង្គមនិយមវៀតណាមចូលមកក្នុងខេត្តមណ្ឌលគិរី។ "នៅម៉ោង <0៦00> ថ្ងៃទី០២ ខែមីនា កងទ័ពវៀតណាមបានចូលឈ្លានពានមកដាក់ដាំនៅមណ្ឌលគិរី ចូល១គីឡូម៉ែត្រមកក្នុងបូរណភាពដែនដីរបស់យើង។ យើងបាញ់ពួកវា ហើយសម្លាប់ពួកវាអស់<១៦>នាក់។ <អ្នកនៅរស់បានរត់គេចខ្លួនទៅវិញទាំងចលាចល ដោយបន្សល់ទុកខ្មោច>ពួកវាប្រាំពីរនាក់<>។ យើងរឹបអូសបាន<កាំភ្លើង>អាកាពីរដើម <>កាំភ្លើង<យន្ត>ពីរដើម កាំភ្លើង<>អឹម៧៩ <បីដើម អង្ករមួយជាល និងម្សៅសម្រាប់ធ្វើនំ>។ <ខ្ញុំចាប់អារម្មណ៍នឹងវាក្យខណ្ឌបន្តទៅទៀតលោកសាក្សី។ វាក្យ-ខណ្ឌនោះនិយាយថា "នៅពេលនិយាយពីពាក្យផ្អែមល្ហែម> ភាតរភាព សាមគ្គីភាពជាមួយ<ប្រជាជន> កម្ពុជា ការចរចា<សន្តិភាព និងការ>គោរពទៅដល់ឯករាជ្យភាព <បូរណភាពទឹកដី> និងអធិបតេយ្យភាពនៃកម្ពុជា ខ្មាំងវៀតណាមនៅតែចង់លេបទឹកដីកម្ពុជា ហើយដាក់បញ្ចូលទៅក្នុងសហព័ន្ធឥណ្ឌូចិន។ ហើយវាក៏បានបន្តឈ្លានពានមកតាម ព្រំដែនរបស់យើងចូលមកក្នុងបូរណភាព ផ្គោងដាក់យើង ហើយបញ្ជូនគិញ <និងកងកម្មង់ដូមក>ធ្វើ<ចារកម្ម ស៊ើបការណ៍ និងធ្វើ>វិទ្ធង្សនា និងធ្វើសកម្មភាព <> បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ វាលស្រែ ស្រូវអង្កររបស់ប្រជាជនយើងនៅតាមតំបន់ព្រំដែន។ ហេតុដូច្នេះឯងប្រជាជនយើងបាន<>មានជំហរប្រុងប្រយ័ត្នបដិវត្តខ្ពស់ និងដើម្បីទប់ស្កាត់ <និងកម្ទេច>ចំពោះ <ល្បិចកលខ្មៅកខ្វក់ ក្នុងការបង្ក>សកម្មភាព<ឈ្លានពាន និង>បង្កប្រទូសរ៉ាយ<ពីសំណាក់វៀត-ណាម> ដើម្បីការពារទៅដល់បូរណភាពដែនដី ឯករាជ្យភាពទឹកដី <អធិបតេយ្យភាព> កិត្តិយស ក៏

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដូចជាបូរណភាពដែនដីរបស់កម្ពុជា<ជារៀងរហូត>”។ លោកសាក្សី សំណួររបស់ខ្ញុំសួរថា តើការផ្សាយតាមវិទ្យុផ្សាយសំឡេងទីក្រុងភ្នំពេញនេះ<> ឆ្លុះបញ្ចាំងទៅលើបទពិសោធន៍របស់លោកប្រចាំថ្ងៃចំពោះស្ថានភាពនៅក្នុងខេត្តមណ្ឌលគិរីក្នុងឆ្នាំ៧៨ នោះដែរទេ?

[០៩:២៧:១៣]

**ឆ៖** បាទ អាហ្នឹងគឺ តាំងពីជួបប្រសាសន៍ហ្នឹងគឺត្រឹមត្រូវហើយ គឺតាមព្រំដែនហ្នឹងគឺវៃលុកមិនសព្វ មិនចេះសូវទេ គឺវៃជាបន្តបន្ទាប់។ ជួនកាលវៃខាងនេះ ជួនកាលវៃខាងនោះ យើងកងទ័តិច មិនដឹងទប់ឯណា ទប់ខាងនេះចូលខាងនោះ ទប់ខាងនោះចូលខាងនេះទៅ វៃជាប់រហូតហ្នឹង។

**ស៖** ការផ្សាយសំឡេងតាមវិទ្យុនេះ និយាយអំពី<ការស៊ើបការណ៍ និងការធ្វើសកម្មភាព> វិទ្ធង្សនា តើលោកអាចជម្រាបជូនតុលាការបានទេ <ពាក់ព័ន្ធទៅនឹងសកម្មភាពទាំងអស់នេះ? តើ> លោកមានឧទាហរណ៍ជាក់លាក់ណាមួយទេ ពាក់ព័ន្ធទៅនឹងការធ្វើ<ចារកម្ម ការស៊ើបការណ៍ និងការធ្វើ>សកម្មភាពវិទ្ធង្សនាជាដើម<នោះ>?

**ឆ៖** ហ្នឹងគឺខ្ញុំលើកជាឧទាហរណ៍ជាក់ស្តែង អត់យល់ទេរឿងចារកម្មនោះ វាចូលទៅត្រង់ណាទិសណា ទៅដល់ណា អត់សូវយល់ វាចេះតែឃើញ ជាចូលមកៗអ៊ីចឹង វាទៅជាចារកម្មតាមភូមិ តាមស្រុកអីវា យើងវារកមុខវាមិនឃើញ។

**ស៖** ខ្ញុំសូមលើកឧទាហរណ៍បង្ហាញទៅលោកដែលអាចនឹងជួយរំឭកដល់ការចងចាំរបស់លោក លោកសាក្សី ខ្ញុំយោងទៅលើឯកសារ E3/7960 ជាសេចក្តីសង្ខេបនៃចម្លើយដែលខ្ញុំបានប្រើពីមុនពាក់ព័ន្ធទៅនឹង<កងទ័ព>មកពីកងពល៩២០ម្នាក់។ លោកសាក្សី កងទ័ពមកពីកងពល៩២០នេះនិយាយអំពីចលនា ខាំ ភូន ឬក៏ចលនាបះបោរ ហើយគាត់និយាយថា ខាំ ភូន បាននាំយកវៀតណាមមកចូលមកក្នុងបូរណភាពទឹកដីកម្ពុជា តាមរយៈមនុស្សម្នាក់ដែលលោកបានលើកឈ្មោះឡើងពីម្សិលមិញ គឺឈ្មោះ ស្វាយ។ ហើយពួកវៀតណាមនេះ គឺថាគេបង្កប់ទុកនៅក្បែរភូមិ។ តើលោកមានដឹងអំពីសកម្មភាព ខាំ ភូន ហើយដឹងថា ស្វាយ បាននាំយកវៀតណាមស្ងាត់ៗមកចូលមកក្នុងបូរណភាពដែនដីកម្ពុជា ហើយលាក់ទុកនៅក្បែរភូមិស្រុក។ លោកដឹងទេ?

[០៩:៣០:៣៤]

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ។ ខ្ញុំពីមុនអត់ដឹងទេ ដល់មកខាងតំបន់គេហៅមកប្រជុំ គេថាមានពួកវៀតណាមចូលមក កន្លែង ឃើញយកបាយ យកមី យកត្រីខ ទៅទូលឲ្យពួកវៀតណាម។ ពួកក្បែរផ្ទះ

ខាំ ភូន និង ស្វាយ ហ្នឹងឯង។ គេថា ខាង -- ទៅប្រជុំហ្នឹង គេលើកអ៊ីចឹង ពួកខ្ញុំចេះតែ -- ហើយម្ដងនេះ គេទៅមើលច្រើនដែរ តែខ្ញុំមិនបានទៅ ខ្ញុំវាមិនសូវស្រួលខ្លួន គេទៅមើលអាកន្លែងស៊ីបាយ ស៊ីអី ឃើញមែន កញ្ចប់មី កញ្ចប់អីហ្នឹង ប៉ុន្តែប្រជាជនទេ អ្នកភូមិជិតខាងនុំងគេឃើញ។ គេថា កុំប្រាប់អានេះអង្គការថ្មី ចូលមក មកជួយកម្ពុជាយើង។ គេនិយាយជាមួយប្រជាជនហ្នឹង និយាយអ៊ីចឹង ប៉ុន្តែខ្ញុំអត់ឃើញទេ។ ជាក់ស្ដែង ខ្ញុំអត់ឃើញ ខ្ញុំមិនបានទៅ។

**ស៖** តើកងពល៩២០ និងកងពល៨១០ឬ ដែលបានចូលរួម<ដោះស្រាយការឈ្លានពានរបស់វៀតណាម និង>ចេតនារបស់វៀតណាម <ក្នុងការ>ធ្វើវិទ្ធង្សនា <និងឈ្លបយកការណ៍នោះ>? តើវាជាភារកិច្ច<ចម្បង>របស់កងពលទាំងពីរនេះឬ <ក្នុងការ>ដោះស្រាយ<>ជាមួយវៀតណាមនោះ? លោកសាក្សី លោកកំពុងតែនៅជាមួយយើងឬអត់ទេលោក? លោកសាក្សី លោកស្ដាប់ឮសំណួរខ្ញុំដែរ?

**ប្រធានអង្គជំនុំ៖**

មានបញ្ហាៗ ច្នេកទេស។

សួស្ដីលោកសាក្សី សៅ សារុន តើលោកឮដែរឬទេ?

**លោក សៅ សារុន៖**

បាទ ឮ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

លោកមេធាវី សូមអញ្ជើញតាំងសំណួរបន្តទៀត។ ដូចជា មិនមានបញ្ហាផ្នែកខាងបច្ចេកទេសសោតទស្សន៍ទេ។

[០៩:៣៣:៣៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី សំណួរខ្ញុំសួរថា <>តើវាជាភារកិច្ច<ចម្បង>របស់កងពល៩២០ និងកងពល៨១០ឬ ដែលត្រូវដោះស្រាយ<>ការវាយប្រហារ<ជាបន្តបន្ទាប់>ពីសំណាក់វៀតណាម? <តើវាជាតួនាទីរបស់ពួកគេឬ គឺមិនមែនជាតួនាទីរបស់លោកទេ>?

**លោក សៅ សារុន៖**

**ឆ៖** បាទ អាហ្នឹង គឺខ្ញុំ អាហ្នឹងគឺកងពល៩២០ កងពល៨១០ ហ្នឹងខ្ញុំអត់យល់ទេ។ រឿងកង

01239155



ពលខាងណា ខាងក្រចេះ មិនដឹង ខ្ញុំអត់យល់។ ខ្ញុំយល់តែកងពល៩២០ ពីព្រោះអាហ្នឹងគេចូលមកនៅមណ្ឌលគិរី ដើម្បីការពារ ពីព្រោះតំបន់វាអត់មានកងទ័ពទេ កងទ័ព១០០, ២០០ ហ្នឹង។ ខាងកងពល៩២០ គេមានកម្លាំងចាត់ការគេ។ កងពលតំបន់មានអីទេ មានតែ -- អាវុធអីក៏មិនមានដែរ មានតែអាកាមួយដើម ពីរដើម។

**ស៖** លោកសាក្សី ខ្ញុំយល់ចម្លើយលោកហើយ។ មុននឹងខ្ញុំបន្តចូលទៅសួរលោកអំពីមហាសន្និបាត ខែកញ្ញា ៧៨។ ខ្ញុំសួលោកបន្តទៀតសិនអំពីពួកប្រាំពីរ។ <> ខ្ញុំសូមបង្ហាញឡើងម្តងទៀតនូវសារទូរលេខដែលពាក់ព័ន្ធនឹង<ពាក្យថា ក្រុម៧>នេះ <>គឺឯកសារE3/1030 ជាសារទូរលេខសរសេរឡើងដោយឈ្មោះ<> សុភា នេះជាឈ្មោះមនុស្សម្នាក់ដែលលោកបានលើកឈ្មោះឡើងពីម្សិលមិញ។ <មូលហេតុដែលខ្ញុំអាន>សារទូរលេខនេះ<ឲ្យលោកស្តាប់> គឺដោយសារវាពាក់ព័ន្ធទៅស្រុកដែលនៅពេលនោះ លោកគឺជាលេខាស្រុកនៅឡើយទេ។ ខ្ញុំសូមអាននូវអ្វីដែល សុភា សរសេរផ្ញើជូនទៅថា " សមមិត្ត ឆាន ជាទីស្នេហា និងនឹករឭក។ <យើងមិនច្បាស់ថាគាត់ជាអ្នកណាទេ។ ពួកគេអាចជាទ្បាំង ឬក៏តាហំ ប៉ុន្តែ>មិនថ្វីទេ។ អ្វីដែលគាត់សរសេរនោះគឺនៅថ្ងៃទី២១ ខែមិថុនា ៧៧ "ក្រុមពួក៧ ដែលវាយយើងនៅពេជ្រាដានោះ ឥឡូវបានចូលមកទិសភូមិពូជ្រីចាស់ និងភូមិតុញ និង<ភូមិ>ដេអេ គ្នាវាប្រហែល៣០នាក់។ <>យើងកំពុងចាត់ចែងកម្លាំងទៅស្ទាក់<វាយប្រហារពួកវា>។" លោកសាក្សី នេះគឺជាសារទូរលេខ<និយាយពី>ស្រុករបស់លោក នៅពេលដែលលោកជាលេខាស្រុក ហើយ សុភា និយាយអំពីការវាយប្រហារពីសំណាក់ពួក៧ ចូលមកពេជ្រាដា។ តើលោកនឹកឃើញរឿងនេះទេ?

[០៩:៣៦:៥៤]

**ឆ៖** ថាចូលមកហ្នឹងគឺអត់នឹកឃើញទេថា មានសារពី សុភា ហ្នឹងគឺថា៧ ចូលមកពូជ្រី, ដេអេ ហ្នឹងវាជិតមកកក់--

**ស៖** មិនអីទេលោកសាក្សី ខ្ញុំបន្តទៅមុខទៀតចុះ។ ខ្ញុំចូលទៅនិយាយអំពីមហាសន្និបាតបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ៧៨ លោកបានឆ្លើយពីចំណុចនេះរួចមកហើយដែរ។ គឺនៅក្នុងឆ្នាំ២០១២ ដែលលោកបានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយលោកក៏បានឆ្លើយជូនមន្ត្រីស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតរួចមកហើយដែរ។ ខ្ញុំសូមបង្ហាញជូនលោកគឺឯកសារ E3/404 ERN ជាភាសាអង់គ្លេស 00403025, ខ្មែរ 00398480, បារាំង 00484199។ លោកបាននិយាយអំពីមហាសន្និបាតដ៏ឱឡារិកដែលមានប្រជាជនចូលរួម<រាប់រយនាក់> ប៉ុល ពត បានថ្លែងសុន្ទរកថា។

ដើម្បីឲ្យ<>ច្បាស់លាស់ តើនេះគឺជាមហាសន្និបាត<>បក្សកុម្មុយនីស្តកម្ពុជាលើកទី១៨ ឬក៏យ៉ាងណា?

**ឆ៖** បាទ គឺមហាសន្និបាតហ្នឹងគឺសន្និបាតប្រចាំឆ្នាំ អាហ្នឹងគឺដូចខ្ញុំបានរាយការណ៍ជូនថ្ងៃមុនហើយ។ សន្និបាតបក្ស និងកម្មាភិបាលទូទាំងប្រទេសគ្រប់ស្ថាប័ន តាំងពីខាងស៊ីវិល តាំងពីខាងទាហានគេចូលសន្និបាតៗប្រចាំឆ្នាំរបស់បក្ស។

[០៩:៣៩:២៥]

**ស៖** ចុះលោកយល់ស្របជាមួយខ្ញុំទេ គឺឯកសារ E3/215 ជាខួបលើកទី១៨ នៃមហាសន្និបាតបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវប្រារព្ធឡើងនៅចន្លោះពីថ្ងៃទី១៨ ខែកញ្ញា ទៅដល់ថ្ងៃទី៣០ ខែកញ្ញា គឺជាមហាសន្និបាតមួយដែលមានរយៈពេលរហូតទៅដល់ ១២ថ្ងៃ។ លោកនឹកឃើញទេ?

**ឆ៖** ឆ្នាំទីប៉ុន្មាន? ខ្ញុំច្រឡំគ្នា ឆ្នាំណាគេសន្និបាតខួបហ្នឹង។ សូមឲ្យអានម្តងទៀត អត់យល់ច្បាស់។

**ស៖** គឺមហាសន្និបាត<នៅខែកញ្ញា ថាតើវាធ្វើរយៈពេលពីរបីថ្ងៃឬ ហើយតើវា>បានប្រារព្ធធ្វើ<នៅ>ខួបលើកទី១៨ នៃការបង្កើតបក្សកុម្មុយនីស្តកម្ពុជា<ឬ?>

**ឆ៖** បាទ ហ្នឹងច្បាស់មែន។ អាហ្នឹងគឺដូចយល់ស្របហើយ។

**ស៖** នៅក្នុងឯកសារទស្សនាវដ្តីទង់បដិវត្តសុន្ទរកថាដែល ប៉ុល ពត បានថ្លែង ហើយលោកលើកយកមកឆ្លើយនោះគឺ វាមានសរសេរនៅក្នុងទស្សនាវដ្តីទង់បដិវត្តយ៉ាងពេញលេញមែន។ ឥឡូវខ្ញុំសូមបង្ហាញលោកនូវអ្វីដែល ប៉ុល ពត បាននិយាយពាក់ព័ន្ធទៅនឹងជនជាតិវៀតណាម និងប្រទេសវៀតណាម។ លោកប្រធាន គឺឯកសារ E3/215, ERN ជាភាសាខ្មែរ 00064610, បារាំង 00524077, 00488626។ នេះគឺឯកសារខាងដើម ដែលខ្ញុំសំដៅទៅលើលោក ហ៊ីនតុន នោះ។ ខ្ញុំនឹងមិនអានសម្រង់នេះទាំងស្រុងឡើងវិញទេ លោក ដោយសារតែពេលវេលាខ្ញុំខ្លី។ ប៉ុន្តែត្រឹមត្រូវដែរទេ នៅពេលដែល ប៉ុល ពត បានថ្លែងសុន្ទរកថា<>អំពីប្រទេសវៀតណាម និងគោលនយោបាយរបស់វៀតណាម? តើគាត់មានញែកពីគ្នាឲ្យដាច់ពីគ្នាទេ រវាងពាក្យថាប្រជាជនវៀតណាម? ហើយម្យ៉ាងទៀត នៅពេលដែលគាត់ថ្លែងពាក់ព័ន្ធទៅនឹងគោលនយោបាយបរទេសវៀតណាម គឺគាត់ប្រើពាក្យ "យួន"។ តើលោកយល់ស្របនៅត្រង់ចំណុចនេះទេ?

**ឆ៖** បាទ យល់ស្រប។

[០៩:៤២:៥០]

**ស៖** នេះគឺជាសេចក្ដីថ្លែងដែលគាត់បានថ្លែងទៅកាន់សមមិត្តរួមអាវុធរបស់លោកនោះរាប់រយ រាប់ពាន់នាក់ តើ<នេះជាអ្វីដែលគាត់បាននិយាយជាមួយលោក>ដោយផ្ទាល់ដែរទេ?

**ឆ៖** បាទ ស្ដាប់តើ តែវាយូរហើយ យូរ ភ្លេចភ្លាំងអស់ហើយ សេចក្ដីគាត់ថ្លែងការណ៍ហ្នឹង។ សំខាន់គាត់ថ្លែងការណ៍ពីរឿង ដូចមិញៗអ៊ីចឹងឯង។ យល់ស្របហើយ។

**ស៖** ខ្ញុំយល់ហើយសាក្សី។ ម្សិលមិញនោះ លោកបានឆ្លើយថា ប៉ុល ពត មិនបានស្អប់ប្រជាជនវៀតណាមទេ ប៉ុន្តែគាត់ស្អប់ពួកវៀតណាមឈ្លានពាន ពួកយួនឈ្លានពាន។ តើនេះគឺជាអ្វីដែលគាត់បានថ្លែងជាសារធារណៈ ឬក៏គាត់និយាយជាមួយនឹងលោកជាឯកជន ឬក៏យ៉ាងណា?

**ឆ៖** បាទ អាហ្នឹងគឺ គាត់ថ្លែងការណ៍នេះគឺបញ្ជាក់ក្នុងពេលប្រជុំហ្នឹងទេ។ យើងអត់ខឹង អត់ប្រឆាំងជនជាតិវៀតណាមទេ ពីព្រោះជនជាតិវៀតណាមមិនមែនជាអ្នកឈ្លានពានទេ។ គ្នាផ្សេង កងទ័ពវៀតណាមជាអ្នកឈ្លានពាន។ គាត់ថ្លែងការណ៍អ៊ីចឹងមែន។

**ស៖** <តើលោកមាន>បទពិសោធន៍<អ្វី>ចន្លោះពីឆ្នាំ៧៥ ទៅ ៧៩ បាទ <ឬ>ពីឆ្នាំ៧០ <> ដល់ ៧៩? តើ<វាជាតួនាទី>របស់លោក <និង>កម្មាភិបាល<ផ្សេងទៀត ដែលលោកនិយាយជាមួយ >ពាក់ព័ន្ធទៅនឹងគោលនយោបាយ<ការ>បរទេសវៀតណាម <ហើយនិងវៀតណាម>ដែល<គេ> ប្រើពាក្យ<ថា>"យួន" <ត្រូវបានគេប្រើ ហើយ>មិន<មានការ>ស្អប់<ចំពោះប្រជាជនវៀតណាម នោះ>?

**ឆ៖** អាហ្នឹង គឺយល់អ៊ីចេះ តាមយើង ភាគច្រើនគេយល់អ៊ីចេះ! គេថា ជួលកាលគេថាយួន ដូចគេថាយើងហ្នឹង ខ្មែរ កម្ពុជា វាអ៊ីចឹង។ យួនឈ្លានពាន។ អ្នកខ្លះ វៀតណាមឈ្លានពាន។ និយាយភាសាពីរអ៊ីចឹង។

[០៩:៤៥:៥៦]

**ស៖** បាទ ខ្ញុំសូមអានសម្រង់ សុន្ទរកថារបស់ ប៉ុល ពត ហើយនិង<>ខ្ញុំនឹងសួរលោកថា តើលោកនៅចាំ ប៉ុល ពត ឬក៏ នួន ជា បាននិយាយពាក្យពេចន៍នេះទៀត ក្នុងលក្ខណៈ ឯកជនដែរឬទេ? គឺឯកសារ <E3/215> ជាភាសាអង់គ្លេសគឺ 00488621, 00064595 ដល់ 96, ជាភាសាបារាំងគឺ 00524072 ដល់ 73។ បាទ ខ្ញុំសូមដកស្រង់សម្រង់សុន្ទរកថារបស់ប៉ុល ពត <ដែលលោកបានចូលរួមនៅខែកញ្ញា>ឆ្នាំ១៩៧៨<>គាត់និយាយដូចតទៅអំពីយុទ្ធសាស្ត្ររបស់វៀតណាម៖ "<យុទ្ធសាស្ត្ររបស់

យួន និង>សូវៀត<វាតទីនិយម> ដែល<ប៉ុនប៉ង>ចង់យកប្រទេសកម្ពុជាបាន<បានបង្ហាញខ្លួនជាថ្មី។> យួន <និងអន្តរជាតិវាតទីនិយមសូវៀតបានចូលរួមជាមួយគ្នា ដើម្បី>វាយប្រទេសកម្ពុជា<យើងពីព្រោះពួកវាមាន>ទិសដៅ<ដូចគ្នា។ ចំពោះ>យួន <វា>មានបំណងចង់យកកម្ពុជា<>តាំងពី<ឆ្នាំ១៩៣០> តាម<យុទ្ធសាស្ត្រសហព័ន្ធ>ឥណ្ឌូចិន <និងតាមគោលនយោបាយយួនអំពីប្រទេសមួយប្រជាជាតិមួយ ក្រោមការដឹកនាំរបស់គណបក្សតែមួយ។> វៀតណាមចង់ក្លាយជាប្រទេសដែលខ្លាំងជាគេបំផុតនៅ<ឥណ្ឌូចិន និងនៅ>អាស៊ីអាគ្នេយ៍<ផងដែរ។> ចំណែកឯពួកសូវៀត<វាតទីនិយមអន្តរ-ជាតិ>វិញ <ពួកវា>មាន<យុទ្ធសាស្ត្រ>ពិភពលោក<របស់វាផ្ទាល់>តែម្តងនោះ គឺគេចង់គ្រប់គ្រងអាស៊ីអាគ្នេយ៍<>។ <ដូច្នេះហើយទើបពួកវាខឹងខ្លាំងណាស់>។ នៅ<ចុង>ឆ្នាំ<១៩៧៧> ពួកវាចាប់ផ្តើមវាយកម្ពុជាទ្រង់ទ្រាយធំណាស់ មានទាំងយួន ហើយមាននិងពួកវាតទីនិយមអន្តរជាតិសូវៀត ហើយនិង<>បក្សពួកវារួមគ្នា។" <ហើយបន្ទាប់មក គាត់និយាយអំពីកងទ័ព១៤កងពលរបស់វៀតណាមដែលបានចូលពាក់ព័ន្ធ។> លោកសាក្សី តើលោកចាំពីរឿងរ៉ាវនេះដែរឬទេ? លោកមានចាំសុន្ទរកថារបស់ ប៉ុល ពត នេះទេ គាត់ថ្លែងសុន្ទរកថានេះនៅក្នុងឱកាសសន្និបាតមួយដែលលោកបានចូលរួមដែរ?

**ឆ៖** បាទ អាហ្នឹងគឺបានចាំ។ គាត់បានថ្លែងការណ៍ សុន្ទរកថាហ្នឹងមែន។ បន្ទាប់ទៀតគាត់ថា "យើងប្រយ័ត្នប្រយែង ពាក់ព័ន្ធនឹងយួន-វៀតណាមហ្នឹងវាមានជាប់ទាក់ទងគ្នា *(ឮមិនច្បាស់)*។

**ស៖** <តើលោកចាំទេថាតើលោកបានឮពាក្យនោះនៅពេលណា?> តើលោកគិតថាគាត់និយាយអ៊ីចឹង ត្រឹមត្រូវដែរឬទេ? <>តើមតិយោបល់របស់គាត់ហ្នឹង វាស៊ីគ្នានឹង<បទពិសោធន៍>របស់លោកដែរឬទេ?

[០៩:៤៩:៥៩]

**ប្រធានអង្គជំនុំ៖**

លោកសាក្សី តើស្តាប់សំណួរបានទេ?

**លោក សៅ សារុន៖**

ស្តាប់បានខ្លះដែរ ប៉ុន្តែកន្លែងខ្លះមិនចាំ មិនយល់។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី លោកចង់ដឹងពីយោបល់របស់សាក្សី នៅពេលដែលគាត់ស្តាប់ឮ សុន្ទរកថាហ្នឹង<ឬ>?

**លោក វ៉ិចទ័រ កូប៉េ៖**

តាមពិតខ្ញុំចង់ដឹង<ថាតើគាត់>យល់<ស្របនឹង>ខ្លឹមសារនៃសុន្ទរក<ហ្នឹងទេ>។

**<ចៅក្រម ក្លូឌា ហ្វេនស៍៖>**

<អ៊ីចឹងម៉េចបានលោកមិនសួរសំណួរទៅ?>

**<លោក វ៉ិចទ័រ កូប៉េ៖>**

<អត់បញ្ហាទេ ខ្ញុំនឹងរៀបសំណួរឡើងវិញ។>

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកយល់ស្របនឹង ប៉ុល ពត ដែរឬទេ ពេលដែលគាត់និយាយអំពីមហិច្ឆតារបស់វៀតណាមនោះ ហើយនិងសហភាពសូវៀត?

**លោក សៅ សារុន៖**

**ឆ៖** បាទ យល់ស្រប។ ពីព្រោះវា គាត់បញ្ជាក់ច្បាស់ណាស់ ទិសដៅរបស់គេ ហ្នឹងគឺគេយកកម្ពុជាចូលក្នុងសហព័ន្ធឥណ្ឌូចិន គាត់បញ្ជាក់អ៊ីចឹង។ តែយើងស្តាប់ ឃើញហើយ ដូចជាក់ស្តែង គេវាយតាមលុកតាមព្រំដែនជារហូត អាហ្នឹងគឺថាតាមលោក ប៉ុល ពត គាត់បានឧទ្ទេសនាម គាត់ថាជាយុទ្ធសាស្ត្ររបស់គេ គេយកកម្ពុជាចូលក្នុងសហព័ន្ធឥណ្ឌូចិន។ គាត់បញ្ជាក់ច្បាស់អ៊ីចឹងតែម្តង។

**ស៖** លោកសាក្សី <រយៈពេលតែ>បីខែក្រោយមក<ប៉ុណ្ណោះ> វៀតណាមដែលមានការគាំទ្រពីសហភាពសូវៀត បន្ទាប់ពីបានចុះយុត្តាធិការយោធាជាមួយគ្នានោះ ក៏បានចូលមកឈ្លានពានប្រទេសកម្ពុជា។ នៅពេលនោះ <ក្នុងអំឡុងពេល>បុណ្យខួបទី១៨ <នេះ តើ>គេបានត្រៀមលក្ខណៈដើម្បីទប់ទល់នឹងការឈ្លានពានរបស់វៀតណាម<ទេ?> តើ<គេមានដឹងជាមុន>ទេ ថាបីខែក្រោយមក វៀតណាម<>ចូលមកឈ្លានពានប្រទេសកម្ពុជាហើយ<បន្តបន្ទាប់មកទៀត> បានមកកាន់កាប់ប្រទេសកម្ពុជារយៈពេល១០ឆ្នាំទៀតផង។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[០៩:៥២:៤៦]

**ស៖** ខ្ញុំចោទសំណួរខ្ញុំមួយសាទៀត។ តើលោកដឹងដែរឬទេ ថានៅមណ្ឌលគិរី ឬក៏តំបន់១០៥ មានការត្រៀមលក្ខណៈយោធា ដើម្បីទប់ទល់នឹងការឈ្លានពានរបស់វៀតណាម ដែលបានធ្វើឡើងបីខែក្រោយពី ប៉ុល ពត ថ្លែងសុន្ទរកថាហ្នឹង?

**ឆ៖** បាទ គាត់បានបញ្ជាក់មែន ត្រៀមដើម្បីទប់ទល់វៀតណាមឈ្លានពានទឹកដីកម្ពុជា ត្រៀមលក្ខណសម្បត្តិរៀបចំ លក្ខណៈសម្បត្តិដើម្បីត្រៀមទប់ទល់ អាហ្នឹងគាត់បានបញ្ជាក់ -- បញ្ជាក់ច្បាស់។

**ស៖** តើលោកមានចាំដែរឬទេ អំពីការត្រៀមលក្ខណៈនុ៎ង? នៅមណ្ឌលគិរី ឬក៏តំបន់១០៥នុ៎ងមានត្រៀមលក្ខណៈអ្វីខ្លះ ដើម្បីទប់ទល់នឹងការឈ្លានពានរបស់វៀតណាម? តើរូបលោកផ្ទាល់ លោកបានចូលរួមក្នុងការត្រៀមលក្ខណៈហ្នឹងដែរឬទេ?

**ឆ៖** បាទ ក្រោយពីសេចក្ដីថ្លែងការណ៍ហើយ ក៏បានត្រៀមរៀបចំកងទ័ពដើម្បីទប់ទល់ តាមលទ្ធភាពដែលយើងអាចធ្វើបាន។ ពីព្រោះកងទ័ពតំបន់នេះជាកងទ័ពតិចទេ ក៏ត្រៀមលក្ខណៈសម្បត្តិដើម្បីរួមសហការជាមួយកងពលគេ។ បាទសូមអស់។

**ស៖** តើលោកដឹងដែរឬទេ ថាកងទ័ពតំបន់១០៥នោះ អាចឈ្នះនឹងការឈ្លានពានរបស់វៀត-ណាមដែរឬទេ?

**ឆ៖** សូមឆ្លើយ។ គឺបញ្ហាហ្នឹងសន្និដ្ឋានមិនបានទេ ពីព្រោះគេប្រទេសធំ យើងប្រទេសតូច កងទ័ពតិច ហើយក្រ អាវុធសាស្ត្រាក៏មិនទំនើប មិនសម្បូរបែប។ ហើយអាកាំភ្លើងទំនើបៗវាមានប្រទេសប៉ុន្តែមិនទាន់ចេះប្រើ នៅមិនទាន់បានរៀនបច្ចេកទេសអី ស្រាប់តែយកប្រជាជនពីស្រុកស្រែចម្បាំង ចប់សង្គ្រាមហើយ គេថាលើកគោលការណ៍ថាទិញមួយស្តារសេដ្ឋកិច្ច *(ឮមិនច្បាស់)*។ ទី២ ការពារទឹកដី គេយកសេដ្ឋកិច្ចហ្នឹងជាខទី១ហ្នឹង។ អីចឹងរឿងការពារទឹកដីនេះក៏វាការពារដែរ ប្រទេសអាវុធសាស្ត្រាក៏វាខ្សោយ ខាងតំបន់ ខាងកងពលទេ គេមានអាវុធសាស្ត្រា ខាងតំបន់អីអត់មានទេ មានកាំភ្លើងអាកាពីរបីដើមទេ មានតែមួយដើមពីរទេ ពីព្រោះកងតំបន់គេថាគ្រាន់តែការពារតិចតួចទេ អាកា--

[០៩:៥៦:២៨]

**ស៖** បើតាមរូបលោកនៅក្នុង<សន្និបាត>បុណ្យខួបទី១៨<នៅខែកញ្ញានោះ គឺ>មានសេចក្ដីណែនាំចុះ<ខែកក្កដា>ឆ្នាំ១៩៧៨ <>ឲ្យ<>លើកលែងទោស<ចំពោះខ្មាំងជាក់លាក់មួយចំនួន>។ តើលោក<>មានចាំទេពីសេចក្ដីណែនាំ<>ឲ្យលើកលែង<>នោះ? <តើនៅពេលនេះ លោកចងចាំអ្វីខ្លះអំពីហេតុការណ៍នោះ?>

**ឆ៖** បាទ សូមឆ្លើយ។ អាហ្នឹងគាត់បានណែនាំច្បាស់ ការខុសឆ្គង ឬក៏ភ័ន្តច្រឡំអី អាហ្នឹងគាត់ឲ្យលើកលែងទោសមិនឲ្យមានការចាប់ខ្លួន មិនឲ្យមានការចងទេ អាហ្នឹងគេប្រកាសទូទាំងប្រទេសតែម្តង យកឧបករណ៍គាត់ប្រកាសផ្ទាល់មាត់គាត់តែម្តង។ ឲ្យតែរឿងណែនាំធ្វើម៉េចឲ្យកែប្រែ យើង

ប្រទេសខ្មែរយើង ធ្វើយ៉ាងម៉េចកុំរួមដៃរួមជើង ហើយនិងលក់ទឹកលក់ដីឲ្យបរទេស ខ្មែរយើងក៏ការពារទឹកដីខ្មែរ ការពារបូរណភាពទឹកដីរបស់ខ្មែរយើង។ បរទេសយើងមិត្តភាពសាមគ្គីភាពជាមួយបរទេស តែយើងអត់មានបង្ករឿងបង្កហេតុទេ។ អ៊ីចឹងគាត់បានបញ្ជាក់ក្នុងហ្នឹងច្បាស់ណាស់។

**ស៖** សេចក្ដីណែនាំហ្នឹងត្រូវបានបោះពុម្ពផ្សាយនៅខែកក្កដា ឆ្នាំ១៩៧៨។ លោកបាននិយាយថា គេបានប្រកាសផ្សាយសេចក្ដីណែនាំនេះនៅបុណ្យខួបទី១៨នេះ តើលោកមាន<ចាំទេថា លោក>បានដឹងពីសេចក្ដីៗណែនាំនេះ<>តាំងពីខែកក្កដា ៧៨ <មិនមែននៅខែ>កញ្ញា <ឆ្នាំ៧៨>ទេ?

**ឆ៖** បាទ ដឹងច្បាស់ហើយ គេសេចក្ដីណែនាំនោះក៏បានផ្សព្វផ្សាយ បានយកមកផ្សព្វផ្សាយដើម្បីឲ្យសាធារណជនហ្នឹងឲ្យយល់ដឹងកងទ័ពទាំងអស់ ឲ្យយល់ដឹង។ បញ្ហាហ្នឹងគឺអស់។

[០៩:៥៩:២២]

**ស៖** ក៏ប៉ុន្តែខ្ញុំចង់ដឹងថាតើលោកដឹងពីសេចក្ដីណែនាំហ្នឹងលើកដំបូងបំផុតនោះនៅពេលណា? តើនៅ<>ខែកក្កដា ឆ្នាំ១៩៧៨ ឬក៏នៅខែកញ្ញា ឆ្នាំ១៩៧៨ គឺក្នុងឱកាសបុណ្យខួបកំណើតទី១៨?

**ឆ៖** តាមខ្ញុំយល់ណា ក្រោយៗសន្និបាតហ្នឹងហើយ ចេញសេចក្ដីណែនាំ។ បាទសូមអស់។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវខ្ញុំសូមយោងទៅអ្វីដែលលោកបាននិយាយនៅក្នុងឯកសារ E3/384 ដែលជាកំណត់ហេតុស្ដាប់ចម្លើយរបស់លោកចំពោះមុខសហចៅក្រមស៊ើបអង្កេត ERN <> ជាភាសាអង់គ្លេសគឺ <00348373>, ជាភាសាបារាំងគឺ 00354237, ជាភាសាខ្មែរគឺ <00345904>។ បាទ សំណួរ<ដែលគេ>សួរ<លោកគឺ> “តើ<ករណីនយោបាយ ឬករណីក្បត់បក្សមានន័យ>យ៉ាងម៉េច?” <ហើយលោកបានឆ្លើយដូចតទៅ៖ “ឧទាហរណ៍ អ្នកដែលសហការជាមួយយួនឈ្លានពាន ឬខ្មាំង មានន័យថា ជាខ្មាំងយួន។ ឧទាហរណ៍សព្វថ្ងៃនេះ សត្រូវឈ្លានពាន បូរណភាពទឹកដីគឺថៃ>។ <តើលោកចាំថាបាននិយាយថា ការក្បត់អង្គការ មានន័យថា សហការជាមួយវៀតណាមឈ្លានពាន គឺខ្មាំងយួន?>

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ។ និយាយថា “ក្បត់ជាតិ” នេះ គេសំដៅថាអ្នករួមដៃរួមជើងជាមួយខ្មាំងសត្រូវបរទេស។ ហ្នឹងគេសំដៅនិយាយអ៊ីចឹង។ អ្នកណារួមដៃរួមជើងធ្វើសកម្មភាពដើម្បីកម្ទេចបំផ្លាញអធិបតេយ្យភាព បូរណភាពទឹកដីរបស់ខ្លួន អាហ្នឹងគេ -- ពាក្យគេថាសំដៅអ្នកហ្នឹង។

[១០:០២:១៥]

**ស៖** សំណួរ ខ្ញុំសូមអានសម្រង់មួយទៀត ដែល<> សុន សេន <បានប្រាប់ទៅមេបញ្ជាការ

កងពលនានា> នៅក្នុងកិច្ចប្រជុំមួយចុះខែ១០ ឆ្នាំ១៩៧៦។ ស្ដីអំពីស្ថានភាពខ្មាំងផ្ទៃក្នុង និង<ខ្មាំង>ខាងក្រៅ។ ចំពោះ<>ខាងក្រៅគាត់សំដៅទៅលើវៀតណាម ហើយនិងសហភាពសូវៀត គឺឯកសារ E3/13 គាត់និយាយដូចតទៅនេះ ERN ជាភាសាអង់គ្លេសគឺ <00940354>, ជាភាសាខ្មែរគឺ <00052413> ទៅដល់ 414, ជាភាសាបារាំងគឺ 00344983។ សំណួរខ្ញុំដូចតទៅនេះ លោកសាក្សី តើលោកយល់ស្របនឹងវិធីសាស្ត្ររបស់ សុន សេន ដែរឬទេ ដែលគាត់បាននិយាយជាមួយនឹងប្រធានកងពល ចំពោះខ្មាំង<នោះ? អត្ថបទនោះនិយាយថា “នៅពេលដោះស្រាយជាមួយខ្មាំងផ្ទៃក្នុង ត្រូវធ្វើតាម>វិធីសាស្ត្រដូចតទៅនេះ៖ ទី១ ត្រូវតែបន្តអប់រំ។ ទី២ ត្រូវបោសសម្អាតសមាសភាពមិនល្អ<>យ៉ាងដាច់ខាត <ក្នុងន័យ>តស៊ូវណ្ណៈដាច់ខាត។ <ការសម្រិតសម្រាំងត្រូវ>ផ្អែកលើមូលដ្ឋានបី ទី១ គឺប្រភេទអន្តរាយ ត្រូវតែសម្រិតសម្រាំងដាច់ខាត។ ប្រភេទទី២ ប្រភេទសេរីធម្មតា ត្រូវអប់រំជាបន្តបន្ទាប់ក្នុងសាលាអប់រំរបស់យើង ហើយប្រភេទទី៣ គឺប្រភេទពួកទើបតែខ្មាំងញុះញង់ ហើយទើបតែជឿការញុះញង់ ជាដំបូងត្រូវតែអប់រំគេឡើងវិញ ដើម្បីកុំឱ្យគេជឿខ្មាំងទៀត”។ តើលោកមានមតិយោបល់យ៉ាងម៉េចដែរ ចំពោះសេចក្ដីថ្លែងរបស់ សុន សេន នេះ? នេះ គឺជាសុន្ទរកថារបស់ សុន សេន ដែលគាត់ថ្លែងទៅប្រធានកងពល។ តើលោកមានចាំអំពីការបែងចែកប្រភេទខ្មាំងទាំងបីប្រភេទនេះដែរ ឬទេ?

**ឆ៖** បាទ ចាំអារឿង គឺថា សេចក្ដីថ្លែងការណ៍របស់ សុន សេន អ៊ីចឹងមែន។ គាត់ថា យើងមិនមែនថាចេះធ្វើពាសវាលពាសកាលទេ ទាល់តែមានការអប់រំ គាត់ថាមនុស្សយើង វាចេះតែភ្លេចតែភ្លាំងទៅ ចេះតែអប់រំទៅ អូសទាញទៅ។ គាត់បញ្ជាក់អ៊ីចឹង វាមានបីប្រភេទអ៊ីចឹងមែន។ គាត់បញ្ជាក់ច្បាស់មិនមែនថាចេះតែឱ្យចាប់ ចេះតែឱ្យចងទេ ឱ្យអប់រំទី១។ គឺសំខាន់ទី១ គឺអប់រំរៀនសូត្រឱ្យគេរៀនយល់ខ្ញុំអស់មតិ។

**សៈ** លោកសាក្សី លោកជិតស្និទ្ធនឹង តាសាន ហើយនិងកងពល៩២០។ នៅពេលដែល ខាំ ភួន សម្លាប់ តាឡាំង <ឬហំ> តើលោកដឹងដែរឬទេថា ពេលនោះមានយោធា<ប្រហែល>១០០នាក់ចេញពីកងពល៩២០ ត្រូវបានដោះលែង<>ចេញពីមន្ទីរស-២១? លោកចាំទេ? លោកដឹងទេ?

**ឆ៖** បាទ អត់ចាំទេ។ មិនដឹងគេជួយពេលណា ខ្ញុំអត់ដឹងដែរ។

[១០:០៦:៥១]

**សៈ** ខ្ញុំរៀបសំណួរខ្ញុំឡើងវិញ។ តើលោកដឹងដែរឬទេថា នៅពេលណាមួយនោះទាហាននៃកងពល៩២០ ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅភ្នំពេញ ហើយត្រូវបានសួរចម្លើយ ហើយត្រូវបានដោះលែង

វិញនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៧។ លោកដឹងទេ?

**ឆ៖** អត់ដឹងទេ ខ្ញុំ។ ឆ្លើយថាអត់ដឹង។

**ស៖** ខ្ញុំសូមកត់ត្រាចូលប្រតិចារឹកគឺថា ខ្ញុំយោងទៅលើឯកសារ E3/8648។ វាជាឯកសារចេញពីមន្ទីរស-២១ ដែលនិយាយអំពីការដោះលែងយោធាចំនួន១០០នាក់ <មក>ពីកងពល៩២០។ យោធាទាំង១០០នាក់នេះ បានទៅដល់មន្ទីរស-២១ នៅថ្ងៃទី២៣ ខែ១១។ <ដូច្នេះ>ហើយបីថ្ងៃក្រោយមក ត្រូវបានដោះលែងចេញវិញ។ លោកសាក្សី តើលោក<ដឹង>ឧទាហរណ៍<ណាមួយ>នៅមណ្ឌលគិរី<ចំពោះអ្នក>ដែលស្ថិតនៅក្នុងប្រភេទ<>ត្រូវអប់រំជាបន្តបន្ទាប់ <ឬក៏អ្នកដែលត្រូវ>កែប្រែឲ្យល្អវិញបានទេ<>?

**ឆ៖** រៀបរាប់អត់បានទេ ព្រោះកងពល៩២០ មិនដឹងគេបញ្ជូនប៉ុន្មាន មិនដឹងអប់រំគេបញ្ជូនមកវិញ ខ្ញុំអត់យល់ អត់ដឹង។ ខាងកងពលគេ ឃើញថាគេទាក់ទងបង ស៊ីន ផ្ទាល់ ខ្ញុំអត់ដឹងគេបញ្ជូនប៉ុន្មានអប់រំ គេបញ្ជូនមកវិញប៉ុន្មាន អត់ដឹង។

**ស៖** ក៏ប៉ុន្តែដល់ពេលដែលលោកពិភាក្សាជាមួយ តាសាន ដែលជា<មេបញ្ជាការ>កងពល៩២០ តើតាសាន នេះធ្លាប់និយាយអំពីយោធានៃកងពល៩២០ នេះដែលត្រូវបានចាប់ខ្លួន ហើយក្រោយមកដោះលែងវិញដែរឬទេ?

**ឆ៖** រឿងហ្នឹងគឺឮ តាសាន គាត់ធ្លាប់និយាយហ្នឹង គេអប់រំបញ្ជូនទៅ។ អាហ្នឹងឮៗគាត់និយាយដែរអាហ្នឹង តែខ្ញុំវាអត់ឃើញនឹងភ្នែក។ វាអត់ច្បាស់លាស់ដែរ ឮគាត់និយាយហ្នឹង។

**ស៖** <នេះគឺ>សេចក្តីណែនាំ<លើកលែងទោស>ខែកក្កដា ឆ្នាំ១៩៧៨<> តើវាជាការបញ្ជាក់<ពីអត្ថិភាព>នៃគោលនយោបាយ<>ចំពោះខ្មាំង ឬក៏វាគ្រាន់តែជាការបកស្រាយពីការបង្ហាញអំពីការវិវត្តន៍នៃ<>គោលនយោបាយ<ទេ? តើលោកអាច>បញ្ជាក់<បានទេ>ថា <តើសេចក្តីណែនាំលើកលែងទោសខែកក្កដា ឆ្នាំ១៩៧៨នោះ អនុវត្តជាក់ស្តែងយ៉ាងម៉េចដែរ>?

**ប្រធានអង្គជំនុំ៖**

សាក្សីស្តាប់សំណួរយល់ទេ? បើមិនយល់ទេ ឲ្យស្តាប់ ឲ្យសួរ ឲ្យអ្នកសួរៗម្តងទៀត។ ឲ្យមេធាវីសួរម្តងទៀតណា៎ះ!

**លោក សៅ សារុន៖**

បាទៗ ឲ្យសួរម្តងទៀត អត់យល់ទេ បើយល់ឆ្លើយហើយ។ អត់យល់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំសូមអភ័យទោសលោកសាក្សី ប្រហែលជាសំណួរខ្ញុំនេះពិបាកបន្តិចហើយ។ បាទ ខ្ញុំរៀបរាប់អំពីប្រភេទមនុស្សបីប្រភេទអម្បាញ់មិញ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំឃើញមីក្រូលោកបើក <>ប៉ុន្តែ ខ្ញុំអត់ឮ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំសូមអភ័យទោសសំណួរខ្ញុំពិបាក។ បាទ លោកបានបញ្ជាក់ថា លោកស្គាល់ប្រភេទមនុស្សទាំងបី<>ប្រភេទ<>នេះ ដែលសុន សេន បានលើកឡើង លោកបាននិយាយអំពីការ<ណែនាំ> លើកលែងទោស ដែលចេញ<>កក្កដា ៧៨។ អ៊ីចឹងខ្ញុំសួរលោកថា តើនេះគឺគ្រាន់តែជាការបញ្ជាក់ អំពី<អត្ថិភាពនៃ>គោលនយោបាយ<> ឬក៏វាជាការ<>ផ្លាស់ប្តូរគោលនយោបាយចំពោះខ្មាំង?

[១០:១២:១២]

**លោក សៅ សារុន៖**

**ឆ៖** បាទ អាហ្នឹងគឺ ខ្ញុំសូមឆ្លើយ អាហ្នឹងជាបញ្ជាក់ ជាគោលនយោបាយរបស់អាៗលើ គេមិនឲ្យចាប់មិនឲ្យចង់ផ្តេសផ្តាសទេ ទាល់តែគេវិនិច្ឆ័យឲ្យច្បាស់លាស់ រាយការណ៍ឲ្យច្បាស់លាស់។ បាទ អាហ្នឹងគឺមិនមែនថា បញ្ជាក់ហ្នឹងទេ គឺគេតាំងពីថារំដោះភ្នំពេញគាត់ចេះបញ្ជារហូតមកដល់ មានការប៉ះពាល់ដល់កម្លាំងប្រជាជន ចាប់ចេះតែចាប់ចេះតែចងហ្នឹង អាហ្នឹងច្បាស់ណាស់ គាត់បញ្ជាក់ច្បាស់រឿងហ្នឹង។ និយាយខ្ញុំ និយាយអ៊ីចឹង មិនមែនថាកាន់ដៃកាន់ជើង ប៉ុល ពត ទេ ពីព្រោះត្រចៀកឮ គាត់បញ្ជាក់ច្បាស់ រឿងចាប់ រឿងចងហ្នឹងគឺហាមដាច់ខាតតែម្តង តែតាមស្រុកតាមខេត្តហ្នឹងគេ មិនដឹងគេធ្វើយ៉ាងម៉េចអាហ្នឹង យើងអត់យល់។

**ប្រធានអង្គជំនុំ៖**

បាទអរគុណៗលោកមេធាវី។ បាទ អរគុណលោកសាក្សី ឥឡូវនេះ ដល់ពេលសម្រាកហើយ ហើយលោកសាក្សី លោកមេធាវីអាចសម្រាកបាន ហើយរហូតដល់ម៉ោងដប់កន្លះ សូមបន្តកិច្ចដំណើរការសវនាការរបស់យើង ហើយសូមមកកាន់កន្លែងផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍នៅទីនោះ។ ហើយឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:១៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សួស្តីលោក សៅ សារុន តើបានត្រៀមខ្លួនរួចហើយឬនៅ?

**លោក សៅ សារុន៖**

បាទ ត្រៀមខ្លួនរួចហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក សៅ សារុន។ ជាបន្តផ្តល់វេទិកាជូនទៅក្រុមមេធាវីសហមេធាវីការពារក្តី នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរសាជាថ្មីលោកសាក្សី ខ្ញុំសូមលើកឡើងនិយាយសាជាថ្មី នូវអ្វីដែលខ្ញុំបាននិយាយជាមួយលោកមុនពេលលោកឈប់សម្រាកនេះ។ លោកនៅចាំទេ ខ្ញុំបានអានសម្រង់មួយផ្សាយតាមវិទ្យុផ្សាយសំឡេងទីក្រុងភ្នំពេញ អំពីការឈ្លានពានពីសំណាក់វៀតណាម ក៏ដូចជាសកម្មភាពចារកម្មរបស់វៀតណាម។ ឥឡូវ ខ្ញុំសុំបន្តសួរចំណុចនេះឲ្យបានជាក់លាក់បន្តិចពាក់ព័ន្ធជាមួយខ្លួនលោកតែម្តង។ នៅចំពោះមុខខ្ញុំនេះ លោកសាក្សីខ្ញុំមានសារទូរលេខពីរច្បាប់ ដែលខ្លួនលោកផ្ទាល់ជាអ្នកសរសេរសារទូរលេខទាំងពីរនេះ។ <>នៅក្នុងឆ្នាំ២០១២ គេបានសួរលោកពីចំណុចពាក់ព័ន្ធនឹងសារទូរលេខនេះ ហើយលោក

ទទួលស្គាល់ថា លោកពិតជាអ្នកសរសេរសារទូរលេខទាំងពីរច្បាប់នេះមែន គឺខ្ញុំយោងទៅលើឯកសារ E3/937 និង E3/1072 ដែលជាសារទូរលេខមានតែមួយទំព័រៗទេ។ លោកសាក្សី ខ្ញុំសុំសួរសារទូរលេខទី១សិន គឺជាសារទូរលេខ "គោរពជូនបងជាទីគោរព" លោកបានសរសេរនៅថ្ងៃទី២៣ មេសា ៧៨។ ម្សិលមិញនេះ ក៏បានយកមកសួរខ្លះៗដែរ ពាក់ព័ន្ធទៅនឹងឈ្មោះ សុទ។ ក៏ប៉ុន្តែថ្ងៃនេះ ខ្ញុំ<ចង់ពិភាក្សាជាមួយលោក ដោយ>យកកថាខណ្ឌមួយនៃឯកសារ E3/937 លោកសរសេរដូចតទៅ ខ្ញុំសូមដកស្រង់សំណេរលោកតែម្តង៖ "១. អំពីសកម្មភាពខ្មាំងខាងក្រៅ ពួកចារកម្មយួន គឺវាចូលមកកន្លែងកងពលនៅក្រុងតេះ តាំងពីថ្ងៃទី២០ ខែមេសា ឆ្នាំ៧៨ វាចូលមកដើម្បីស៊ើបការណ៍ រហូតដល់ថ្ងៃទី២១-២២ <ខែមេសា> រយៈពេល៣ថ្ងៃហើយ តែយើងក៏បានចាត់តាំងកម្លាំងរកវា តែរកមិនឃើញ ឃើញតែដានវាចូលមក។ ហើយតាមការពិនិត្យដានពួកវានេះ គឺវាមិនទាន់បានទៅវិញទេ គឺវាបន្តធ្វើសកម្មភាពស៊ើបការណ៍រកទីតាំងយើង។"

ហើយថ្ងៃបន្ទាប់លោកសរសេរថាទូរលេខមួយច្បាប់ទៀត "ជូនបងជាទីគោរព" ហើយលោកសរសេរថា៖ "១) អំពីសភាពការណ៍ខ្មាំងគឺឯកសារ (E3/1072) នៅម៉ោងមួយអធ្រាត្រថ្ងៃទី២៣ មេសា ៧៨ មានខ្មាំងយួនវាចូលវាយមន្ទីរកងពលនៅក្រុងតេះ ប្រហែលយូរ ប្រាំមួយ ទៅប្រាំពីរនាទី យើងវាយតបយ៉ាងខ្លាំងក្លា។ តាមការពិនិត្យ ពួកវាអាចត្រូវរបួសខ្លះ។" លោកសាក្សី ទី១ តើលោកនៅចាំទេថាលោកបានសរសេរសារទូរលេខពីចំណុចនេះ? គឺការវាយប្រហារពីសំណាក់ពួកវៀតណាមនៅក្រុងតេះ លោកនៅចាំថាលោកបានសរសេរចំណុចនេះនៅក្នុងសារទូរលេខនេះទេ?

**ឆ៖** បាទ គឺថាវ៉ៃមែនកាលនោះ កន្លែងកងពល ឮតាម ឮទេកងពលទេគាត់ប្រាប់ វ៉ៃមែន យើងក៏វ៉ៃតបខ្លាំងក្លាមែន បាទខាងកងពលគេវ៉ៃ។

[១០:៣៦:៥០]

**ស៖** ហើយតើអ្នកណាមកពីកងពលដែលបានរាយការណ៍ជូនលោកនេះ?

**ឆ៖** គឺរាយការណ៍តាមអក្សរគេទៅ។ យើងរាយការណ៍មកប្រធានកងពលគេ ប្រធានកងពលគេមកប្រាប់ខ្ញុំ។

**ស៖** <តើ>មេបញ្ជាការកងពលតំបន់ ឬក៏មេបញ្ជាការកងពល៩២០ ដែលបានរាយការណ៍មកលោកអំពីការវាយប្រហារពីសំណាក់វៀតណាមនេះ?

**ឆ៖** ខាងកងពល៩២០ គេរាយការណ៍មកប្រធានកងពល៩២០ដែរ។ ប្រធានកងពល៩២០ ក៏

មកប្រាប់ឲ្យខ្ញុំដឹង។

**ស៖** តែតាមដែលខ្ញុំយល់ សូមកែតម្រូវខ្ញុំផងបើខ្ញុំយល់ច្រឡំថាកងពល៩២០ ជាកងពលមជ្ឈិម ហើយកងពល៩២០នេះ ត្រូវរាយការណ៍ដោយផ្ទាល់មកអគ្គសេនាធិការ នៅពេលដែលកងពល៩២០ រាយការណ៍មកលោកនេះ តើលោកក៏ត្រូវតែមានភារកិច្ចត្រូវរាយការណ៍មកជូនមជ្ឈិមដូចគ្នានេះដែរទេ?

**ឆ៖** បាទ រាយការណ៍ដូចតែគ្នា។

**ស៖** នៅពេលលោកបញ្ជូនរបាយការណ៍របស់លោកមកមជ្ឈិម តើលោកប្រើប្រាស់ព័ត៌មានដែលកងពល៩២០ រាយការណ៍ជូនលោកដូចម្ដេច? តើលោកចម្រាញ់យកតែព័ត៌មានណាខ្លះដើម្បីរាយការណ៍មកមជ្ឈិមពាក់ព័ន្ធទៅនឹងសារទូរលេខទាំងពីរដែលលោកបញ្ជូនមក ដែលលោករាយការណ៍មកមជ្ឈិមនេះ? ទី១គឺថាកងពល៩២០រាយការណ៍មកលោក ហើយលោករាយការណ៍មកមជ្ឈិម។ អ៊ីចឹងតើលោកជ្រើសរើស ឬក៏សង្ខេបព័ត៌មានបែបណាដើម្បីរាយការណ៍មកមជ្ឈិម?

**ឆ៖** បាទ គឺសង្ខេបតាមគេ យើងរាយការណ៍ទៅវ៉ៃ យួនវ៉ៃពេលណាអីពេលណី គឺគេរាយការណ៍តែប៉ុណ្ណឹង ពីរបីម៉ាត់ហ្នឹង រាយការណ៍ទៅ។

[១០:៤០:០៣]

**ស៖** ហើយបើខ្ញុំយល់មិនច្រឡំទេ កងពល៩២០ បានរាយការណ៍លម្អិតអំពីការវាយប្រហារពីសំណាក់វៀតណាម។ តើត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ដូចដែលខ្ញុំទើបតែបានលើកឡើង<>នៅពេលមុនឈប់សម្រាកនេះ<ថា> ខ្ញុំបានអានសម្រង់មួយដែលផ្សាយចេញពីវិទ្យុផ្សាយសំឡេងទីក្រុងភ្នំពេញ រៀបរាប់អំពីសកម្មភាពទាំងអស់របស់ពួកវៀតណាម ឈ្លានពាន។ របាយការណ៍ ឬក៏ថាការផ្សាយតាមវិទ្យុនេះ គឺផ្សាយនៅដើមខែមីនា ៧៨។ ការវាយប្រហារពីសំណាក់វៀតណាមដែលលោករាយការណ៍ក្នុងសារទូរលេខទាំងពីរនេះ តើវាជាឧទាហរណ៍ពាក់ព័ន្ធទៅនឹងការ<ឈ្លានពានរបស់វៀតណាម> ដែលត្រូវបានផ្សាយតាមវិទ្យុទីក្រុងភ្នំពេញនេះ ឬយ៉ាងណា?

**ឆ៖** បញ្ហានេះ គឺរាយការណ៍តាមជាក់ស្ដែង រឿងវ៉ៃកងទ័ពហ្នឹងហើយ គេត្រូវបញ្ជូនវ៉ៃជាក់ស្ដែងហ្នឹង ហើយបានគេរាយការណ៍ទៅភ្នំពេញ។

**ស៖** ខ្ញុំយល់ហើយលោក ក៏ប៉ុន្តែវិទ្យុផ្សាយសំឡេងទីក្រុងភ្នំពេញ គឺផ្សាយនៅថ្ងៃទី០២ មីនា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

៧៨ ផ្សាយអំពីការលុកលុយឥតឈប់ឈរពីសំណាក់វៀតណាម<នៅតាមព្រំដែន និង>ចូលមកក្នុងបូរណភាពដែនដីកម្ពុជា<ប្រជាធិបតេយ្យ> ក៏ដូចជាការបញ្ជូនចារកម្មចូលមកដែរ។ ហើយលោកបានរៀបរាប់នៅក្នុងសារទូរលេខរបស់លោកទាំងពីរលើកនេះ តើព្រឹត្តិការណ៍នេះ គឺជា<ឧទាហរណ៍>ដែលត្រូវបានយកទៅរៀបរាប់នៅក្នុងការផ្សាយតាមវិទ្យុទីក្រុងភ្នំពេញនេះដែរឬទេ?

[១០:៤២:២៣]

**ឆ៖** ទេ វាយការណ៍ទៅហើយ គឺអារឿងខាងវិទ្យុហ្នឹងគេ មិនចេះរៀបរាប់ទេ រៀបរាប់តែចូលថ្ងៃណា វៃថ្ងៃណា វាចេះតែលុកលុយមកវៃកម្ពុជាជារឿងរហូតនោះ ខាងលើដឹងគេរៀបចំផ្សាយកម្មវិធីយ៉ាងម៉េចៗក៏អត់ដឹងដែរ។ យើងអ្នកខាងក្រោមចេះតែវាយការណ៍ឱ្យដឹង គេវៃថ្ងៃណា ចូលមកថ្ងៃណា អាហ្នឹងវាយការណ៍តែប៉ុណ្ណឹង។

**ស៖** លោកសាក្សី យើងខ្ញុំមិនមានសារទូរលេខទាំងអស់ដែលលោកបានរៀបចំសរសេរឡើងនោះទេ យើងខ្ញុំមានតែពីរបីសារទូរលេខដែលលោកសរសេរដោយផ្ទាល់។ ព្រឹត្តិការណ៍មួយដែលលោកបានរៀបរាប់អំពីការវាយប្រហារពីសំណាក់កងទ័ពវៀតណាមមកលើទីតាំងរបស់កងពល <តើ>នេះគឺជាអ្វីដែលបានកើតឡើងជាញឹកញាប់ កើតឡើងជាប្រចាំថ្ងៃ<ទេ គឺ>ចន្លោះខែមីនា ៧៦ ទៅដល់<ខែមេសា> ៧៨<?> តើកងទ័ពវៀតណាមបានលុកលុយចូលមកក្នុងបូរណភាពដែនដីកម្ពុជា<ប្រជាធិបតេយ្យ>ញឹកញាប់ប៉ុនណាដែរលោក?

[១០:៤៣:៥៥]

**ឆ៖** តាមព្រំដែនញឹកញាប់មែន បានចូលមក វៃនៅទីតាំងរបស់កងពល៩២០ហ្នឹង ពីក្រុងតេះទៅព្រំដែនមិនមែនជិតទេ ប្រហែលជាប់ជិត៤០គីឡូហើយ ក្រុងតេះហ្នឹង។ ចូលវៃ យប់ វៃទប់គ្នាខ្លាំងក្លាដែរ កងពលគេ គេវៃ។ វៃនៅទីតាំងតែម្តង មិនមែនវៃអីទេ វៃចូលវៃទីតាំងតែម្តង ទីតាំងរបស់កងពល ៩២០ បោះប្រចាំការនៅក្រុងតេះ។ ពីក្រុងតេះ ទៅព្រំដែនប្រហែលជិត ៤០គីឡូ។ បាទ សូមអស់។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំយល់ហើយថា លោកមិនអាចអានសារទូរលេខនេះបានដោយសារតែភ្នែកលោកឥឡូវនេះគឺថាចុះខ្សោយច្រើន។ លោកក៏បានបញ្ជាក់ផងដែរថា ខ្លួនលោកផ្ទាល់នេះ មិនបានប្រើពាក្យ “អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន” ទេ ដែល<យើងអាចដឹងតាមរយៈសារទូរលេខទាំងនោះ>។ តាមធម្មតា គឺលោកសំដៅទៅលើថា បងជាទីគោរព ឬបងជាទីស្នេហា។ តើត្រឹមត្រូវទេ<> លោកសរសេរសារទូលេខតោងតែសរសេរថា “គោរពជូនបងជាទីគោរព<>” ដោយមិនប្រើឈ្មោះទេ។ <តើ>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ចុះតើលោកធ្លាប់បានឃើញសារទូរលេខណាមួយ ឬធ្លាប់បានឃើញឯកសារសម័យកាលនោះ ណាមួយដែលគេធ្លាប់ប្រើពាក្យថា “បងទី១, បងទី២” ដែរទេ? ធ្លាប់ដែលឃើញទេ?

**ឆ៖** បាទ ឃើញតើ! ខាងកងពលគេធ្លាប់ហៅ បងទី១, បងទី២។ ទី១ ហ្នឹងគឺ គេសំដៅថា អ៊ំប៉ុល ពត ៗ ហ្នឹង។

**ស៖** នៅពេលដែលលោកឆ្លើយថា ខាងកងពលគេធ្លាប់ប្រើពាក្យនេះ លោកចង់មានន័យដូចម្ដេច?

**ឆ៖** មានន័យអី ពីព្រោះគេធ្លាប់សរសេរអ៊ីចឹង។ គេហៅបងទី១, បងទី២ អ៊ីចឹង។ មិនដឹងមានន័យម៉េចទេ គឺគេធ្លាប់ហៅអ៊ីចឹង។ គេមិនចង់ហៅឈ្មោះទេណា៎។ បងទី១ ហ្នឹងគេដឹងហើយ, បងទី២ គេដឹងហើយ។ ន័យគេអ៊ីចឹង។

**ស៖** តើលោកនេះ និយាយមកកាន់ ប៉ុល ពត ឬ នួន ជា ឬ វន វ៉េត ឬ អៀង សារី ឬ សុន សេន តើលោកសរសេរមកកាន់ពួកគាត់ទាំងនេះថា “<អ៊ំ> អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន” ឬក៏លោកនិយាយមកកាន់គាត់ដោយប្រើជាលេខ?

[១០:៤៨:១១]

**ឆ៖** បាទ គឺសរសេរអី ខ្ញុំមិនដែល “អ៊ំវន, អ៊ំវន វ៉េត” អីខ្ញុំអត់យល់ទេ។ ច្រើនសរសេរតែឈ្មោះតែជូនតែប្រធានតែម្នាក់លោក ប៉ុល ពត ទេ និង នួន ជា តែប៉ុណ្ណឹង។ សុន សេន បីនាក់ ពីព្រោះគេបីនាក់នេះ គេចុះជាប់តាមមូលដ្ឋាន ក្រៅពីហ្នឹងមិនសូវដាក់ឈ្មោះគេទេ ហើយអត់យល់ផង ដូច វន វ៉េត អីអត់ស្គាល់មុខគេផង។

**ស៖** យើងទាំងអស់គ្នាដឹងហើយថា បង៨៩ ហ្នឹង គឺ សុន សេន ហើយ។ ចុះលោកស្គាល់បង៨១ បង៨៧ ដែរទេ?

**ឆ៖** អត់ស្គាល់ទេ។

**ស៖** ចង្កោមសំណួរខ្ញុំចុងក្រោយសួរទៅកាន់លោក គឺពាក់ព័ន្ធទៅនឹងអង្គប្រជុំមួយ ដែលលោកបានចូលរួមនៅក្នុងឆ្នាំ១៩៧៥ គឺមួយអាទិត្យ ឬពីរអាទិត្យ ឬបីអាទិត្យក្រោយរំដោះទីក្រុងភ្នំពេញ។ លោកត្រូវបានសួរសំណួរពាក់ព័ន្ធចំណុចនេះច្រើនណាស់មកហើយ <ដូច្នេះ> ខ្ញុំមិនសួរសំណួរនេះឡើងវិញទេ ដោយសារលោកបានផ្ដល់សក្ខីកម្មច្បាស់លាស់ហើយ។ ប៉ុន្តែមានចំណុចមួយដែលខ្ញុំចង់ជជីកសួរ

ឲ្យបានស៊ីជម្រៅបន្តិច។ លោកបានឆ្លើយថា នៅក្នុងអង្គប្រជុំឆ្នាំ៧៥ អាចថា ប៉ុល ពត ឬ នួន ជា ដែលបានថ្លែងនៅត្រង់ចំណុចមួយនិយាយអំពីលុយកាក់ថា លុយកាក់នឹងត្រូវប្រើប្រាស់ឡើងវិញ ហើយប្រជាជនដែលជម្លៀសហ្នឹងគឺថា នឹងត្រូវត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញ។ តើលោកនៅនឹកឃើញថា ពួកគាត់ណាម្នាក់និយាយពីចំណុចនេះទេ?

**ឆ៖** បាទ ដូចខ្ញុំបានរាយការណ៍អ៊ីចឹង ដូចច្បាស់អ៊ីចឹង។

[១០:៥០:៥៦]

**ស៖** តើ នួន ជា ឬក៏ ប៉ុល ពត មានបាននិយាយលម្អិតទេថា លុយកាក់នេះនឹងត្រូវយកមកឲ្យចាយវាយឡើងវិញ<>នៅពេលណាដែរទេ?

**ឆ៖** បាទ ពេលប្រជុំហ្នឹងនៅភ្នំពេញ ប៉ុន្តែថ្ងៃខែខ្ញុំភ្លេចអស់ហើយ គាត់ប្រកាសមែន "លុយត្រូវតែចាយវាយ"។

**ស៖** តើពួកគាត់ណាម្នាក់មានបាននិយាយថា<នៅពេលណា ពួកគេ>នឹង<>ឲ្យចាយ<លុយ>ឡើងវិញ<>ទេ?

**ឆ៖** គេថាចាយលុយវិញ អាលុយកាក់ហ្នឹង គឺក្នុងដើមឆ្នាំ៨០ គឺឲ្យចាយលុយវិញ។

**ស៖** ឥឡូវនេះ <និយាយពីការវិលត្រឡប់របស់ប្រជាជនវិញម្តង។ ដើម្បីឲ្យ>ច្បាស់លាស់លោកប្រធាន គឺខ្ញុំយោងទៅលើគឺប្រតិចារឹក<សវនាការលើកទី៧០> ថ្ងៃទី០៦ មិថុនា ឆ្នាំ២០១២ នៅម៉ោង ១៣:៤២ ដែលសាក្សីបានឆ្លើយ ហើយនិយាយអំពីកិច្ចប្រជុំហ្នឹង។ <គាត់និយាយថា> "ក្រោយមកគេប្រកាសថាប្រជាជននឹងត្រូវបានអនុញ្ញាតឲ្យត្រឡប់មកទីក្រុងភ្នំពេញវិញ ហើយលុយកាក់នឹងឲ្យចាយវាយឡើងវិញ"។ លោកសាក្សី ទោះជា ប៉ុល ពត ក្តី, នួន ជា ក្តី <ជាអ្នក>និយាយ ថាតើ<>នៅពេលណា<ដែល>គេ<គិតថា>ឲ្យប្រជាជនត្រឡប់ចូលមកទីក្រុងភ្នំពេញវិញ? <តើវានៅ>ឆ្នាំ៨០ <នោះដែរ> ឬក៏<ច្រើនឆ្នាំមុននោះ>? តើ<លោកដឹងទេ? តើពួក>គាត់មាននិយាយ<អ៊ីចឹងទេ ឬក៏ពួកគាត់មិនបានយោងទៅលើអ្វី>ទេ?

**ឆ៖** បាទ គាត់ប្រកាសហ្នឹងគឺ គាត់ថាយ៉ាងម៉េចដើម៨០នេះ គាត់ឲ្យប្រជាជនចូលវិញជាបន្តបន្ទាប់តាមទីក្រុង លុយក៏ឲ្យចាយ ឲ្យបោះពុម្ពលុយចាយវាយទៅវិញ។

**ស៖** ចុះនិយាយអំពីទីផ្សារវិញលោក និយាយអំពីផ្សារផ្សេវិញ គាត់មាននិយាយដែរឬអត់ទេ?

**ឆ៖** បាទ និយាយថា គាត់បើកជាបន្តបន្ទាប់ហើយតើផ្សារ តាំងពី៧៩ ហ្នឹងមានលក់បន្លែអីនៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ផ្សារថ្មី នៅភ្នំពេញ ឃើញព្រោងព្រាតហ្នឹងអីដែរ។ ប៉ុន្តែវាមិនមានទ្រង់ទ្រាយធំដូចយើងសព្វថ្ងៃ ប៉ុន្តែជាទិសដៅគាត់ថា ផ្សារត្រូវបើកឡើងវិញទាំងអស់។ ៧៩ ហ្នឹងឃើញថា តាំងលក់នៅផ្សារថ្មីនៅភ្នំពេញជាបន្តបន្ទាប់ ដូចជាបន្លែបង្ការអី។

[១០:៥៤:០៨]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំពាក់ព័ន្ធទៅនឹងអង្គប្រជុំមួយនេះលោកសាក្សី ចំណុចនេះហាក់បីដូចជាច្របូកច្របល់តិចអំពី<>ទីតាំងនៃកិច្ចប្រជុំនេះ។ អ្នកខ្លះនិយាយថាគេប្រជុំនៅជិតស្តាតអូឡាំពិក អ្នកខ្លះទៀតនិយាយថា អង្គប្រជុំនេះប្រជុំនៅបុរីកីឡា។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះឱ្យបាន<ទេ អំពីទីតាំង>ច្បាស់លាស់<នៃកន្លែង>ប្រជុំ<>ដែល<រៀបចំឡើងពីរបីសប្តាហ៍> ក្រោយ<ពីរំដោះភ្នំពេញនៅ>ថ្ងៃ ១៧ មេសា ៧៥? តើគេប្រជុំនៅកន្លែងណាលោក?

**ឆ៖** មុនរំដោះ ១៧ មេសា ហ្នឹងគឺរំដោះរួចហើយ គេហៅពួកខ្ញុំទៅប្រជុំនៅអី សាលាសហភាពសូវៀត -- ខ្មែរសូវៀតហ្នឹង។ ទៅប្រជុំបីថ្ងៃហ្នឹង ដូចខ្ញុំបញ្ជាក់ថ្ងៃមុនហ្នឹង។

**ស៖** <>អ្វីដែលលោកបានឆ្លើយ<នោះគឺសំខាន់ណាស់>។ <>តើមានកិច្ចប្រជុំណាមួយនៅស្តាតអូឡាំពិកដែរទេបន្ទាប់ពីរំដោះភ្លាមហ្នឹង <ឬក៏មិនមានទេ>?

**ឆ៖** ក្រោយមកមានៗម្តងទៅប្រជុំរៀនសូត្រនៅអូឡាំពិកហ្នឹង គេឱ្យភ្លាមបានមួយឆ្នាំ គេហៅគ្រប់ស្រុកទូទាំងប្រទេសហ្នឹង គេឱ្យទៅប្រជុំរៀនសូត្រ។

**ស៖** ដូច្នេះក្រោយថ្ងៃរំដោះមានការប្រជុំពីរបីលើក កិច្ចប្រជុំមួយលើកគឺប្រជុំនៅសាលាមិត្តភាពកម្ពុជា-សូវៀត ហើយមួយលើកទៀតប្រជុំនៅស្តាតអូឡាំពិក។ ត្រឹមត្រូវដែរទេលោក?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** សំណួរចុងក្រោយបំផុត លោកដឹងថាប្រធានរដ្ឋសភាបច្ចុប្បន្ននេះ ឈ្មោះ ហេង សំរិន នេះលោកស្គាល់ទេ?

**ឆ៖** អត់ៗស្គាល់ទេ។

[១០:៥៧:០៨]

**ស៖** ខ្ញុំ<រៀបសំណួរឡើងវិញ។ តើ>លោកមិនស្គាល់គាត់នៅពេលនេះ ឬក៏លោកមិនស្គាល់<គាត់> តាំងពីពេលនោះ<>?

**ឆ៖** អត់ស្គាល់ទេ ពីព្រោះអត់ដឹងពីណាទៅណាទេ ឃើញតែទៅប្រជុំព្រាត មិនដឹងពីណា

01239172



ឈ្មោះអីៗទេ។

**ស៖** ក្នុងពេលប្រជុំទាំងប៉ុន្មានលើកនេះ តើលោកធ្លាប់ឮថ្នាក់ដឹកនាំនិយាយទៅកាន់កម្មាភិបាល ដោយនិយាយអំពីអតីតទាហានលន់ នល់ ហើយថាអតីតទាហានលន់ នល់នេះ គួរតែបំបែកចេញពីគ្នា <ទេ? ពាក្យ>ថាកម្ចាត់ <អាចត្រូវបានប្រើពាក់ព័ន្ធទៅនឹងអតីត>ទាហានរបបលន់ នល់។ <តើលោកមានចាំពីចំណុចនេះ>ទេ?

**ឆ៖** បាទគឺខ្ញុំអត់ថាឮទេ ឮតែថាឲ្យរៀបចំ ឲ្យគេធ្វើស្រែ ធ្វើចម្ការ គ្រប់គ្រងឲ្យបានល្អ អាហ្នឹងខ្ញុំឮ ថាកម្ចាត់អីៗ ខ្ញុំអត់ដែលឮទេ។

**ស៖** តើមានការពិភាក្សាណាមួយ ថាគួរត្រូវធ្វើដូចម្ដេចជាមួយនឹងទាហានលន់ នល់ <និងសមាជិកពួកគេនោះ? តើមានការពភាក្សាណាមួយទេ>ទាំងកិច្ចប្រជុំនៅសាលាមិត្តភាពខ្មែរ-សូវៀត ក៏ដូចជាកិច្ចប្រជុំនៅស្ដាតអូឡាំពិក? <តើលោកនឹកឃើញ>ទេ?

**ឆ៖** អត់ឮគេនិយាយអីទេ ឮតែថា គេថាឲ្យធ្វើស្រែ ធ្វើចម្ការ គ្រប់គ្រងគេឲ្យល្អ ឮតែប៉ុណ្ណឹង ក្រៅពីហ្នឹងអត់ឮទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកសាក្សីអរគុណច្រើន។ អរគុណលោកប្រធាន។

[១០:៥៩:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះ ផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមនិងភាគីទាំងអស់។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក សៅ សារុន! ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិមេធាវីការពារក្ដីលោក ខៀវ សំផន ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរទៅកាន់លោក។ អង្គជំនុំជម្រះបានជម្រាបលោកមកហើយថា លោកត្រូវបានស្ដាប់ចម្លើយរួចមកហើយ នៅក្នុងសំណុំរឿង០០២/០១

ហើយអង្គជំនុំជម្រះ<ហៅ>លោក<មកវិញលើកនេះពាក់ព័ន្ធទៅនឹង>មន្ទីរសន្តិសុខភ្នំក្រោល។ ដូច្នេះ ខ្ញុំផ្តោតសំណួរខ្ញុំតែលើមន្ទីរសន្តិសុខ<>ប៉ុណ្ណោះ។ តាមរយៈសក្ខីកម្មរបស់លោក ខ្ញុំយល់ថា លោកធ្លាប់ជាលេខាស្រុក ហើយក្រោយមក<ប៉ុន្មានខែ>មុនពេលវៀតណាមវៃចូល លោកក៏ក្លាយទៅជាលេខាតំបន់១០៥។ ដូច្នេះ ខ្ញុំចង់ដឹងថាក្នុងពេលលោកបំពេញមុខងារ តើលោក<ដឹងថាមាន>មន្ទីរសន្តិសុខមួយដែលមានឈ្មោះថា "មន្ទីរភ្នំក្រោល <>ទេ?

**ឆ៖** បាទ អាហ្នឹង ខ្ញុំស្គាល់ ឮ គេចូលចិត្តនិយាយ មានសន្តិសុខនៅភ្នំក្រោល។

**ស៖** លោកដឹងថាមន្ទីរភ្នំក្រោលហ្នឹងស្ថិតនៅកន្លែងណាទេ ហើយអ្នកណាជាប្រធានមន្ទីរសន្តិ-សុខភ្នំក្រោល?

**ឆ៖** ខ្ញុំមិនដឹងពីណាទេ។ ខ្ញុំអត់ -- មិនច្បាស់ទេ ក្តាប់មិនបានទេ រឿងការងារនៅស្រុក មានការងារគេនៅតំបន់នេះ វាប្រាប់អត់បានទេ ដឹងពីណាៗមុនដំបូង ខ្ញុំអត់ដឹង។

[១១:០២:១៥]

**ស៖** លោកបានលើកឡើងអំពីឈ្មោះជាច្រើន ហើយសាក្សីផ្សេងៗ ក៏បាននិយាយអំពីឈ្មោះទាំងអស់ហ្នឹងដែរ។ ដូច្នេះ ខ្ញុំចង់ដឹងថាតើអ្នកទាំងអស់ហ្នឹងមានមុខងារអ្វីខ្លះ? លោកបាននិយាយអំពីឈ្មោះ សុភា តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាតើ សុភា នេះមានមុខងារអ្វីដែរនៅក្នុងតំបន់១០៥?

**ឆ៖** បាទ សុភា ហ្នឹងគាត់ជាសមាជិករបស់គណៈតំបន់ ប៉ុន្តែគាត់ទទួលខាងសន្តិសុខ។

**ស៖** នៅពេលដែលលោកនិយាយថាគាត់ទទួលខាងសន្តិសុខហ្នឹង តើមុខងារគាត់ឲ្យប្រាកដហ្នឹងជាអ្វីដែរ?

**ឆ៖** ខាងទាហាន។ រឿងហ្នឹងគេដកគាត់ពីខាងទាហានមក ចូលសមាជិកតំបន់។

**ស៖** លោកបាននិយាយអំពីវត្តមានរបស់ តាសាន ហើយនិង<>តួនាទីរបស់ តាសាន នៅក្នុងកងពល៩២០។ ដូច្នេះ តើលោកដឹងទេថា កងពល៩២០នេះធ្វើការរួមគ្នាជាមួយ សុភា ឬក៏ម្នាក់ៗ ធ្វើការដាច់ដោយឡែកពីគ្នាមិនមានការជាប់ពាក់ព័ន្ធគ្នាទេ?

**ឆ៖** បាទ ធ្វើរួមគ្នា បញ្ហាការពារហ្នឹងឯង ខាងកងទ័ពនិងកងទ័ពរួមគ្នា សហការគ្នា មានបញ្ហាអ្វីប្រាប់គ្នា រាយការណ៍គ្នាឲ្យដឹងបាទ។

**ស៖** សាក្សីមួយរូបដែលមានឈ្មោះថា ប៊ុន ឡឹងចូយ ដែលទើបតែផ្តល់សក្ខីកម្មមុនលោកបន្តិច

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

នេះ គាត់បាននិយាយអំពីឈ្មោះ ម៉ុង ដែលជាប្អូនរបស់លោក។ ខ្ញុំសូមបញ្ជាក់ថានៅសវនាការគាត់បានឆ្លើយថាគាត់ប្រហែលជាដឹងតាមរយៈពាក្យចចាមអារ៉ាម គាត់ដឹងថា ម៉ុង ហ្នឹងពាក់ព័ន្ធនឹងការចាប់ខ្លួនមនុស្ស។ អ៊ីចឹងតើលោកដឹងទេថាប្អូនរបស់លោកឈ្មោះ ម៉ុង ហ្នឹងគាត់តួនាទីគាត់គឺជាអ្នកចាប់មនុស្ស?

[១១:០៥:២៧]

**ឆ៖** តាមខ្ញុំដឹងនេះ តួនាទីរបស់គាត់គឺការពារព្រំដែនទេ។ រងវរៈទី១ហ្នឹង ដល់អ៊ីចឹងទៅ ឆ្នាំណាទេ ខ្ញុំភ្លេចទៅ ៧៨ហ្នឹង គេហៅគាត់មកការពារខាងក្រោយ។ ហើយនិងចាប់ចងមនុស្សអីហ្នឹង ខ្ញុំអត់ឃើញ ខ្ញុំនៅឯស្រុកហ្នឹង ដូចអត់ឃើញ អត់ឮ។ ប្អូនមែន តែអត់ដូចឃើញឮថាចាប់មនុស្ស ចងមនុស្សអីហើយ។ ម៉ុង ហ្នឹងទៅរកដើរតួនាទីចាប់ចង ខ្ញុំអត់ឮ ខ្ញុំនៅឯស្រុកពេជ្រាដានោះ គេនៅខាងការពារ គេហៅមកការពារខាងក្រោយ។ អានេះ ខ្ញុំមិនមែនថាកាន់ដៃកាន់ជើងទេ វាអត់ឮថាអត់ឮ អត់ឃើញថាអត់ឃើញទៅ។ ប្អូនមែន ប៉ុន្តែវាភារកិច្ចវាខុសៗគ្នា។

**ស៖** លោកថា គាត់ជាអនុប្រធានកងវរសេនាធំ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើអ្នកណាជាប្រធានកងវរសេនាធំ? <តើលោកដឹងទេ?>

**ឆ៖** អត់មានវរសេនាធំទេ វរសេនាតូច។ នៅមណ្ឌលគិរីមានតែពីរវរសេនាតូចទេ អត់មានវរសេនាធំទេ។ ប្រធានវរសេនាតូចនេះ ម៉ុង ហ្នឹងគេប្រធាន គាត់ស្លាប់ហើយ។

**ស៖** ចុះប្រធានវរសេនាតូចរបស់ ម៉ុង ហ្នឹង ឈ្មោះអីដែរ លោកនៅចាំទេ?

**ឆ៖** រៀងៗ គាត់ស្លាប់ហើយ។

**ស៖** មុននេះ លោកបាននិយាយអំពីឈ្មោះ សុភា តើលោកដឹងទេ មន្ទីរសុភា ហ្នឹងនៅកន្លែងណាហើយមន្ទីររបស់គាត់ឈ្មោះអ្វីដែរ?

**ឆ៖** នៅៗតំបន់នៅភ្នំក្រោលហ្នឹង។

**ស៖** លោកធ្លាប់ឮឈ្មោះមន្ទីរ ក-១១ ទេ?

**ឆ៖** បាទឮ ក-១១ វានៅខាងៗកើតអូរច្បារ នៅមាត់អូរច្បារ។

**ស៖** លោកដឹងទេមន្ទីរ ក-១១ ហ្នឹងជាមន្ទីររបស់ តាសុភា មែនទេ?

**ឆ៖** បាទ។ មានតែ១១ ខ្ញុំភ័ន្តច្រឡំ មិនមែននៅមាត់អូរច្បារទេ នៅភ្នំក្រោល មន្ទីរសុភា នោះ។

**ស៖** មិនបញ្ហាអ្វីទេ ព្រោះថារឿងហេតុនេះវាយូរណាស់មកហើយ។ លោកបាននិយាយអំពីមន្ទីរ ក-១៧ ផងដែរ។ ដូច្នេះ តើ ក-១៧ នេះ គឺលោកទៅម្តងម្កាលដែរមែនទេពេលដែលលោកកាន់មុខ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តំណែងជាលេខាតំបន់១០៥ នោះ?

**ឆ៖** សំណួរនេះដូចអត់ច្បាស់ សូមម្តងទៀត។

[១១:០៩:៤៥]

**ស៖** ខ្ញុំនឹងសួរឱ្យលោកស្រួលយល់។ លោកស្គាល់មន្ទីរ ក-១៧ ដូច្នេះខ្ញុំចង់សួរលោកអ៊ីចេះ ថា តើលោកដឹងទេមន្ទីរ ក-១៧ ហ្នឹងជាមន្ទីរអ្វីដែរ? <ហើយជាមន្ទីររបស់អ្នកណា?>

**ឆ៖** បាទ អារឿង ក-១៧ ហ្នឹង គេហៅមន្ទីររបស់តំបន់។

**ស៖** នៅពេលឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាកាលពីម្សិលមិញលោក<បាន និយាយអំពីឈ្មោះ ឡាំង។> បើសិនជាខ្ញុំច្រឡំ សូមលោកកែខ្ញុំ។ <តើ>នៅពេល ឡាំង នៅជាលេខា តំបន់<នៅឡើយ> លោកទៅមន្ទីរ <> នេះ ហើយលោកឃើញមនុស្សពីរបីនាក់ត្រូវបានគេឃុំខ្លួន <នោះឬ?> តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ តាមចម្លើយលោកនោះ បើខុសសូមលោកជួយកែតម្រូវផង។

**ឆ៖** បាទ អ៊ីចឹងបាទ អានេះតាមខ្ញុំឃើញមិនមែនថានិយាយអ៊ីចេះ ខ្ញុំចេះភូតចេះភរ។ តាមខ្ញុំ ឃើញ ខ្ញុំគេហៅទៅធ្វើការម្តងៗ ថាយកមនុស្សមកឃុំឃាំងនៅមន្ទីរ ក-១៧ នេះ អត់ឃើញទេ តាម ធ្លាប់មកធ្វើការអីនោះ។

**ស៖** ខ្ញុំមិនដឹងថាខ្ញុំ<ជាអ្នកដែលមិន>យល់<អ្វីដែលលោកនិយាយនោះ>ឬក៏យ៉ាងម៉េច<ទេ>។ ក៏ប៉ុន្តែម្សិលមិញនេះ លោកថា លោកឃើញមនុស្សពីរបីនាក់ត្រូវបានគេឃុំខ្លួននៅ<កន្លែងណាមួយ>។ លោក សូមបញ្ជាក់<>មើល <តើ>លោកឃើញ<នៅកន្លែងណា>?

**ឆ៖** ខ្ញុំបានបញ្ជាក់ ដូចខ្ញុំបញ្ជាក់ម្សិលមិញនោះឯង ដូចនៅកន្លែងមន្ទីរសន្តិសុខនេះ ខ្ញុំនិយាយថា ឃើញអ្នកទោសដែលជាប់នៅមន្ទីរសន្តិសុខពីរបីនាក់ ប៉ុន្តែនៅមន្ទីរក-១៧ អត់ឃើញគេមកឃុំឃាំងនៅ ហ្នឹងទេ។ អាហ្នឹងខ្ញុំបានបញ្ជាក់អ៊ីចឹងកាលពីម្សិលមិញ។

**ស៖** សូមអភ័យទោស ខ្ញុំយល់ច្រឡំអ៊ីចឹង។ អ៊ីចឹងលោកអាចបញ្ជាក់បានទេ មន្ទីរសន្តិសុខដែល លោកឃើញគេឃុំខ្លួនមនុស្សពីរបីនាក់នោះ មន្ទីរសន្តិសុខណា? ហើយមានទីតាំងនៅកន្លែងណា?

**ឆ៖** នៅជិតក-១៧ ហ្នឹងដែរ ចម្ងាយប្រហែលជាជិត២០០ម៉ែត្រ។

[១១:១២:៣៧]

**ស៖** សូមលោករៀបរាប់អំពីអ្វីដែលលោកបានឃើញនៅមន្ទីរសន្តិសុខនោះ។

**ឆ៖** បាទ ខ្ញុំទៅឃើញគេឃុំឃាំង មិនឃើញគេធ្វើអីទេ ឃើញគេឃុំឃាំងពីរបីនាក់ហ្នឹង យូរៗ

ទៅគេអប់រំដោះលែងទៅ អ្នកណាគេអត់ទោសមានពៃរ៍គេក៏លែងទៅអ៊ីចឹង មិនឃើញគេធ្វើអីដែរ នៅធម្មតា ធ្វើការធម្មតាអី។

**ស៖** លោកអាចជម្រាបបានទេ ថាពេលដែលលោកឃើញហ្នឹង គឺនៅឆ្នាំណាដែរ?

**ឆ៖** ៧៧, ៧៨ ហ្នឹង ខ្ញុំឃើញ។ ខ្ញុំទៅលេងទេ ទៅលេងទៅ មានឃើញទៅ ក៏ឃើញគេអ្នកទោសហ្នឹងពីរបីនាក់ បួនប្រាំនាក់អី ឃើញគេធ្វើការធម្មតា អីដូចយើងដូចគេដែរ គេបោះកន្លែងគេ មានសន្តិសុខគេ ឃើញតែប៉ុណ្ណឹង។

**ស៖** តើលោកដឹងទេ អ្នកណាជាអ្នកក្តាប់មន្ទីរសន្តិសុខនោះ?

**ឆ៖** កាលមុននោះ គឺ តាឡេង ក្តាប់*(ឮមិនច្បាស់)*។

**ស៖** ហើយលោកដឹងទេ ថាក្រោយមកទៀត ហ្នឹងអ្នកណាជំនួសគាត់?

**ឆ៖** ក្រោយមកមិនដឹងពីណាទេ ខ្ញុំដូចភ្លេចភ្លាំងត្រង់ហ្នឹង វាយូរហើយភ្លេចភ្លាំង។ ដល់ខ្ញុំវាទៅឈឺទៅ ភ្លេចការចងចាំអីអស់មិនដឹងពីណាៗ។

**ស៖** តាឡាំង ហ្នឹងគាត់ជាយោធាមែនទេ?

**ឆ៖** អត់ទេ គាត់គឺជាប្រធានតំបន់ ប៉ុន្តែគាត់ទទួលខុសត្រូវខាងយោធារួម។ ពីព្រោះសម័យហ្នឹង គេច្រើនតែខាងតំបន់ទទួលខុសត្រូវខាងកងទ័ពតែម្តង។ ដូច សុភា អីវាក្រោមការគ្រប់គ្រងរបស់គាត់ដែរ។

**ស៖** សូមអរគុណ។ អ៊ីចឹងតើលោកដឹងទេ ថាតើអ្នកកាន់ ឬក៏ក្តាប់មន្ទីរសន្តិសុខដែលលោកបានឃើញហ្នឹង គឺសុទ្ធតែពួកយោធាមែនទេ?

**ឆ៖** បាទ។

**ស៖** យោធាន៎ុងមកពីណា មកពីយោធាតំបន់ ឬក៏យោធាមកពីខាងណា?

**ឆ៖** បាទ ដូចជាយោធានៅក្នុងតំបន់ ពីព្រោះជំនាន់ន៎ុងគេអត់បានចាត់តាំងប៉ូលិស យកយោធាហ្នឹង។

[១១:១៦:២៥]

**ស៖** ពាក់ព័ន្ធនឹងសាក្សីដែលខ្ញុំបាននិយាយមុននេះបន្តិចនេះ គឺប៊ុន ឡឹងចូយ គាត់បាននិយាយអំពីការចាប់ខ្លួនមនុស្សជាច្រើនទាំងខ្មែរៗ នៅមណ្ឌលគិរី?

**ឆ៖** គាត់ដូចជាអត់នៅមណ្ឌលគិរីទេ តែឮឈ្មោះ ប៊ុន ឡឹងចូយ នេះ។

01239177



**សៈ** ខ្ញុំមិនដឹងថាតើខ្ញុំអានឈ្មោះហ្នឹងត្រូវ ឬក៏អត់? លោកមេធាវី គង់ សំអុន គាត់ខ្ញុំនិយាយឈ្មោះហ្នឹងត្រូវហើយ។ ប្រហែលជាលោកមិនដែល<>ឮឈ្មោះគាត់ ប៉ុន្តែគាត់ជាសាក្សីមួយរូបដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ គាត់បាននិយាយថាគាត់ស្គាល់លោក ហើយគាត់បាននិយាយអំពីការចាប់ខ្លួនមនុស្ស<មួយចំនួន>។ គាត់បានពន្យល់ថា មានបញ្ហាសងសឹកគ្នាទៅវិញទៅមក គឺថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ ក្រោយម៉ោង១០:០៣:៤៩ គាត់ថា៖ "ខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា មានការសងសឹកគ្នារវាងមនុស្សទាំងពីរក្រុមនេះ។ មានការសងសឹកគ្នាមែន ខ្មែរខាំ ភូន វៃខាង ឡាំង ពីព្រោះថា ខាង ឡាំង ហ្នឹងសម្លាប់កូនរបស់គាត់ឈ្មោះ ខាំ។ គេចាប់ ខាំ ភូន បាន ហើយ ញុន ជាប្រធានមន្ទីររបស់គាត់។ ញុន ត្រូវបាននាំចូលបក្សដោយ កាស៊ី។" ដូច្នេះ ខ្ញុំចង់ដឹងថា តើ<>លោក<ដឹង>អំពីបញ្ហានៃការសងសឹកគ្នារវាងខ្មែរខាង ខាំ ភូន និង ខ្មែរ តាឡាំង គឺពីរក្រុមហ្នឹង គឺវៃគ្នា សងសឹកគ្នាទៅវិញទៅមក?

**ឆៈ** បាទ ខ្ញុំសូមឆ្លើយ។ រឿងបញ្ហានេះខ្ញុំអត់យល់ទេ គេសងសឹកគ្នាយ៉ាងម៉េច អាហ្នឹងអត់យល់ទេ ឮតែគេកាប់គ្នាអី ឈ្លោះគ្នាអីស្អុកស្អាញ ពីព្រោះខ្ញុំនៅអីស្រុកពេជ្រាដាហ្នឹង ខ្ញុំមិនមានការពាក់ព័ន្ធរឿងពួកគាត់សងសឹកគ្នាអ៊ីចេះ។ ឮតែថា គេ -- មុនដំបូង ខាំ ភូន -- អ៎! ឡាំង ចាប់កូន ខាំ ភូន ក្រោយមកដឹងអាម៉េចអីម៉េចរឿងគេ ខ្ញុំអត់យល់ទេ រឿងគេ ខ្ញុំអត់មានការពាក់ព័ន្ធទេ។ ខ្ញុំនៅឯស្រុកហ្នឹង ខ្ញុំធ្វើតែការងារខ្ញុំតែមួយមុខនៅស្រុកហ្នឹង។

[១១:១៩:៣៦]

**សៈ** ជាថ្មីម្តងទៀត ដើម្បីឲ្យលោកអាចឆ្លើយតបបាន ពីព្រោះថាសាក្សីនុ៎ង គាត់បាននិយាយអំពីឈ្មោះលោក គឺនៅម៉ោង១០:០៨:២០ គឺនៅសវនាការថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦នុ៎ង ម្សិលមិញហ្នឹង។ <នេះជាអ្វីដែល>ប៊ុន ឡឹងចូយ <បាននិយាយ>។ ខ្ញុំសូមបញ្ជាក់ថា <បន្តិច>ក្រោយមកទៀត <គាត់បានពន្យល់ថា> គាត់<>ឮ<បញ្ហាទាំងអស់នោះ>តាមពាក្យចចាមអារ៉ាម។ <នេះជាអ្វីដែលខ្ញុំចង់សួរលោក។> ខ្ញុំសូមដកស្រង់នូវសម្តីរបស់គាត់៖ "ការចាប់ខ្លួនកើតឡើងក្រោយពី ហាម និង ខាំភូន ឈ្លោះគ្នា <ធ្វើឲ្យ>មានការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់។" គាត់និយាយអំពីលោកថា៖ "សារុន <(គឺលោកផ្ទាល់)> និង សុភា ហ្នឹងជាអ្នកទទួលខុសត្រូវ ក៏ប៉ុន្តែ សុភា មិនទាន់ត្រូវបានគេចាប់ខ្លួននៅឡើយទេនៅពេលនោះ។ ខ្ញុំមិនដឹងថាអ្នកណាជាអ្នកសម្រេចបែបហ្នឹងទេ មិនដឹងថាតើ តាសារុន ឬក៏អ្នកណាផ្សេងដែលសម្រេចទេ។ ខ្ញុំមិនអាចជម្រាបបានទេ ប៉ុន្តែបើតាមអ្វីដែលខ្ញុំស្តាប់ឮ គឺមានការប្រជុំគណៈ<>។

ហើយខ្ញុំដឹងថាការសម្រេចគឺ<មិនមែន>តែម្នាក់ទេ<> គឺសម្រេចរួមនៅក្នុងគណៈ<>។ ក៏ប៉ុន្តែអ្នកដែលទទួលខុសត្រូវក្នុងការសម្រេចហ្នឹងគឺជាអ្នកដែលខ្ពស់ជាងគេហើយ គឺកម្មាភិបាលជាន់ខ្ពស់ហើយ។" សូមបញ្ចប់ការដកស្រង់។ ខ្ញុំសូមបញ្ជាក់ថា នៅម៉ោង១០:១០:៤២វិនាទី សាក្សីគាត់បានបញ្ជាក់បន្ថែមទៀតថា គាត់ឮតាមពាក្យចចាមអារ៉ាម<និងការនិយាយតៗគ្នា>។ អ៊ីចឹងហើយខ្ញុំយកចម្លើយគាត់ហ្នឹងមកអានឲ្យលោកស្តាប់ហ្នឹង ដើម្បីឲ្យលោកមានប្រតិកម្មតបទៅនឹងចម្លើយរបស់ ប៊ុន ឡឹងចូយ នេះ។

**ឆ៖** បាទ ប៊ុន ហៅ ប៊ុន ឈ្មោះចូយ នេះអត់ស្គាល់ នៅមណ្ឌលគិរី ប៉ុន្តែដល់រឿងចាប់រឿងចងហ្នឹង ខ្ញុំអត់មានថាអ៊ីចេះអ៊ីចុះទេ។ ខ្ញុំនិយាយដោយស្មោះត្រង់ចំពោះលោកតុលាការ។ រឿងចាប់រឿងចងហ្នឹង ខ្ញុំអត់យល់ទេ ពីព្រោះខ្ញុំនៅស្រុកហ្នឹង គេប្រជុំហ្នឹងមានដំបូងគេ តាលប អ៊ីៗ បងប្អូនគេ ៗប្រជុំមានកងពល៩២០ មាន សុភា។ កាលហ្នឹង ខ្ញុំនៅឯស្រុក ខ្ញុំអត់ដឹងគេប្រជុំណាចាប់យ៉ាងម៉េច ណាចងយ៉ាងម៉េចអី អត់ដឹងទេ។ មិនមែនថា ខ្ញុំនិយាយនេះ គឺនិយាយពន្លើសភូតភរអីទេ។ និយាយសុទ្ធស្មោះត្រង់ថ្ងៃនេះ ឲ្យច្បាស់ហ្មង ខ្ញុំអត់យល់រឿងអ៊ីចឹងៗ។

**ប្រធានអង្គជំនុំ៖**

លោក សៅ សារុន ឈ្មោះ ចាន់ ប៊ុនលឺត ហើយជាអនុប្រធានមន្ទីរស្រុកកែវសីមា ហើយពីមុនជាកងការពារ។

[១១:២២:២៧]

**លោក សៅ សារុន៖**

**ឆ៖** បាទ ចាន់ ប៊ុនលឺត ក៏អត់ស្គាល់ មិនស្គាល់ទេ ចាន់ ប៊ុនលឺត, ចាន់ ឡឹងចូយ អីហ្នឹង អត់ស្គាល់ទេ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ចំណុចចុងក្រោយដើម្បីចង់ដឹងថាតើលោកនឹកឃើញឡើងវិញឬក៏អត់ លោកបានឆ្លើយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតគឺឯកសារ E3/383 ខ្ញុំចង់ដកស្រង់នូវសម្រង់មួយដើម្បីរំឭកការចងចាំរបស់លោក គឺទំព័រចុងក្រោយនៃបទសម្ភាសន៍របស់លោកគឺ ERN ជាភាសាបារាំង 00361766, ERN ជាភាសាអង់គ្លេស 00350266, ERN ជាភាសាខ្មែរ 00345915។ <ទាំងនេះជា>សំណួរចម្លើយចុងក្រោយដែល<ពាក់ព័ន្ធ>។ ពេលនោះគេសួរលោកដូចតទៅ ខ្ញុំសូមដកស្រង់៖ "តើមានករណីចាប់ខ្លួន<មួយណា ដែលលោកត្រូវ>សួរយោបល់ទៅមជ្ឈិម ហើយមជ្ឈិមឲ្យ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បញ្ជូនទៅភ្នំពេញឬទេ?" ពេលនោះលោកឆ្លើយដូចតទៅ៖ "ក្នុងពេលខ្ញុំជាគណៈតំបន់ មិនដែលមានទេ។" សំណួរបន្តទៅទៀត៖ "អ៊ីចឹងលោកមានដែលបញ្ជូនមនុស្សទៅមន្ទីរសន្តិសុខផ្សេងៗនៅក្នុងតំបន់ដែរឬទេ?" លោកឆ្លើយថា៖ "នៅក្នុងពេលខ្ញុំជា<សមាជិក>គណៈតំបន់ គ្មានទេ មានតែដោះលែង។ សួរ៖ តើនៅពេលលោកដោះលែងអ្នកទោសចាស់ៗ លោកមានសុំយោបល់ទៅមជ្ឈិមជាមុនដែរឬទេ? ឆ្លើយ៖ មិនដែលទេ នេះជាសិទ្ធិអំណាចរបស់ខ្ញុំ។ សំណួរ(ចុងក្រោយបំផុត)៖ តើលោកស្គាល់ទីតាំងមន្ទីរសន្តិសុខណាខ្លះ? ឆ្លើយ៖ <> មន្ទីរសន្តិសុខទំនប់ភ្នំក្រោល ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សុភា ប្រធានយោធាតំបន់។ ក្រោយមកគាត់ក្លាយជាប្រធានសន្តិសុខតំបន់។ អ្នកដែលកាន់តំណែងជំនួស សុភា គឺ វៀង (សុំទោសបើខ្ញុំអានឈ្មោះនេះមិនត្រូវ) ជាមេវរ<សេនាធំ>លេខ១ ពោលគឺ វៀង ដែលមានឈ្មោះថា ខាំ ឬ រុន។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះ លោកសាក្សី ខ្ញុំចង់សួរបញ្ជាក់លោក ពាក់ព័ន្ធនឹងចម្លើយដែលលោកឆ្លើយជូនការិយាល័យសហចៅក្រមស៊ើបអង្កេតនេះ លោកមានទឹកឃើញចម្លើយហ្នឹងឡើងវិញទេ? ហើយលោកអាចបញ្ជាក់ឲ្យបានច្បាស់បានទេថា<> លោកអាចមានសិទ្ធិអំណាចដោះលែងមនុស្ស ដោយមិនចាំបាច់សួរយោបល់ទៅមជ្ឈិម?

[១១:២៦:៣០]

**ឆ៖** បាទ សូមឆ្លើយ អាហ្នឹងគឺខ្ញុំមកកាន់ការងារនៅក្នុងតំបន់ -- សួរទៅគេ អាហ្នឹងគេចាប់ឃុំឃាំងនៅក្នុងមន្ទីរសាច់សូរហ្នឹងតាំងពីសម័យ តាឡាំង។ ខ្ញុំទៅកាន់កាប់ការងារតំបន់ហ្នឹង តាឡាំង ស្លាប់ទៅហើយ សួរទៅវាអត់មានហេតុ មានផលអីនឹងចាប់និងចងគេ អត់មានហេតុផលអីគេហ្នឹងក្បត់។ អាហ្នឹងគឺខ្ញុំប្រើសិទ្ធិរបស់ខ្ញុំ ខ្ញុំដោះលែង។ លែងហើយខ្ញុំក៏រាយការណ៍ទៅខាងលើដែរ ខ្ញុំក៏ខ្លាចដែរណា បាទខ្លាចមានរឿងដែរ ប៉ុន្តែខ្ញុំលែង អាហ្នឹងជាប្រើរបស់សិទ្ធិរបស់ខ្ញុំ។ អត់មានហេតុផលអី ហេតុផលសួនតួបុគ្គលគេ ប្ដីៗ ប្រពន្ធគេឈ្លោះគ្នាកំប៉ិកកំប៉ុកចេះតែចាប់ ខ្ញុំថាចាប់ធ្វើអី? កាលសម័យ តាឡាំង នៅនេះ ខ្ញុំ គេ គាត់ហៅប្រជុំហ្នឹង ខ្ញុំចេះតែថារហូតទេ។ អ្នករាយការណ៍ អាស្ដាបបាក់ក៏រាយការណ៍ខ្ញុំ ម៉ែពីណាមិនបាក់ស្ដាបព្រា បើយើងមិន វាមិនរែកូនយើងអស់ទៅ ឲ្យងាប់ទៅ? ស្ដាបព្រា ចាន មិនដែលថាវាមិនបាក់។ អាហ្នឹង ខ្ញុំមិនថា តាឡាំង ម្ដងនោះ។ រាយការណ៍កំប៉ិកកំប៉ុក អាស្ដាបព្រាបាក់ក៏រាយការណ៍ដែរ ម៉ែឪយើងបើអ៊ីចឹង មិនរែកូនងាប់អស់ហើយ គ្មានសល់មនុស្សទេ មិនដែលស្ដាបព្រាអីៗតែផ្ដេសផ្ដាស។ អាហ្នឹងគឺ ខ្ញុំប្រើសិទ្ធិរបស់ខ្ញុំ ខ្ញុំលែង អត់ប្រាប់គេ ឲ្យគេលែងមានសេរីភាពដូចគេដូចឯង។ លែងរួចហើយក៏ ខ្ញុំរាយការណ៍ទៅ តារិន *(ឮមិនច្បាស់)*។ រាយការណ៍ទៅរដ្ឋាភិបាល ទោសប៉ុន

នេះៗហ្នឹង គេសួរទៅអត់មានហេតុផល គឺខ្ញុំដឹង គេក៏ឯកភាពដែរ វាអត់មានហេតុផល ចាប់មនុស្សមកទទេៗយ៉ាងម៉េច។ សូមអស់។

[១១:២៨:៥២]

**ស៖** ជាភាសាបារាំង ខ្ញុំឮដូចជាតែម្នាក់ទេ។ ខ្ញុំនិយាយៗជាលក្ខណៈទូលំទូលាយ ក្នុងសម្រង់ដែលខ្ញុំអានឲ្យលោកស្ដាប់ក្នុងឯកសារ E3/383 នេះ លោកដូចជានិយាយថាលោកមិនចាំបាច់ទៅសុំយោបល់ថ្នាក់លើអីទេ គឺលោកមានសិទ្ធិអំណាចដោះលែងមនុស្សបានដោយមិនចាំបាច់រាយការណ៍ទៅអ្នកណាទេ។ លោកអាចបញ្ជាក់អំពីចំណុចនេះឲ្យបានច្បាស់បានទេ? <>លោក<និយាយសំដៅលើមនុស្ស>តែម្នាក់ឬក៏យ៉ាងម៉េច ពីព្រោះថាតាមរយៈភាសាបារាំង ខ្ញុំឮដូចជាតែម្នាក់ទេ។ អ៊ីចឹង សូមៗបញ្ចប់ត្រឹមហ្នឹងសិន ចាំខ្ញុំសួរលោកបន្តទៅទៀត សូមលោកឆ្លើយសិន <ព្រោះអ្វីដែលលោកនិយាយថ្ងៃនេះ វាខុសគ្នាពីពេលដែលលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។>

**ឆ៖** បាទ អាហ្នឹង ខ្ញុំលែងមិនមែនមួយនាក់ទេ លែងជាបន្តបន្ទាប់ មនុស្ស។ លែងហើយ យើងចេះតែសួរជាបន្តបន្ទាប់ អ្នកណាលែងមុន អ្នកណាលែងក្រោយ ចេះតែលែងបណ្ដើរៗទៅបាទ។ លែងរួចហើយក៏យើងរាយការណ៍ អ្នកណា វាចម្លើយវាខ្សែៗហ្នឹង យើងរាយការណ៍សួរមតិខាងលើដែរ។ មិនមែនថាចេះតែអំណាចខ្លួនឯងទេ អ្នកណាមានអំណាចសួរ លែងរួចយើងសួររាយការណ៍ប្រាប់។ បាទ សូមអស់។

**ស៖** ចម្លើយមុនរបស់លោក លោកបានពន្យល់ថា ជួនកាល គឺរឿងកំប៉ិកកំប៉ុក បន្តិចបន្តួចក្នុងគ្រួសារក៏ទៅចាប់ដែរ។ អ៊ីចឹងលោកសូមបញ្ជាក់ថាឲ្យច្បាស់មកថា រឿងកំប៉ិកកំប៉ុកបន្តិចបន្តួច ក្នុងគ្រួសារជារឿងអ្វីខ្លះ?

**ឆ៖** បាទ សូមចម្លើយ។ កំប៉ិកកំប៉ុកហ្នឹង ខ្ញុំចង់និយាយថា រឿងប្ដីប្រពន្ធណា ធម្មតាក្នុងគ្រួសារយើងឆ្លើយ ចេះតែប្រកែកគ្នាអ៊ីចេះឡើង រឿងអ៊ីចេះ រឿងអីនៅក្នុងគ្រួសារ កូនចៅ។ អាហ្នឹង ខ្ញុំហៅថារឿងកំប៉ិកកំប៉ុក។ អ៊ីចឹងខ្ញុំនេះ រឿងហ្នឹង គេចាប់មនុស្សប្រភេទហ្នឹង ខ្ញុំលែង លែងរួចហើយខ្ញុំរាយ-ការណ៍ អ្នកណាពាក់ព័ន្ធនឹងរឿងនយោបាយ សួរទៅ អាហ្នឹងខ្ញុំ ជាមតិខ្ញុំ សួររួច ដើរសួរគេរួចហើយលែង ហើយសុំមតិ ខ្ញុំប្រភេទនេះ តាមខ្ញុំពិនិត្យអត់មានទោសពៃរ៍អីវាធ្ងន់ ខ្ញុំសូមលែង។ ដល់អ៊ីចឹងខាងលើក៏ឯកភាព ក៏ខ្ញុំក៏លែង គេតបមកលែង ក៏ព្រមព្រៀងឲ្យគេមានសេរីភាពជាបន្តបន្ទាប់ អាហ្នឹងខ្ញុំបាន

លែងច្រើនដែរ។ ពីព្រោះទោស នៅសន្តិសុខនៅតំបន់ហ្នឹងវា មនុស្សនេះវាអត់ច្រើនដែរ តាមខ្ញុំឃើញណា តាំងពី*(ឮមិនច្បាស់)* មានប្រហែលជាបីបួននាក់ទេ។

[១១:៣២:១២]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ។ ពេលដែលលោកនិយាយអំពីមន្ទីរសន្តិសុខភ្នំក្រោល ហើយនិងអ្នកដែលមកកាន់តំណែងជំនួស សុភា ឈ្មោះ វៀង នេះ។ តើលោកមាននឹកឃើញឡើងវិញទេ?

**ឆ៖** ជំនួស សុភា, វៀង -- អើ! នឹកឃើញ។ វៀង នេះគេប្រធានវរសេនាតូច ហ្នឹងគេមកជំនួស វៀង -- អ៎! ជំនួស សុភា បាទ។

**ស៖** សំណួរខ្ញុំ គឺផ្តោតទៅលើអ្នកដែលមកជំនួស សុភា គឺឈ្មោះ វៀង។ អ៊ីចឹងលោកនឹកឃើញថាឈ្មោះ វៀង ហ្នឹង ជាអ្នកមកបន្តតំណែងពី សុភា ជាប្រធានសន្តិសុខមែនទេ?

**ឆ៖** បាទ មែន។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ ហើយខាងសហភាតារបស់ក៏អស់សំណួរដែរ គឺអត់មានអ្វីសួរទៀតទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

អង្គជំនុំជម្រះអរគុណលោក សៅ សារុន សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីដល់ពេលនេះបានដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយវត្តមានរបស់លោកនៅទីនោះ លែងមានភាពចាំបាច់ទៀតហើយ ឥឡូវនេះលោកអាចសម្រាក់បានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ ហើយនិងបានសេចក្តីសុខ សេក្តីចម្រើន។

អង្គជំនុំជម្រះក៏សូមអរគុណ លោក មឿន សុវណ្ណ មេធាវីប្រឹក្សាសាក្សី ឥឡូវនេះលោកអាចសម្រាកបានហើយ។ អរគុណលោក ញ៉ែម សំណាង បុគ្គលិកអង្គការអង្គភាពគាំពារសាក្សីនិងអ្នកជំនាញដែលបានជួយរៀបចំសម្របសម្រួល និង ដំណើរការសវនាការផ្តល់សក្ខីកម្មសាក្សី តាមប្រព័ន្ធសោតទស្សន៍នាពេលនេះ ប្រព្រឹត្តទៅបានល្អតាំងពីដើមរហូតដល់ចប់ លោកអាចសម្រាកបានហើយលោក សំណាង។

**លោក ញ៉ែម សំណាង៖**

បាទ លោកប្រធាន។ អរគុណលោកប្រធាន។

**លោក សៅ សារុន៖**

បាទ ខ្ញុំសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទៗ សម្រាកចុះណ៎ា។

**លោក សៅ សារុន៖**

បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ហើយមុននឹងសម្រាកថ្ងៃត្រង់នេះ អង្គជំនុំជម្រះចេញដីកាសម្រេចផ្ទាល់មាត់មួយទៅលើសំណើសុំរបស់សហព្រះរាជអាជ្ញាសូមឲ្យកោះហៅសាក្សីបន្ថែម ពាក់ព័ន្ធនឹងសវនាការលើអង្គហេតុចោទប្រកាន់មន្ទីរសន្តិសុខភ្នំក្រោលឯកសារ E390។ អង្គជំនុំជម្រះបានទទួលសំណើសុំរបស់សហព្រះរាជអាជ្ញាសូមឲ្យកោះហៅ និងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1017 អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងសម្រាប់អង្គហេតុចោទប្រកាន់មន្ទីរសន្តិសុខភ្នំក្រោលក្នុងសំណុំរឿង០០២/០២ ឯកសារ E390។ ហើយសហព្រះរាជអាជ្ញាបានស្នើសុំឲ្យស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1017 ជំនួស ឬបន្ថែមលើសាក្សី 2-TCW-1011។ អង្គជំនុំជម្រះបានស្តាប់សារណាផ្ទាល់មាត់របស់ភាគីនានានៅ -- ទៅលើសំណើសុំនេះកាលពីថ្ងៃច័ន្ទទី២១ ខែមីនា ឆ្នាំ២០១៦។ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ អង្គភាពគាំពារសាក្សីនិងអ្នកជំនាញបានរាយការណ៍មកថា ខ្លួនមិនអាចទំនាក់ទំនងជាមួយនឹងសាក្សី 2-TCW-1017 បានទេ ហើយបានយោងតាមក្រុមគ្រួសារ និងអ្នកជិតខាងរបស់សាក្សីរូបនេះ បានឲ្យដឹងថាសាក្សី 2-TCW-1017 បានផ្លាស់ទៅរស់នៅប្រទេសថៃជាអចិន្ត្រៃយ៍ហើយ។ ប្អូនពៅប្រុសរបស់លោក -- របស់សាក្សី 2-TCW-1017 កាលពីដំបូងបានបញ្ជាក់ថា ពុំមានព័ត៌មានលម្អិតអំពីអាសយដ្ឋានរបស់បងស្រីខ្លួននោះទេ ប៉ុន្តែក្រោយមក ក្រោយពីការព្យាយាមរកបានលេខទូរស័ព្ទបងស្រីគាត់ពីសមាជិកក្រុមគ្រួសារផ្សេងទៀតនោះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានព្យាយាមធ្វើទំនាក់ទំនងទៅកាន់សាក្សី 2-TCW-1017 តាមរយៈទូរស័ព្ទដែលបានផ្តល់ដូចនេះ តាំងពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦មកម្ល៉េះ ប៉ុន្តែមិនអាចទំនាក់ទំនងបាននោះទេ។ ដោយសារតែពុំមានព័ត៌មានលម្អិតណា

មួយច្បាស់លាស់បន្ថែមទៀត សំណើសុំឲ្យអាជ្ញាធរប្រទេសថៃជួយស្វែងរក និងកោះហៅសាក្សីរូបនេះ ទំនងជាត្រូវចំណាយពេលវេលារាប់ខែ ហើយលទ្ធផលនៃសំណើសុំនេះ ក៏ពុំដឹងថានឹងទទួលបានលទ្ធ-ផលយ៉ាងម៉េចនោះដែរ។

[១១:៣៧:៣៤]

អង្គជំនុំជម្រះយល់ឃើញថាខ្លួនមិនមានលទ្ធភាពទទួលបានសក្ខីកម្មរបស់សាក្សី 2-TCW-1017 នៅក្នុងរយៈពេលសមស្របបានទេ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបដិសេធសំណើរបស់សហព្រះរាជអាជ្ញាសូមឲ្យកោះហៅសាក្សីរូបនេះ។

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1016 សូមភាគីជ្រាប។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោកខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះវិញឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៨ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:២៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅរសៀលនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1016។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

សូមអញ្ជើញ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំផ្អៀតពេលដើមបណ្តឹងរដ្ឋប្បវេណីដើរចូលមកនេះ សូមអភ័យទោស ខ្ញុំផ្អៀតពេល ដើមបណ្តឹងរដ្ឋប្បវេណីចូលមកក្នុងសវនាការនេះ ដើម្បីស្នើសុំអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងការសម្រេចកាលពីព្រឹកមិញនេះ។ <តើ>យើងនឹងស្តាប់សាក្សី 1011 <នៅល្ងាចស្អែកឬក៏អត់ទេ>? ខ្ញុំ<ចង់>ដឹងថា តើ<សាក្សីមួយណានឹងបង្ហាញខ្លួន>បន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណី<នៅថ្ងៃស្អែក ព្រោះថាពេលនេះខ្ញុំដូចជាច្របូកច្របល់បន្តិចដែរ>។

**ប្រធានអង្គជំនុំ៖**

សូមជម្រាបថា ព្រឹកមិញនេះ យើងសម្រេចលើសំណើសុំរបស់ខាងការិយាល័យសហចៅក្រម--សហព្រះរាជអាជ្ញាដែលបានស្នើសុំ ហើយពីមុននោះ គឺយើងសម្រេចមួយហើយ ហើយរង់ចាំលទ្ធផលនៃការសិក្សាស្វែងយល់ពាក់ព័ន្ធនឹងបញ្ហាព័ត៌មានជុំវិញសាក្សីដែលស្នើសុំនោះ ពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។ ហើយឥឡូវនេះ យើងបានរបាយការណ៍ ហើយយើងផ្អែកមូលដ្ឋាននោះ យើងបានធ្វើការសម្រេចលើបញ្ហាសាក្សីដែលមានរហស្សនាម 2-TCW-1017 នៅព្រឹកមិញនេះ។ ហើយសូមជម្រាបថា ចំពោះសាក្សីបន្តទៀតដែលអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីនៅក្នុងសប្តាហ៍មុនពេលចូលឆ្នាំខ្មែរនោះ គឺអង្គជំនុំជម្រះនឹងជម្រាបជូនភាគីនៅក្នុងថ្ងៃនេះ។ ដោយអង្គជំនុំជម្រះក៏ជួបប្រឈមនឹងបញ្ហាក្នុងការរៀបចំកាលវិភាគសវនាការ ដើម្បីឆ្លើយតបឲ្យសមស្របទៅនឹងស្ថានភាព ដែលភាគីបានស្នើជាពិសេសក្នុង -- មេធាវីលោក ខាងភាគីមេធាវីការពារក្តី ដែលមានមេធាវី នួន ជា បានស្នើសុំកុំឲ្យអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងស-២១ នេះជាបញ្ហាហើយអ៊ីចឹងហើយ គឺយើងពិនិត្យលទ្ធភាពទាំងអស់នេះ ប្រឹងប្រែងឲ្យអស់លទ្ធភាព ដើម្បីធ្វើយ៉ាងណាប្រើប្រាស់ថ្ងៃដែលធ្វើការ សម្រាប់ធ្វើសវនាការឲ្យបានជាអតិបរមានៅក្នុងអំឡុងពេលនៃបញ្ហាដែលកំពុងកើតមានចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

កាលវិភាគកំណត់កាលបរិច្ឆេទសម្រាប់សប្តាហ៍ក្រោយ នឹងជូននៅថ្ងៃនេះចុងម៉ោង។

[១៣:៣៦:២០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**សៈ** សួស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

**លោក សុន វុត៖**

**ឆៈ** បាទ ឈ្មោះ សុន វុត។

**សៈ** អរគុណលោក សុន វុត។ តើលោកកើតនៅថ្ងៃខែឆ្នាំណាលោកចាំទេ?

**ឆៈ** ខ្ញុំកើតនៅឆ្នាំ១៩៥៧។

**សៈ** បាទ អរគុណ ហើយទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណា?

**ឆៈ** ស្រុកកំណើតពីដើមនៅស្រុកពួក ភូមិយាង ស្រុកពួក ខេត្តសៀមរាម បាទ។

**សៈ** សូមលោកស្តាប់សំណួរឲ្យបាន ហើយលោកគិតថា សំណួរដែលសួរទៅនេះ លោកស្តាប់យល់ដែរឬទេ ហើយលោកគួរឆ្លើយតបសំណួរយ៉ាងដូចម្តេច ពីព្រោះសំណួរតទៅមុខទៀត នឹងមានសំណួរជាច្រើនពីភាគីពាក់ព័ន្ធ ដែលមានសំណួរជាច្រើនដែលពាក់ព័ន្ធនៅក្នុងរឿងក្តីនេះ ដែលជាមានលក្ខណៈស្មុគស្មាញ ហើយស៊ីជម្រៅ។ ដូច្នេះ បើយើង លោកមិនស្តាប់សំណួរឲ្យបានច្បាស់លាស់ យល់ច្បាស់លាស់លើសំណួរទេ នោះនឹងអាចមានបញ្ហាក្នុងការឆ្លើយតប។ អ៊ីចឹង គឺវា ម្យ៉ាងគឺបង្អង់បន្តិចនេះ គឺក្នុងន័យគិតឆ្លើយតបនឹងសំណួរផង ហើយវាជាប្រយោជន៍សម្រាប់ដល់ពេលដែលលោកចាប់ផ្តើមឆ្លើយតបនឹងសំណួរនោះ គឺនាំឲ្យសំឡេងៗដែលប្រើប្រាស់នៅទីនេះ គឺទាំងសំឡេងលោក ទាំងសំឡេងភាគីដែលពាក់ព័ន្ធទាំងអង្គជំនុំជម្រះហ្នឹង គឺប្រើប្រាស់ជាបីភាសា ត្រូវបកប្រែជាភាសាបារាំង ភាសាអង់គ្លេស ឬក៏ទៅជាភាសាខ្មែរ ភាសាបារាំង ភាសាអង់គ្លេស។ អ៊ីចឹងវាមានបីភាសាណ៎ា ហើយចុះទីលំនៅសព្វថ្ងៃរបស់លោក តើលោករស់នៅទីកន្លែងណា?

[១៣:៣៨:២៨]

**ឆៈ** សព្វថ្ងៃរស់នៅភូមិបន្ទាយចាស់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យបាទ។

**សៈ** បាទ អរគុណ ហើយលោកប្រកបមុខរបរអីដែរសព្វថ្ងៃ?

**ឆៈ** ធ្វើស្រែចម្ការធម្មតា។

**សៈ** ឪពុកបង្កើតរបស់លោកឈ្មោះអី ហើយម្តាយបង្កើតរបស់លោកអី?

**ឆៈ** ម្តាយ សុន វ៉ាញ។

**សៈ** ឆ្លើយម្តងទៀត ឪពុកឈ្មោះអី?

**ឆៈ** ឪពុកៗខ្ញុំឈ្មោះ សាត ប៊ិត។

**ស៖** ម្តងទៀតលោក ឪពុកលោកឈ្មោះអី ហើយម្តាយលោកឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ សាត ប៊ិត។

**ស៖** ចុះម្តាយរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ម្តាយឈ្មោះ សុន វ៉ាញ។

**ស៖** ប្រពន្ធរបស់លោកឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំឈ្មោះ ឡេន នឹម។

**ស៖** កូន?

[១៣:៤០:០០]

**ឆ៖** កូនឈ្មោះ វុធ ឆេន។

**ស៖** កូនៗប៉ុន្មាននាក់ រាប់តែនាក់ទៅបានហើយ កូនៗលោកមានកូនប៉ុន្មាននាក់?

**ឆ៖** កូនតែមួយ ខ្ញុំ។

**ស៖** លោកមិនបាច់កាន់ក្បាលមីក្រូហ្វូនហ្នឹងទេ មានអ្នកសម្របសម្រួលហើយ ដើម្បី ព្រោះកាលណាលោក ឲ្យលោកធ្វើប្រតិបត្តិការខ្លួនឯងទៅអាចមានបញ្ហា យឺត បញ្ហាលឿន ឬក៏លោកភ្លេច ព្រោះមិនស្ទាត់រាល់ថ្ងៃទេ។ អ៊ីចឹងអង្គជំនុំជម្រះបានរៀបចំឲ្យអ្នកជំនាញខាងក្បាលមីក្រូហ្វូន ខាងសំឡេង និងរូបភាពហ្នឹង គេរៀបចំបើកជូនលោក នៅពេលដែលការបកប្រែភាសាហ្នឹងបានចប់ពីភាគីសួរណ៎ា។ រង់ចាំមើលក្បាលមីក្រូហ្វូនទៅបានហើយណ៎ា។ ហើយមន្ត្រីរដ្ឋបាលតុលាការពិនិត្យឡើងវិញម្តងទៀត រុញឲ្យជិតគាត់ទៅ ហើយទាញឲ្យៗងាកឲ្យចេញពីគាត់បន្តិចទៅទៀតហ្នឹងដើម្បីឲ្យគាត់ហ្នឹងបានមើលឃើញដោយខ្លួនឯងនូវភ្លើងក្រហម ដែលជាសញ្ញាប្រតិបត្តិការនៃការក្បាលមីក្រូហ្វូន។

លោក សុន វុត នៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ អង្គជំនុំជម្រះកោះអញ្ជើញឲ្យមកផ្តល់សក្ខីកម្មក្នុងឋានៈជាសាក្សី -- ក្នុងឋានៈជាអ្នកដើមបណ្តឹងរដ្ឋប្បវេណី ហើយក្នុងនាមលោក ឬក៏ក្នុងឋានៈលោកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះនេះ គឺជាចុងក្រោយបង្អស់នេះនៃការផ្តល់សក្ខីកម្មរបស់លោក គឺលោកអាចមានសិទ្ធិធ្វើសេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម បានន័យថា ផលអន្តរាយដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។

ហើយកន្លងមក តើលោកធ្លាប់បានផ្តល់កិច្ចសម្ភាសន៍ ឬក៏ផ្តល់ចម្លើយជូនដល់អ្នកស៊ើបអង្កេតនៃ

ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ?

**ឆ៖** បាទ បាន ស៊ើបអង្កេតពីរដង សួរ។

**ស៖** ហើយលោកដឹងថាធ្វើនៅពេលណា ហើយធ្វើនៅកន្លែងណាដែរទេ? ធ្វើ លោកៗដែលផ្តល់កិច្ចសម្ភាសន៍ហ្នឹងធ្វើនៅទីកន្លែងណា? ហើយនៅពេលណា? លើកទី១ និងលើកទី២?

[១៣:៤៣:០៥]

**ឆ៖** បាទ ធ្វើលើកទី១ នៅភូមិបន្ទាយចាស់ ស្រុកចុងកាល់បាទ ខេត្តឧត្តរមានជ័យ បាទ។

**ស៖** ចុះលើកទី២?

**ឆ៖** ធ្វើនៅទីក្រុងភ្នំពេញនេះ សម្ភាស។

**ស៖** លោកអាចភ័ន្តច្រឡំទេ តើលោកធ្វើចំពោះជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿងក្តី០០២ នៃតុលាការខ្មែរក្រហមនេះ ឬក៏ក្រុមមនុស្សផ្សេង? យើងចង់សួរលោកតែក្នុងក្របខ័ណ្ឌនៃអ្នកស៊ើបអង្កេតរបស់ការិយាយសហចៅក្រមស៊ើបអង្កេត ដែលធ្វើការស៊ើបអង្កេតផ្លូវការនៅក្នុងសំណុំរឿង០០២/០២ ទេ។ តើគេបានប្រាប់លោកថា គេៗមានតួនាទី គេមានឋានៈអីទេ អ្នកដែលបានធ្វើសម្ភាសន៍លោកនោះ?

**ឆ៖** បាទ ដែលបានសម្ភាសនោះគឺ អង្គការ ចុ មុនដំបូងបាទ។

**ស៖** បាទ អរគុណ។ នោះគឺមិនមែនជាអ្នកស៊ើបអង្កេតនៃការិយាយល័យសហចៅក្រមស៊ើបអង្កេតដែលជាបុគ្គលិករបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ជាអង្គការក្រៅរដ្ឋាភិបាលទេ។ ហើយអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមុនភាគីដទៃទៀត។ ហើយសហមេធាវីនាំមុខរួមទាំងសហព្រះរាជអាជ្ញាមានពេលវេលាពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោកលោកស្រីចៅក្រម យើងខ្ញុំសុំស្នើលោកប្រធានអនុញ្ញាតឲ្យលោក ឡោ ជុនធី ចាប់ផ្តើមសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញលោកមេធាវី ឡោ ជុនធី។

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សូមជម្រាបសួរលោក សុន វុត។ ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំមកពីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជាផងដែរ។ តទៅនេះ ខ្ញុំបាទសូមជម្រាបសួរលោកពូដែលពាក់ព័ន្ធទៅនឹងបទពិសោធន៍ក្នុងអំឡុងឆ្នាំ ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ រហូតទៅដល់ថ្ងៃ០៦ មករា ឆ្នាំ១៩៧៩។ មានន័យថា នៅក្នុងអំឡុងដែលរបបកម្ពុជាប្រជាធិបតេយ្យកាន់កាប់។ ជាដំបូង ខ្ញុំបាទសុំលើកឡើងនូវសំណួរមួយចំនួនដែលពាក់ព័ន្ធទៅនឹងប្រវត្តិរបស់លោកពូផ្ទាល់តែម្តង។ ទី១ ថាតើលោកបានចូលធ្វើបម្រើនៅកងទ័ពហ្នឹង នៅក្នុងឆ្នាំណាដែរ?

**លោក សុន វុត៖**

**ឆ៖** បាទ ខ្ញុំបាទបានចូលបម្រើកងទ័ពនៅឆ្នាំ១៩៧៤ បាទ។

**ស៖** បាទអរគុណ។ ហើយមានមូលហេតុពាក់ព័ន្ធទៅនឹងអ្វីដែលលោកពូចូលបម្រើកងទ័ពហ្នឹង ហើយកងទ័ពខាងណាដែរ?

**ឆ៖** បាទ ខ្ញុំបាទចូលបម្រើកងទ័ពនោះគឺ សម័យនោះគឺខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យដែលយកខ្ញុំទៅ បញ្ជូនខ្ញុំទៅធ្វើកងទ័ពបាទ។

**ស៖** លោកពូអាចបញ្ជាក់ខ្លីបន្តិចទេថា ពេលដែលចូលហ្នឹង ចូលដោយស្ម័គ្រចិត្ត ឬមួយចូលដោយយ៉ាងដូចម្តេច?

**ឆ៖** អត់ស្ម័គ្រទេ នេះគឺហៅទៅតែម្តង តម្រូវតាមអង្គការដែលតម្រូវយកបាទ។

**ស៖** បាទ ចុះបទពិសោធន៍លោកពូ នៅពេលដែលលោកពូបានចូលទៅបម្រើកងទ័ពហ្នឹង។ តើមានបានចូលទៅក្នុងសមរភូមិខាងណាខ្លះបាទ?

**ឆ៖** បាទ យកបញ្ជូនខ្ញុំទៅគឺវៃមួយជួរស្រុកពួក បាទ មួយជួរវត្តដង្កើម ហើយនិងភ្នំក្រោមដែលវៃសមរភូមិដែលត្រូវបញ្ជូនខ្ញុំទៅមុនដំបូងបាទ។

**ស៖** បាទ អរគុណ។ ហើយក្រោយមកទៀតមានអញ្ជើញមកខាងណាទៀតអត់ទេ?

**ឆ៖** បាទ ទើបមកតំបន់នោះរួច វាយសមរភូមិស្រុកពួករួច បានបញ្ជូនខ្ញុំមកដល់ទីក្រុងភ្នំពេញ

បាទ ហើយមកក៏មិនបានចូលទីក្រុងភ្នំពេញ ប៉ុន្តែវៃមួយជួរផ្សារត្រាច ឧដុង្គ ហើយរហូតមកដល់ភូមិធំ ត្រពាំងប្រើយ៍ មួយជួរភ្នំប្រសិទ្ធិ៍ រហូតមកបានចូលដល់ឃ្លួញកប់ស្រូវ បាទ ដំណាក់កាលដែលចូលអង្គាល់វ៉ៃ។

[១៣:៥០:២០]

**សៈ** បាទ អរគុណ។ ចុះនៅពេលនោះ លោកពូនៅពេលណាដែលត្រឡប់ទៅមណ្ឌលគិរីវិញ?

**ឆៈ** រំដោះបាន ៧៥ ចូលភ្នំពេញបានអង្គការបញ្ជូនពួកខ្ញុំកងពល៩២០ ឲ្យទៅការពារព្រំដែនវៀតណាម។

**សៈ** ព្រំដែនហ្នឹងអាចបញ្ជាក់បានបន្តិចទេថា ព្រំដែននៅម្តុំណាដែរ?

**ឆៈ** បាទ ព្រំដែន--

**ប្រធានអង្គជំនុំៈ**

កុំៗអាលទាន់។

**ឆៈ** បាទ ព្រំដែនដែលឲ្យបញ្ជូនខ្ញុំទៅគឺនៅកោះញែក ស្រុកកោះញែក ប៉ុន្តែទៅសមរភូមិគឺទៅអូរដាក់ដាំៗ មួយជួរម្រើច អូរពុល បាទ តំបន់សមរភូមិជាយដែន។

**សៈ** ពេលនោះលោកពូត្រូវជាយ៉ាងដូចម្តេចទំនាក់ទំនងជាមួយមេទ័ពដឹកនាំរបស់លោកពូហ្នឹង បាទ?

**ឆៈ** ជាមេរបស់ខ្ញុំគឺលោក តាឈិន គាត់ប្រធានកងពល៩២០ គឺ តាសយ គាត់អនុបាទ។ បានដឹកនាំខ្ញុំទៅឲ្យទៅនៅការពារព្រំដែនខាងមណ្ឌលគិរី។

**សៈ** លោកពូអាចបញ្ជាក់បានបន្តិចទេថា តើលោកពូពេលនោះធ្វើមុខងារលោកពូធ្វើអ្វីដែរ?

**ឆៈ** បាទ អង្គាល់ណោះវាខ្ញុំបាទឲ្យកាន់កងអនុសេនាធំ។

**សៈ** មិនមែនជានីរសាររបស់ តាឈិន ទេអ៊ីចឹង?

**ឆៈ** បាទ ពីមុនមិញ ខ្ញុំនៅនីរសារគាត់ផ្ទាល់ ប៉ុន្តែនៅទៅគាត់ដកឲ្យខ្ញុំចេញពីនីរសារឲ្យកាន់កងអនុសេនាធំ បាទ ពិសេសនៅជុំគាត់។

**សៈ** អង្គាល់លោកពូកាន់ជាតួនាទីជានីរសារ តាឈិន ហ្នឹងមានចាំឆ្នាំទេ ឆ្នាំណាដល់ឆ្នាំណាដែរ?

**ឆៈ** បាទ ដែលខ្ញុំចូលមកគឺនៅបានចំនួនប្រហែលជាពីរខែ គាត់យកខ្ញុំធ្វើនីរសារសម័យសង្គ្រាមដែលដាច់ភ្នំពេញ៧៥មករហូត។ រំដោះភ្នំពេញ៧៥ បានៗគាត់ទៅនៅមណ្ឌលគិរីវិញ បានឲ្យខ្ញុំឡើងកាន់

ប្រធានកងអនុសេនាធំ។

**ស៖** បាទ អរគុណ។ ខ្ញុំសូមបញ្ជាក់បន្តិចថា ក្រោយពីពូត្រឡប់ទៅមណ្ឌលគិរីវិញ តើមានគេបញ្ជូនលោកពូហ្នឹងទៅឲ្យទៅរៀនសូត្រខាងទ័ពហ្នឹងនៅខាងណាខ្លះ?

**ឆ៖** បាទ ដែលគេបញ្ជូនខ្ញុំបាទមករៀន គឺបានមករៀនមកភ្នំពេញ ឆ្នាំ៧៥ៗ មករៀននៅមួយជួរគេហៅវាលបែកចាន។ កាលនោះ ខ្ញុំរាងមិនសូវច្បាស់ដែរ ប៉ុន្តែបែកចានខាងជើងពោធិ៍ចិនតុងបាទ។ មកហ្វឹកហ្វឺនផ្នែកខាងយោធាបាទ បានចំនួនជាងមួយខែ បានបញ្ជូនឲ្យខ្ញុំទៅវិញ បានទៅលត់ដំនៅក្រចេះ ខេត្តក្រចេះទៀតបាទ។

[១៣:៥៥:៣៤]

**ស៖** អ៊ីចឹងខ្ញុំ -- មានន័យថាគេបញ្ជូនមកភ្នំពេញ រៀននៅភ្នំពេញហើយ បន្ទាប់ពីភ្នំពេញទៅរៀននៅក្រចេះទៀត។ អ៊ីចឹងមែនទេ?

**ឆ៖** បាទៗ បានទៅរៀនដល់ក្រចេះទៀតបាទ។

**ស៖** បាទ អរគុណ។ ថាតើនៅពេលដែលចេញពីក្រចេះហ្នឹង ទៅកន្លែងណាវិញទៀតបាទ?

**ឆ៖** ដែលចេញពីក្រចេះវិញ ក៏ទៅឈរជើងនៅមណ្ឌលគិរីវិញ។ បាននេះបានបញ្ជូនខ្ញុំឲ្យទៅនៅការពារព្រំដែន គឺដើម្បីរៀបចំឲ្យធ្វើចម្រូងចាក់ការពារព្រំដែន តាមបន្ទាត់ព្រំដែនវៀតណាមអូរដាក់ដាំ ជួរម្រើច រហូតទល់ព្រំប្រទល់ខាងអូរពុល។ បាទ ដើរធ្វើការតាមព្រំដែន ធ្វើចម្រូង ចាក់ចម្រូង ធ្វើខ្នារបាញ់ឯង បាទ តាមព្រំដែនដាក់ស្នោកស្កះ ជីកអន្លង់សម្រាប់គោរពតាមផែនការ ហើយនិងៗការពារប្រទេសជាតិ បាទទឹកដី។

**ស៖** បាទ អរគុណ។ ខ្ញុំសូមចូលទៅវគ្គមួយទៀតដែលលោកពូបានជួបប្រទះផ្ទាល់ ថាតើកាលនោះ មានការព្រឹត្តិការណ៍គេចាប់មេរបស់លោកពូដែរឬអត់ទេ?

[១៣:៥៧:៤២]

**ឆ៖** បាទ ពេលនោះក៏មានព្រឹត្តិការណ៍កើតឡើងដែរ គេហៅមេខ្ញុំហ្នឹងមករៀនបាទ ហៅមករៀនទៅ ក៏គេថាយកទៅសម្លាប់ចោលអស់ ថាក្បត់ពីអង្គការ។ ខ្ញុំក៏មិនដឹងថាគាត់ក្បត់របៀបម៉េច គឺខ្ញុំមិនដឹងដែរ ព្រោះខ្ញុំធ្វើការគឺបម្រើអង្គការពេញសិទ្ធិច្បាស់លាស់ជំនាន់នោះបាទ ប៉ុន្តែឮក្រោយមកបានគេចាប់មេខ្ញុំទៅចំនួនបានប្រហែលជាមួយខែជាង គេប្រាប់ល្បៀងមក ទាហានទាំងអស់គ្នា មិត្ត យុទ្ធមិត្តយើងថា "លោកឯង មិត្តឯងប្រយ័ត្នជាប់ខ្សែស្រឡាយ"។ ខ្ញុំក៏ៗមិនបានទេ ខ្ញុំមិនបានក្បត់ពីអង្គការទេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទោះបីជាមេខ្ញុំក៏មិនដែលគាត់ឮថានិយាយពីប្រាប់ខ្ញុំថា "មិត្តឯងត្រូវតាមខ្ញុំ" ក្បត់អង្គការ ទៅចូលទៅខាងណាខាងណើ ឮទៅយួនទៅអី មកវៃរបបថាខ្មែរក្រហមវិញ ក៏មិនឮដែរមានគាត់និយាយទេ មិនដែលដឹង ខ្ញុំក៏មិនដែលដឹងសោះ បាទ។ តែពេលនោះឡើយបានគេដឹងទៅគេចាប់ខ្ញុំបាទ ចាប់ខ្ញុំៗមិនដឹងរឿងអីបន្តិចសោះ មិនដែលក្បត់ពីអង្គការណាបន្តិច អង្គការដាក់ផែនការទៅទីណា ខ្ញុំជូនសម្រេចតាមផែនការបាទ។ មិនដែលថាមានពាក្យខ្ញុំទៅក្បត់ពីអង្គការទេ ធ្វើបម្រើកងទ័ពតាំងតែតូចមក បាទស្មោះត្រង់ជាមួយអង្គការ។ ថាអង្គការថាឯងក្លាហាន ថាសមមិត្តឯងធ្វើការល្អ គោរពអង្គការបាទ។ ដល់ទឹកបញ្ចប់មកវិញ មើលចោទប្រកាន់ខ្ញុំថាខ្ញុំក្បត់ពីអង្គការទៅវិញ។ ខ្ញុំក៏មានដឹងស្អីដែលអ្នកណា លោកណាដែលមកបញ្ចេះ បណ្ដឹងខ្ញុំឲ្យក្បត់ទៅនេះទៅនោះវៃអង្គការវិញ ខ្ញុំមិនដែលមានសោះ។ ដល់គេចាប់វៃសួរចម្លើយខ្ញុំៗដឹងឆ្លើយយ៉ាងម៉េច វាអស់ឆ្ងល់ ឆ្លើយប្រាប់ថាក្បត់ក៏នៅតែគេវៃចោល មិនប្រាប់ក៏គង់តែគេវៃម្ល៉េះហើយខ្ញុំនឹកឃើញខ្លួនខ្ញុំវាឃើចាប់ដែរ ត្រង់ចំណុចនេះ សំខាន់ណាស់ខំធ្វើការបម្រើជាតិ។ ខ្ញុំមិនដឹងថាអ្នកណាទេ មកវៃខ្ញុំឮ--

**ស៖** បាទៗ អរគុណបង។

**ឆ៖** បាទ។

**ស៖** បាទៗ អរគុណ។ អ៊ីចេះ ថាតើពូបានដឹងថា គេចាប់មេៗហ្នឹង អាចរៀបរាប់ឈ្មោះបានទេមេៗហ្នឹងប៉ុន្មាននាក់?

**ឆ៖** ដែលចាប់មេៗទៅ គឺកងពលគឺ តាឈិន តាសយ ហើយមាន មិត្តកុល មិត្តណុន។ កាលនោះដែលចាប់ទៅបានគឺ មិត្តយ៉េង បាទ មិត្តយ៉េង ចាប់ទៅក៏បាត់ទៅ មិនដឹងថា ទៅរៀន ក៏មិនដឹងថាទៅណារហូតទៅ។ គឺថាយើងក្បត់ពីអង្គការ គេវៃចោលនៅភ្នំពេញ។ គេឆ្លើយថា យកមកគុកទួលស្លែងខ្ញុំក៏មិនដឹងដែរ។ ហើយបានខ្ញុំភ្ញាក់ខ្លួនខ្ញុំ មិនបានគេច មិនបានដឹង ហើយថា ខ្ញុំស្មោះត្រង់នឹងអង្គការ។ បើខ្ញុំរត់ក៏ផុតដែរ តែខ្ញុំមិនរឿងថា ស្មោះនឹងអង្គការហើយ ខ្ញុំវាមានអ្នកចោទប្រកាន់។ បើមេក៏មិនដែលមាននិយាយបំពាក់បំប៉នឲ្យខ្ញុំថា "លោកឯង មិត្តឯង ត្រូវតាមខ្ញុំអ៊ីចេះៗ" ខ្ញុំអត់ដឹងដែរ។

[១៤:០១:១៣]

**ស៖** អរគុណលោកពូ។ ចំណុចសំខាន់ដែលពាក់ព័ន្ធទៅនឹងលោកពូហ្នឹង ថានៅពេលដែលគេចាប់លោកពូ ថាតើគេចាប់យ៉ាងដូចម្ដេច គេធ្វើទៅលើលោកពូហ្នឹងយ៉ាងដូចម្ដេច ហើយគេនាំលោកពូយកទៅណា?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ដែលគេមកចាប់នេះ គឺអ្នកដែលមកចាប់ បើខ្ញុំដឹងថាមកពីកងពល៨០១ បាទ មានតាសារឿន ប្រធានកងពល៨០១ គេហៅថា តា០៥៧ មកពី៨០១ គេចាប់ពួកខាងកងពល៩២០ រួច បានគេបញ្ជូនពួកមកពី៨០១ មកក្ដោបក្ដាប់នៅកងពល៩២០។ បាទ នេះកាលនោះវាទៅអ៊ីចេះ ថាកងពល៩២០ក្បត់ច្រើន ក្បត់ពីអង្គការច្រើន មេៗ បានដកពី៨០១មក មកក្ដោបក្ដាប់នៅកងពល៩២០ នេះបាទ។ ម្ល៉ោះហើយដែលចាប់ខ្ញុំទៅក៏គេធ្វើបាបទារុណកម្មខ្ញុំគឺសំខាន់ណាស់។ ហើយមុនដំបូងគេមកចាប់ខ្ញុំ ក៏ខ្ញុំមិនបានដឹងខ្លួនអីបន្តិចក៏មិនដឹង។ ដល់ហុចកាំភ្លើងមកបីនាក់ មកភ្ជង់។ "ចុះមិត្តឯងមកភ្ជង់ខ្ញុំធ្វើអី? ទេ មិត្តឯងក្បត់អង្គការ។ ហ៊ឺ! ចុះខ្ញុំមានបានដឹងរឿងក្បត់ឯណា?" គេភ្ជង់បាន គេរុញបុកខ្ញុំនឹងកាំភ្លើងទៅ ខ្ញុំក៏នឹកឃើញ ចុះមិត្តឯងធ្វើម៉េចអ៊ីចេះ? ទៅគេឲ្យលើកដៃ ខ្ញុំក៏លើកដៃទៅ។ លើកដៃប៉ាប់ គេយកក្រមាចងមុខពីប។ ចងមុខ ដឹក ក៏មិនដឹងគេដឹកទៅខាងណាដែរ។ ប៉ុន្តែខ្ញុំនឹកឃើញ វាឈឺចាប់ដែរ វាគួរណាដែលខ្ញុំវាបានក្បត់ ខ្ញុំនឹកឃើញអ៊ីចឹងរហូតទល់បច្ចុប្បន្ន។ ខ្ញុំនឹកឃើញគឺថា វាកំសត់ ជូរចត់ បម្រើបក្សហើយបក្សមិនទុកចិត្តទៀត ហើយខ្ញុំស្មោះត្រង់ មើលគេចាប់ខ្ញុំទៅបាន។

**ស៖** បាទ អរគុណលោកពូ។ សូមលោកពូឆ្លើយមួយកាត់ៗ ឲ្យខ្លីៗបន្តិចទៅលើសំណួរដែលខ្ញុំបានសួរ។ ហើយបន្តទៀតថា អម្បាញ់មិញលោកពូអត់បានឆ្លើយទេ ថាពេលដែលគេចាប់ហ្នឹង គេចងមុខចងអីហ្នឹង តើគេដឹកនឹងអ្វី ហើយយកទៅកន្លែងណា លោកពូមាននៅចាំដែរ អត់ទេ?

**ឆ៖** ដែលដឹកខ្ញុំទៅនោះ ក៏គេចងមុខ ក៏ខ្ញុំអត់ដឹងដែរ ប៉ុន្តែដល់គេស្រាយពី -- ស្រាយមុខទៅបានខ្ញុំអាចដឹងខ្លះ។ បាទ គេយកទៅដាក់នោះ ដែលគុកនោះក៏នៅមួយជួរអូរច្បារៗ ខាងត្បូងកោះញែក។ ហើយមានកូនភ្នំមួយ វាមិនជាភ្នំអីទេ ដីរាងទើរជាងខ្នងអណ្ដើក ក៏ខ្ញុំក៏ វានៅក្នុងគុក ខ្ញុំតាមមើលទៅវាអាចចំចំណុចនោះឯងបាទ។

[១៤:០៤:២៦]

**ស៖** បាទ អរគុណ។ លោកពូថា គេយកលោកពូទៅកន្លែងមួយហៅថា "អូរច្បារ" អ៊ីចឹងបាទ? ហើយសួរថាកន្លែងហ្នឹង ជុំវិញហ្នឹងមានស្អីខ្លះ លោកពូបាននៅចាំទេ ពេលដែលគេដាក់ទៅក្នុងគុកហើយបានន័យថា គេស្រាយមុខស្រាយអីហើយ អ៊ីចឹងលោកពូចាំទេ តើនៅជុំវិញហ្នឹងអាចរៀបរាប់បានទេ?

**ឆ៖** បាទ ដែលទៅខ្ញុំអាចដឹង មិនចងចាំបានទាំងអស់ទេ ប៉ុន្តែថាដែលយកខ្ញុំទៅ ខ្ញុំអាចដឹង គឺវាមានអូរមួយ អូរច្បារនោះឯង ថាអូរច្បារ គឺមានកូនភ្នំដើរបន្តិចប្រហែលជាមិនខ្ពស់ប៉ុន្មានទេ ភ្នំនោះបាទនៅឯចម្រាក់មាត់ព្រៃ រាងស្ដុកស្រូវ រាងសំយាក ស្ដុកគ្រាន់បាទ។ ហើយមានឃើញកន្លែងគុកគេធ្វើនោះ

ឯង ប៉ុន្តែមិនដឹងថាធ្វើយូរឆាប់ ខ្ញុំមិនដឹងដែរ ប៉ុន្តែដែលខ្ញុំជាប់ទៅក៏ គុកនោះក៏វាបណ្ដោយប្រហែលជា វា១០ម៉ែត្រៗ គឺទទឹងប្រហែលជា ៥ ទៅ ៦ម៉ែត្រ ទទឹង។ ហើយមានបីបន្ទប់គុកបាទ ដែលខ្ញុំចូល គឺនៅខាងត្បូង គ្រាន់តែគុកដែលខ្ញុំចូលមុនដំបូង គឺដាក់តែខ្ញុំម្នាក់ឯងទេ ដែលខ្ញុំសំខាន់ជាងគេបាទ។ ដល់ចាប់ពីថ្ងៃក្រោយទៀត ឃើញរំលងពីរថ្ងៃ ឃើញយកពីរនាក់មកដាក់ជាមួយខ្ញុំ។ បែបជាបន្ទប់ប៉ុន្មាននោះវាពេញក៏មិនដឹង ខ្ញុំក៏មិនដឹងដែរ។

**ស៖** បាទ ខ្ញុំចង់សូមបញ្ជាក់បន្តិចថា ពេលដែលលោកពូទៅដល់ហ្នឹង គេមានដាក់ខ្នោះដាក់អីទេ នៅពេលដែលដាក់នៅក្នុងគុកហ្នឹង?

**ឆ៖** បាទ ដាក់ខ្នោះ ដាក់ជើងផង ដៃ។ ជើងទាំងពីរ ដៃទាំងពីរដែរ។ ជាប់ទាំងអស់។

**ស៖** តើលោកពូអាចរៀបរាប់បានទេ ខ្នោះហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** បាទ ខ្នោះៗនោះវាឈើ វាចំនួនប៉ុននេះ គេខួង គេដាក់មួយប្រលោះជើងៗបាទ។ ចាប់ទាំងពីរ ដៃខ្ញុំក៏ចាប់ បានចំនួនមួយអាទិត្យ បានគេស្រាយដៃ គេទុកដៃមួយ ទុកជើងមួយបាទ។ នៅសល់បន្ធូរដៃបន្តិចបាទ។ បានរំលងពីរថ្ងៃទៀត បានគេហៅ ខ្ញុំទៅសួរចម្លើយ ១ឲ្យស្មោះត្រង់នឹងអង្គការបាទ។ បើស្មោះត្រង់នឹងអង្គការ គេអត់សម្លាប់ចោលទេ មិត្តឯង។ បើមិត្តឯងក្បត់នឹងអង្គការ មិនប្រាប់គេសម្លាប់ចោល។ ខ្ញុំក៏មិនដឹងឆ្លើយរបៀបម៉េច ព្រោះខ្ញុំមិនដឹងអីសោះ។

**ស៖** បាទ សូម -- ខ្ញុំសូមបន្តបន្តិចទៀត ពីស្ថានភាពជុំវិញដែលលោកពូថា ជាប់ឃុំនៅទីនោះ។ ពូអាចជម្រាបតុលាការបានទេថា គុកហ្នឹង គេធ្វើអំពីអី? ជញ្ជាំងធ្វើអំពីអី ហើយប្រក់អ្វីដែរ?

**ឆ៖** គុកនោះវាធ្វើពីឈើធំៗបាទ ឈើប៉ុនៗនេះទៅ វាជីកអន្លង់ វាតម្រៀបគ្នាបានជម្រៅប្រហែលជាចំនួនលើជង្គង់បាទ ហើយវាវៃស្នូកខ្នោះ ប្រហែលប៉ុនកជើង ហើយវាវៃអបខាង មិនអាចឲ្យយើងគាស់បានតែប៉ុណ្ណឹងឯងតាមមើល។ បាទ ប៉ុន្តែស្លឹកលើ គឺបាំងស្បូវមួយកំណាត់ ហើយស្លឹកប្រចេងនោះមួយកំណាត់។ បើខាងនោះគេច្រើនហៅដើមប្រចេង ភាសាជនជាតិភាគតិចពីដើមមិញច្រើនជនជាតិភាគតិចបាទ។ ពួកពួងអីទៅ ច្រើនទៅ ច្រើនហៅដើមប្រចេង ក៏ហៅតាមគេទៅ។ បាទ ហើយស្បូវមួយកំណាត់ ដើមប្រចេងមួយកំណាត់ ប៉ុន្តែជញ្ជាំងដែលដាក់អាឃាំងនោះគឺក្តារ។ ក្តារក៏មិនបានវៃជាប់ស្រួលទេ គ្រាន់តែវៃដាក់តម្រៀបគ្នាពីលើៗ មានមេវៃគាបតែប៉ុណ្ណឹងបាទ។ អាចមើលឃើញគ្នាបន្តិចៗត្រង់ណាប្រហោងបាទ។

[១៤:០៨:៥៨]

**ស៖** បាទ អរគុណ។ សូមបញ្ជាក់លោកពូម្តងទៀតថា នៅជុំវិញហ្នឹងមានផ្ទះអីដែរអត់ទេ? ហើយនៅក្នុងគុកហ្នឹងមានស្ត្រី ឬកុមារទេ?

**ឆ៖** ក្នុងគុកនោះ បើនៅសៀរៗជិតនោះ អត់មានផ្ទះទេ គឺមាន គឺថាធ្វើរោងមួយសម្រាប់គេអ្នកយាមបាទ។ ហើយសម្រាប់គេសួរចម្លើយ កូនរោងមួយខាងត្បូងកន្លែងគុក គឺដែលក្នុងគុកនោះ ក៏វាអាចមានពួមិត្តនារីខ្លះបាទ កាលសម័យមិត្តនារី ពួមិត្តនារី មាត់មិត្តនារីជាប់ដែរ ប៉ុន្តែមិនដឹងប៉ុន្មាននាក់ អត់ដឹងដែរ។

**ស៖** អរគុណលោកពូ។

**ឆ៖** បាទ។

**ស៖** ចំណុចមួយទៀត ថាតើលោកពូបានលើកឡើងអម្បាញ់មិញថា មានគេយកទៅសួរចម្លើយ តើនៅពេលដែលគេយកទៅសួរចម្លើយ គេយកលោកពូចេញពីគុកហ្នឹងទៅកន្លែងណា ឬមួយទៅកន្លែងផ្សេងទៀតដើម្បីសួរចម្លើយ? ហើយការសួរចម្លើយហ្នឹង គេមានធ្វើទារុណកម្មអីដែរអត់?

**ឆ៖** បាទ ដែលគេហៅខ្ញុំទៅ ក៏គេយកទៅកន្លែងខ្ទមនោះឯង កន្លែងខ្ទមសម្ងាត់នោះបាទ។ សួរចម្លើយមុនដំបូងគេដាក់ឆក់ខ្សែភ្លើងបាទ ឆក់ខ្សែភ្លើងខ្ញុំ ក៏ខ្ញុំក៏វា ដូចថាបាត់ស្មារតីអស់ ឲ្យខ្ញុំឆ្លើយៗ ថាខ្ញុំមិនឆ្លើយទៅគេឆក់ទៀតទៅ ដល់ឆក់ទៅ ខ្ញុំដូចថាវាសន្លប់ គឺអត់ដឹងខ្លួនផង វាដូចថា ដឹងថាខ្លួនស្លាប់មានតែប៉ុណ្ណឹងខ្ញុំ។ បានខ្ញុំដឹងខ្លួនប៉ាច់វាសួរទៀត ៗវាឈប់ឆក់ គេវ៉ៃបណ្តោយ គេវ៉ៃ ថាឆក់ទៅ ខ្លាចខ្ញុំមិនបានឆ្លើយសំណួរឲ្យបាន ឲ្យគេបានអស់ ក៏គេឈប់ឆក់ គេវ៉ៃ ដល់វ៉ៃវាអាចយើងឆ្លើយបាន។ ដល់ហើយខ្ញុំមិនដឹងឆ្លើយរបៀបម៉េច ព្រោះខ្ញុំអត់មានបានអង្គការ ឬមេណានឹងឲ្យខ្ញុំក្បត់ពីអង្គការ អត់ដែលមានអីឲ្យខ្ញុំឆ្លើយយ៉ាងម៉េច បើថាខ្ញុំក្បត់ខ្ញុំសុខចិត្តស្មោះត្រង់ប្រាប់ទៅចុះ បើខ្ញុំអត់បានក្បត់អីបន្តិចសោះ។ មេណាដែលនៅ មេខ្ញុំដែលខ្ញុំធ្លាប់នៅជាមួយហ្នឹង ក៏គាត់ តាសយ តាឈិន ក៏មិនដែលឮថាប្រាប់ខ្ញុំ "មិត្តវុត មិត្តឯងគេចពីរបបនេះ" ឮអីចេះអីចុះអី ក៏មិនដែលមានអីសោះ។ ទៅដល់ហើយ គេចោទប្រកាន់ថាខ្ញុំខ្សែរយៈទៅតាម ក្បត់តាមមេ។ បាទ អីចឹងឯង បាទ។

[១៤:១១:៣៨]

**ស៖** បាទ អរគុណ។ កន្លែងសួរហ្នឹង អាចចម្ងាយប៉ុន្មានពីកន្លែងឃុំខ្លួនរបស់លោកពូ?

**ឆ៖** ចម្ងាយប្រហែលជា ៥០ម៉ែត្រ ពីកន្លែងដែលនៅក្នុងគុកបាទ។

**ស៖** លោកពូអម្បាញ់មិញបានរៀបរាប់ខ្លះៗហើយថា គេវ៉ៃសួរចម្លើយ ឆក់ខ្សែភ្លើង។ ថាតើ

គេៗចង់បានចម្លើយអ្វីពីលោកពូ ឬមួយគេសួរសំណួរដែលគេសួរលោកពូហ្នឹង មានចាំទេ ថាតើគេសួរពាក់ព័ន្ធនឹងអ្វីដែរ?

**ឆ៖** បាទ ដែលគេសួរខ្ញុំនេះ គឺគេថា គេចង់សួរចម្លើយថាយើងក្បត់ជាមួយមេ ឮយើងក្បត់ទៅជាមួយយួនបាទ ចូលទៅយួនបាទ។ សួរចម្លើយមានតែប៉ុណ្ណឹង ដែលគេសួរ ថាៗខ្ញុំយួន "ក្បាលយួនខ្លួនខ្មែរ" ចោទប្រកាន់ខ្ញុំ តែខ្ញុំមិនដឹងឆ្លើយយ៉ាងម៉េច គឺខ្ញុំអត់ដឹងដែរខ្ញុំ គេថាឯងក្បត់ ថា "ខ្លួនយួន ខ្លួនខ្មែរមិត្តឯងមិនប្រាប់គេសម្លាប់ចោលតែដដែលហ្នឹង"។ បាទ ខ្ញុំក៏នឹកឃើញថា "អូ! បើសម្លាប់ក៏មិនដឹងធ្វើម៉េចខ្ញុំ មានតែស្ដាប់ហើយ ប៉ុន្តែមិននិយាយ បានតែនឹកឃើញ" មិនដឹងទៅវាយការណ៍យ៉ាងណា ព្រោះអីមិនដឹងអីសោះ ខ្ញុំនឹកឃើញថាអ៊ីចឹង បាទ។

**ស៖** បាទ អរគុណ។ ថាតើនៅក្នុងអំឡុងពេលដែលលោកពូបានជាប់នៅទីនោះ គេបានឱ្យអាហារឱ្យអីបានត្រឹមត្រូវទេ? ត្រឹមត្រូវដែរអត់ទេ?

**ឆ៖** បាទ ដែលអាហារនោះគឺ ដែលខ្ញុំចាប់ខ្ញុំមុនដំបូងគឺ ក្នុងមួយយប់នោះ ក្នុងមួយថ្ងៃគឺអត់បានអាហារចូលពោះទេខ្ញុំ។ រំលងថ្ងៃស្អែកទៀត រំលងពីផុតពីដែលគេចាប់នោះទៅ បានគេឱ្យបាយមួយបន្តិច ប្រហែលជាប៉ុនកដៃ ខ្ញុំ និយាយឱ្យត្រង់ទៅចុះ ស្មោះត្រង់ ប៉ុនកដៃ។ *(ឮមិនច្បាស់)* ហើយដាក់ទឹកនឹងត្រឡោកឱ្យមកបន្តិច។ បាទ តែប៉ុណ្ណឹងឯងខ្ញុំ បាទ។

[១៤:២៥:០០]

**ស៖** អរគុណ។ ចំណុចសំខាន់មួយទៀត ពេលគេដាក់គុក ហើយគេសួរចម្លើយលោកពូ ចុះហេតុ មានមូលហេតុអីដែរទេ ដែលលោកពូអាចចេញពីទីនោះបាន?

**ឆ៖** បាទ ខ្ញុំដូចជាបានរួចពីគុកនោះ ក៏ដូចជាថា និយាយទៅថាអបិយជំនឿយើងជំនឿបាទ។ ហើយខ្ញុំដេកយល់សប្តិដល់ឪពុកម្តាយខ្ញុំប្រាប់ថា មិនដឹងថាម្ចាស់ទឹកម្ចាស់ស្រុកនៅដីនោះ ក៏ជួយខ្ញុំផងក៏មិនដឹង។ ម្ល៉ោះហើយប្រាប់ថាកូន ឪពុកខ្ញុំថាកូន កូនឯងឆាប់រត់ទៅបើមិនរត់គេវៃចោលហើយ។ តែស្អែកនេះត្រូវតែគេវៃហើយ ខ្ញុំដេកយល់សប្តិថាម្តាយខ្ញុំគឺថា កូនឆាប់រត់ចេញទៅ។ ខ្ញុំក៏ភ្ញាក់ឡើងថាអ៊ីយ៉ា! ដៃជាប់ចំណង មិនដឹងល្បិចម៉េច ខ្ញុំគ្រលែងម៉េចបានទៅដូចជា ថាស្អីជួយបាទ ប្រឹងទៅម៉ាភឹះចេះរបើកសោរផ្តួចបាទ សោរផ្តួចនៅជើងម្ខាង ធ្វើម៉េច គឺគាស់ ទាញកន្ត្រាក់ដូចស្អីជួយផងទេ គុណបានថាទឹកដោះម្តាយខ្ញុំថ្លៃ ជីវិតខ្ញុំមិនអស់។ ខ្ញុំមិនក្បត់ពីអង្គការ អាហ្នឹងនិយាយឱ្យចំតែម្តងទៅ។ ត្រង់ទៅបានរបូតសោរមួយទៀត ខ្ញុំកន្ត្រាក់បានទៅ បានរំដោះយកបានពីរនាក់នៅជាមួយខ្ញុំនោះឯង បានបី

01239196



នាក់និងខ្ញុំបានចេញពីគុករួច កាលសម័យនោះបាទ។ បានរួចពីគុកបានបីនាក់ជាមួយខ្ញុំ ម៉ាគុកនោះក៏ឈើ វាមិនសូវធំ វាចងអបនឹងអែបនឹងបង្គោលរបង ធ្វើបានរបើកអានោះ ក៏យកទៅ អាពួកនោះវាចាប់ចងតែជើងដាក់ច្រវាក់តែម្ខាងទេ ប៉ុន្តែយកឈើនោះហើយចេញពីគុកបានទាំងអស់។ ទៅក៏ទៅស្រាយបានចំនួនប្រហែលជា៥០០ម៉ែត្រជាង ថាជាង៥០០ម៉ែត្រចុះ រកអីកាស់កាច់បានបានទៅ បានរបូតទាំងអស់គ្នាបាន។ ប៉ុន្តែដែលវាដេកយាមក៏មិនឆ្ងាយពីខ្ញុំ ចម្ងាយប្រហែលជាដប់ម៉ែត្រប៉ុណ្ណោះអត់ដឹង អាហ្នឹងដូចថាវាជួយខ្ញុំបាន បានខ្ញុំសុខ។ ខ្ញុំត្រូវតែស្លាប់ គេត្រូវតែសម្លាប់ក្នុងថ្ងៃនោះ ខ្ញុំដឹងខ្លួនខ្ញុំថាស្លាប់ហើយ ប៉ុន្តែអ្នកទាំងពីរនាក់ដែលជាប់ជាមួយខ្ញុំគេ ជាយុទ្ធជនចុះ គេវាមិនដឹងថាម៉េចទេ។ បើខ្ញុំ គេថាមេឯងក្បត់វាមិនបានទុកទេកាលនោះ គេអត់បានទុកទេ។ ពួក អាផេង និងអាបៃ នេះវាអ្នកសម្លាប់។ នេះវាពួកមហាឃោរឃៅពិភពគុន។ វាពីដើមមិញ វានៅជាមួយខ្ញុំទេ ប៉ុនដល់គេថាខ្ញុំក្បត់ទៅគេបានមកកងពល៨០១មកក្តោបក្តាប់នៅកងពល៩២០ទៅ គេបានបំពាក់បំប៉នស្មារតីយ៉ាងម៉េចបានគេមកធ្វើបាបគ្នាឯងទៅវិញបាទ ដែលខ្ញុំជាក្តោបក្តាប់វាពីដើមបាទ។ បានខ្ញុំ អាដែងថាអីណាគេចាប់ទៅហើយវានៅក្នុងដៃគេហើយថាយើងក្បត់ ខ្ញុំក៏មិនហ៊ានប្រកែក ទោះបីគេវៃក៏ខ្ញុំសុខចិត្តថា មិត្តឯងធ្វើបាបអីខ្ញុំ ខ្ញុំគ្រាន់ថា មានវិចារទៅវិញតែប៉ុណ្ណឹងបាទ។

[១៤:៣៧:៣៥]

**ស៖** បាទ អរគុណលោកពូ។ គឺអំម្បាញ់មិញលោកពូលើកឡើងឈ្មោះ ផេង ហ្នឹង តើឈ្មោះ ផេង ហ្នឹងគាត់ជា -- ពីមុនគាត់ធ្វើអ្វី ហើយពាក់ព័ន្ធអ្វីទៅជាមួយនឹងគុកហ្នឹង?

**ឆ៖** បាទ ផេង នោះ វាមិនធ្វើអីទេ គឺវាប្រធានក្រុមនៅក្នុងចំណោមកងពលចាស់ ដែលនៅនោះជុំខ្ញុំ។ ប៉ុន្តែដែលគេបានដកមកពី៨០១ ទៅគេឲ្យក្តោបក្តាប់ការងារដឹង ពីព្រោះគេមេចាស់ៗគេអត់ឲ្យធ្វើការទេ គេយកមេថ្មីមកធ្វើទាំងអស់បាទ។ ម្ល៉ោះហើយគេមិនទុកចិត្តយើងជាមេចាស់ មាននៅខ្លះមេចាស់ ហើយហៅទៅរៀនខ្លះ នៅមានខ្លះ គេដកសិទ្ធិអស់ គេអត់មានកាន់អីទេ គេឲ្យធ្វើយុទ្ធជនធម្មតាបាទ។ ដល់ព្រឹត្តិការណ៍ផែនការវាមិនស្រួលទៅ គេឲ្យយុទ្ធជនដែលកាន់មេនោះ វាច្បាំងអត់កើត ច្បាំងជាមួយយួនអត់កើត គេឲ្យអាមេចាស់នោះ វាកាន់តំណែងទៅវិញបាទ។ មានៗ មេចាស់ប៉ុន្មាននាក់ដែលជាប់តំណែងបាទ។ យុទ្ធជនធ្វើអត់កើត ដឹកនាំអត់បានកាលសម័យនោះ។

**ស៖** បាទ អរគុណលោកពូ។ ខ្ញុំចង់ត្រឡប់ទៅក្រោយវិញបន្តិច ក្រោយពីលោកពូបានចេញពីគុកហ្នឹងទៅ តើលោកពូទៅរស់នៅកន្លែងណា?

01239197



**ឆ៖** បាទ ខ្ញុំរត់ពីគុក គឺខ្ញុំចូលព្រៃរហូតបាទ។ រហូតដល់៨៦ បានខ្ញុំមកលេងផ្ទះ មកលេងផ្ទះក៏បានដឹងដំណឹងពីឪពុកម្ដាយខ្ញុំស្លាប់អស់ទៀតបាទ។ គេធ្វើទារុណកម្ម ថាខ្ញុំទារុណកម្មហើយ ដល់ឪពុកម្ដាយបងប្អូនខ្ញុំគេសម្លាប់ចោលអត់មានមូលហេតុអ្វីសោះ ប៉ុន្តែឪពុកម្ដាយខ្ញុំគាត់កាលដាច់ភ្នំពេញ៧៥។ ពីសម័យនោះគាត់បានធ្វើជំទប់លេខ១ មេឃុំគេហៅថា ជំទប់លេខ១ ពីសម័យសាធារណរដ្ឋផងបាទ។ ដល់ទៅដាច់ភ្នំពេញ៧៥ គាត់ក៏បានភៀសខ្លួនទៅនៅប៉ៃលិនពួកម៉ាក់គាត់។ ហើយគាត់នោះមិនមែននៅទេ ប្រុងតែនឹងរត់ទៅក្រៅប្រទេសទៀត គេចខ្លួនឲ្យតែបានផុតសិន ព្រោះរបបនោះគេបំបាត់អនុធនបញ្ញវន្ត សាស្ត្រាចារ្យ គឺគេមិនស្ងួវទុកទេ គេសម្លាប់ចោលហើយ វាទុកទេ យកអ្នកល្ងង់មិនដឹងអីអានោះគេឲ្យមកដឹកនាំវិញ។ បាទ របបនោះគឺមានតែប៉ុណ្ណឹង។ ម្ល៉ោះហើយឪពុកខ្ញុំបានទៅនៅ ម្ដាយខ្ញុំនោះគេប្រាប់មក ចៅសង្កាត់គេប្រាប់ ថ្នាក់សង្កាត់ ថ្នាក់តំបន់គេប្រាប់ថា "មីងឯងឆាប់ទៅតាមប្ដីមីងឯងមកវិញ បើមិនទៅតាមទេ គឺគេសម្លាប់អស់មួយពូជ" ហើយម្ដាយខ្ញុំក៏នឹកឃើញខ្លាចគេសម្លាប់កូនចៅបងប្អូនអស់ទៅ សុខចិត្តទៅតាមដឹងដំណឹងថាពុកខ្ញុំនៅប៉ៃលិនទៅក៏វាក់គាត់មែន ដល់វាក់ទៅក៏ជួបក្ដើគាត់នេះថា "គាត់ថា អ៊ូ! អញទៅដឹងតែងាប់ហើយ" គឺខ្មោចម៉ែគាត់ថាអត់មកទេ អញមិនបានទៅទេថា "ម៉ែវាមិនទៅទេ តែទៅងាប់ហើយ"។ គឺខ្មោចម៉ែក៏គាត់ថា "អ៊ូ! ឪវាបើមិនទាន់គេសម្លាប់បងប្អូនកូនចៅងាប់អស់"។ ម្ល៉ោះហើយឪពុកគាត់ក៏ដាច់ចិត្តមេត្តាមិនបាន ក៏គាត់សុខចិត្តស្រក់ទឹកភ្នែកលះបង់ពីក្ដើពួកម៉ាក់គាត់នៅប៉ៃលិន គាត់ក៏មកទៅតាមម្ដាយខ្ញុំទៅ។ ដល់មកទៅបានចំនួន -- ដែលបងប្រាប់នោះបានចំនួនពីរថ្ងៃគេហៅអញ្ជើញឪពុកខ្ញុំទៅរៀន។ ទៅរៀននៅស្រុកអង្គរជុំ តំបន់អង្គរជុំ គឺតំបន់ស្លាប់ ដឹងតែទៅប្រលោះនោះដឹងតែស្លាប់។ ដល់ទៅរៀនទៅបានប្រហែលជាពីរថ្ងៃ ឮដំណឹងថា ម្ដាយខ្ញុំថាស្លាប់ហើយ។ បងខ្ញុំប្រាប់ថាម្ដាយខ្ញុំថា ឪពុកខ្ញុំស្លាប់ទៅហើយ។ ហើយនៅ -- ដឹងតែស្លាប់ គាត់គឺទៅដឹងតែស្លាប់មែនបាទ។ តាមដានដឹងស្លាប់ យកទៅវ៉ៃ គេឲ្យព័ត៌មានដឹង។

[១៤:២១:៥៣]

**ស៖** បាទ អរគុណ។ ចុះពាក់ព័ន្ធនឹងបងប្អូនសាច់បង្កើតៗជាមួយនឹងលោកពូ តើមានបញ្ហាអីព្រឹត្តិការណ៍អីកើតឡើងលើពួកគាត់ដែរឬទេ?

**ឆ៖** បាទ ផុតពីឪពុកគេចាប់ទៅ ក៏បងប្អូនខ្ញុំទាំងបីនាក់ក៏បានគេចាប់ទៅទៀត។ ចាប់យកទៅទាំងអស់ ហើយបងខ្ញុំមួយនោះធ្វើទាហាន លន់ នល់ គាត់ស័ក្តិ១ ដល់មកផ្ទះថា មកលះលែងបាត់ចោលទៅ គេបញ្ជូនហៅ គេហៅទៅរៀនទៀត ទៅរៀនទៅក៏បាត់ឈ្មោះទៅទៀតទៅ។ ហើយបងមួយទៀត

នោះវាគ្រូបង្រៀន ហៅទៅនោះក៏ទៅបាត់ទៅទៀតទៅ។ បងរឿង នោះក៏ទៅបាត់ទៅទៀតទៅ អស់ទាំងឪពុកម្ដាយ ហើយបងប្អូនជីដូនមួយក៏អស់ច្រើនណាស់ខ្ញុំ ប្រាំបីនាក់ទាំងអស់។ នេះគេថាឯង ក្បត់ពីអង្គការ។ កាលសម័យនោះ ខ្ញុំក៏មិនដឹងដែរ ក៏វាថាក្បត់អង្គការ។ យើងតវ៉ានឹងអង្គការគេ--

**ស៖** បាទ អរគុណលោកតា។

**ឆ៖** បាទ។

**ស៖** គឺអម្បាញ់មិញលោកតាបានរៀបរាប់ហ្នឹង តើលោកតាបានដឹងព័ត៌មានហ្នឹងតាមរយៈនរណាដែរ? ហើយអាចបញ្ជាក់ឆ្នាំបានទេ ដែលគាត់មានបញ្ហាហ្នឹង?

[១៤:២៣:៣៩]

**ឆ៖** នៅឆ្នាំដែលខ្ញុំដឹងនោះគឺនៅឆ្នាំ១៩៨០, ៨៦ បាទ។ ៨៦ ខ្ញុំបានត្រឡប់មកវិញ បានបងអ្នកព័ត៌មានប្រាប់បានដំណឹងដែលខ្ញុំទៅនៅខាងព្រំដែននោះ អត់ដឹងរឿងទេ ទើបមកដឹង៨៦ ដែលខ្ញុំបានទៅវិលមកបានចូលផ្ទះវិញគឺបងប្អូននិយាយប្រាប់ទៅថាស្លាប់អស់ហើយ គេយកទៅវ៉ៃចោលអស់។ ខ្ញុំក៏នឹកឃើញថាឈឺចាប់ដែរខ្ញុំ ខំតស៊ូដើម្បីការពារប្រទេសជាតិ បម្រើបក្ស បម្រើអង្គការ ប៉ុន្តែអង្គការមកចោទប្រកាន់ មើលមួយពូជខ្ញុំស្លាប់អស់ ចុះបើខ្ញុំធ្វើសម្រាប់ការពារប្រទេសជាតិហើយឲ្យវ៉ៃបងប្អូនម៉ែឪចោលចុះ តើខ្ញុំអ្នកបម្រើអង្គការទៅការពារព្រំដែន ខ្ញុំវាចិត្តល្អ ខ្ញុំវាឈឺចាប់របៀបម៉េច។ បាទ ខ្ញុំវាអន់ចិត្តណាស់សព្វថ្ងៃ ខ្ញុំឮតែនិយាយ ខ្ញុំចង់តែវាអួលដើម-ក។

**ស៖** បាទ សូមទោសលោកតា។ អម្បាញ់មិញ លោកតាអត់ទាន់បានបញ្ជាក់ថា ព្រឹត្តិការណ៍ដែលកើតឡើងទៅលើឪពុកនិងបង និងប្អូនរបស់លោកតាហ្នឹងអាច បើអាចជម្រាបបានគឺអាចចាំថា តើឆ្នាំណាដែរ ដែលកើតឡើងហ្នឹង?

**ឆ៖** ដែលបងគាត់ប្រាប់ទៅបានខ្ញុំបានដឹងព័ត៌មាន គឺឆ្នាំ១៩៧៦ បាទៗដែលបានដែលខ្ញុំបានមកជួបនោះបងប្រាប់ថាគេយកទៅសម្លាប់ចោលអស់ ទៅរៀនអស់ ៧៦នេះបាទ ដឹងដំណឹងបាទ។

[១៤:២៥:២៤]

**លោក ឡោ ជុនធី៖**

បាទ លោកប្រធាន ខ្ញុំបាទអស់សំណួរហើយ។ បាទ សូមអរគុណតា។

**សួរដោយលោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំសូមអនុញ្ញាតសួរបន្ត។

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** បាទ ខ្ញុំបាទ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយខ្ញុំមានសំណួរមួយចំនួនដើម្បីសួរបញ្ជាក់ទៅលើលោកដើមបណ្ដឹងរដ្ឋប្បវេណី។ លោកដើមបណ្ដឹងរដ្ឋប្បវេណីលោកអាចបញ្ជាក់បានទេក្រៅពីមេដឹកនាំ៩២០ ពីររូបអម្បាញ់មិញ តើលោកមានស្គាល់អ្នកណាផ្សេងទៀតដែលជាមេដឹកនាំ៩២០ដែរទេ?

**លោក សុន វុត៖**

**ឆ៖** បាទ ស្គាល់។ ខ្ញុំបាទបានស្គាល់មេមកដឹកនាំនៅ៩២០ គឺមានបង០៦ បាទ។ ០៦ គេហៅតាសាន ស្រុកកំណើតគាត់នៅក្រចេះ នៅស្រុកព្រែកប្រសប់ ខេត្តក្រចេះបាទ។ បាទ ហើយមួយទៀតគឺតាឡឺ – ឈ្មោះតាឡឺ គាត់ខាងកងពលដែរ ប៉ុន្តែគាត់ខាងភស្តុភារ តាមមករៀបចំដែរ រចនាសម្ព័ន្ធក៏ភស្តុភារអង្គាល់គេរៀបចំ ប៉ុន្តែគាត់ជនជាតិបាទ ជនជាតិភាគតិច តាឡឺ បាទ។

**ស៖** លោកបាននិយាយអម្បាញ់មិញ តាសាន ហើយនិងតាឡឺហ្នឹង ថាតើគាត់កាន់មកធ្វើការនៅក្នុងយោធាកងពល៩២០ ហ្នឹងតាំងពីដើមមក ឬក៏ពេលណាមួយជាក់លាក់ទេ?

[១៤:២៧:២៨]

**ឆ៖** បាទ ដែលមកកាន់កាប់នៅកងពល៩២០នេះ តាំងពីចាប់មេខ្ញុំចាស់មុនទៅ តាឈិន តាសយ ទៅបានគេៗហៅពី៨០១ មកក្តាប់នៅកងពលទី៩ -- អ! នែ៎បាទ៩២០ បាទៗគេឲ្យមកកាន់នៅ៩២០បាទ មានតាសាន –ឈ្មោះសាន– បាទ គេហៅបង០៦ បាទ។

**ស៖** ចុះលោកមានស្គាល់ម្នាក់ឈ្មោះ តារ៉ុង ទេ?

**ឆ៖** បាទ ស្គាល់តារ៉ុង បាទ ខ្ញុំបាទស្គាល់ដែរ តារ៉ុង។

**ស៖** តើពេលនោះគាត់ធ្វើអ្វីដែរ ហើយគាត់នៅមានអ្វីកើតឡើងចំពោះ តារ៉ុង ហ្នឹងដែរទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ។

**លោក សុន វុត៖**

**ឆ៖** គេចាប់សម័យដែលថាក្បត់ដែរ តារ៉ុង បាទ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** តើព្រឹត្តិការឬណ៍ដែលកើតឡើងចំពោះតារ៉ុង ហ្នឹងក្នុងពេលណា? ក្នុងពេលជាមួយតាសាយ -- តាសយ ឬក៏ តាឈិន ហ្នឹងជាមួយគ្នា ឬក៏កើតឡើងពេលផ្សេងគ្នា?

**ឆ៖** បាទ ផ្សេង មុនក្រោយ បាទ។ ចាប់ទៅក្រោយ បាទ។

**ស៖** បាទ ព្រឹត្តិការណ៍ដែលលោកបាននិយាយហ្នឹងគឺ តើព្រឹត្តិការណ៍ដែលកើតឡើងចំពោះការពួកគាត់ទាំងបីនាក់ហ្នឹងយ៉ាងម៉េច គាត់មានបញ្ហាអីបន្ទាយមានជ័យ -- នៅមណ្ឌលគិរីហ្នឹងតែម្តង ឬក៏ថាមានគេធ្វើយ៉ាងម៉េចជាមួយពួកគាត់ហ្នឹង នៅពេលដែលគាត់បាត់ខ្លួន?

**ឆ៖** គេហៅមករៀន ថាមករៀននៅភ្នំពេញ ក៏មកក៏បាត់ទៅ ប៉ុន្តែដឹងដំណឹងគេថាក្បត់អង្គការ ខ្ញុំក៏មិនដឹងដែរបាទ។

[១៤:២៩:៣៤]

**ស៖** បាទ សូមអរគុណ។ នៅពេលដែលគេ -- ពួកគាត់បាត់ខ្លួន អ្នកដែលមកជំនួសគាត់-- អម្បាញ់មិញលោកបានមានប្រសាសន៍ថាមាន តាសន ហើយនិងមានអ្នកផ្សេងទៀត។ អ៊ីចឹងថា ពួកអ្នកដែលមកជំនួស មកកាន់កាប់៩២០ហ្នឹង មកពីខាងណា ហើយលោកអាចស្គាល់ឈ្មោះពួកគាត់ទេ ហើយពួកគាត់ប្រហែលជាប៉ុន្មាននាក់មកកាន់កាប់៩២០ហ្នឹង?

**ឆ៖** បាទ ដែលមកកាន់កាប់ក្តាប់នៅ៩២០ នេះ គឺមាន តាសាន១ តាឡឺយ បាទ។ ហើយបន្តមកទៀត មានខាងក្រោមគឺមាន មិត្តសារឿន។ សារឿនតូចទេ មិនមែនមិត្តសារឿន កងពលទេ សារឿនកាន់អនុសេនាធំបាទ ហើយនិង មិត្តឡី១ បាទ យូរទៅចង់ភ្លេចឈ្មោះគេបាត់ ហើយនិង មិត្តម៉េន១ អាហ្នឹងវរសេនាតូច គេមកកាន់កាប់។ កងធំ និងវរសេនាតូច។ ខ្ញុំចំណាំបានតែប៉ុណ្ណោះ ដឹងដែលឃើញដែលបានជួប បានដឹង។

**ស៖** ចុះលោកអាចបញ្ជាក់បានទេ តើមន្ទីរសន្តិសុខដែលនៅភ្នំក្រោលហ្នឹង ថាតើនៅចំណុះឲ្យផ្នែកអង្គភាពណានៅខាងកងទ័ពហ្នឹង?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយលោកដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញលោកស្រី អង់តា ហ្គិសសេ។

**កញ្ញា អង់តា ហ្គិសសេ៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងសំណួរចុងក្រោយនេះ ពីព្រោះថា គាត់បានលើកឡើងអំពីឈ្មោះមួយដែលសាក្សីមិនបាននិយាយទាល់តែសោះ ហើយឈ្មោះនៃមន្ទីរសន្តិសុខហ្នឹង ក៏មិនមាននៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ដែរ។ អ៊ីចឹងសុំកុំបញ្ចុកព័ត៌មានទៅដល់មាត់សាក្សី ហើយឲ្យគាត់ឆ្លើយតាមនោះ។ អ៊ីចឹងខ្ញុំសូមជំទាស់ទៅនឹងការសួរសំណួរបែបនេះ។

[១៤:៣២:០៨]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ ខ្ញុំនឹងធ្វើសំណួរខ្ញុំសាជាថ្មី។ អម្បាញ់មិញលោកបានមានប្រសាសន៍ថា អ្នកដែលចាប់ខ្លួនលោកគឺជាមនុស្សដែលធ្លាប់ជាកូនចៅរបស់លោក។ ចាតើ ខ្ញុំចង់សួរថា នៅពេលដែលគាត់នៅក្នុងអង្គភាពមួយដែលគាត់ -- ជាមន្ទីរសន្តិសុខមួយដែលលោកត្រូវបានឃុំខ្លួននៅក្នុងនោះ។ តើលោកអាចបញ្ជាក់បានទេ មន្ទីរសន្តិសុខដែលលោកត្រូវបានគេឃុំខ្លួនហ្នឹង តើមន្ទីរសន្តិសុខហ្នឹង ស្ថិតនៅខាងក្រោមអង្គភាពណា?

**លោក សុន វុត៖**

**ឆ៖** បាទ មន្ទីរសន្តិសុខនោះក៏មានស្ថិតនៅឯណា មានតែនៅកន្លែងក្នុងកងពលនោះឯងបាទ មន្ទីរសន្តិសុខនោះមាននៅឯណា មានតែកន្លែងកងពល៩២០ នោះឯងដែលគេក្តោបក្តាប់ថ្មីនោះបាទ។

**ស៖** ខ្ញុំចង់សួរបញ្ជាក់លោកបន្តិចអំពីរចនាសម្ព័ន្ធនៃកងពលនោះ ដោយសារលោកស្ថិតនៅជាយោធានៅក្នុងកងពលនោះ ថាតើលោកអាចបញ្ជាក់បានទេនៅក្នុងកងពលនោះ គេបែងចែកជារចនាសម្ព័ន្ធអ្វីខ្លះ លោកអាចបញ្ជាក់បានទេ នៅពេលដែល -- មុនពេលដែលលោកត្រូវបានចាប់ខ្លួន?

**ឆ៖** បាទ គេរៀបចំរចនាសម្ព័ន្ធ ខ្ញុំក៏មិនសូវបានដឹងដែរ មិនដឹងថា គេដាក់ធ្វើរបៀបម៉េចៗ ទៅទៀត ខ្ញុំក៏មិនសូវដឹងដែរបាទ។ ខ្ញុំគេចាប់បាត់ ខ្ញុំអត់ដឹង គេរៀបចំក្រោយ មិនដឹងរបៀបម៉េច ខ្ញុំអត់ដឹង។

**ស៖** ប្រហែលជាសំណួរខ្ញុំមិនច្បាស់។ នៅមុនពេលដែលលោកត្រូវបានគេចាប់ខ្លួន តើកងពល ៩២០ ហ្នឹងមានរចនាសម្ព័ន្ធយ៉ាងដូចម្តេចខ្លះ? គេចែកចេញជាវរសេនាធំ ឬក៏ថា ជាអីសូមលោកមានប្រសាសន៍បន្តិច?

**ឆ៖** រៀបរចនាសម្ព័ន្ធនោះគេរៀបចំចាត់តាំងកងពលចាស់ដដែល គេរៀបចំរចនាសម្ព័ន្ធដដែល។

**ស៖** នៅក្នុងកងពល កាលដែលលោកនៅ កងពលនោះបែងចែកចេញជាប៉ុន្មានវរសេនាធំ? ហើយមានវរសេនាធំអ្វីខ្លះ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ មានបីវរសេនាធំបាទ មាន៩១ – វរសេនាធំ៩១, ៩២, ៩៣ បាទ។

[១៤:៣៥:១៣]

**ស៖** ហើយលោកនៅក្នុងវរសេនាធំណាដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

---

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

កុំទាន់! កុំអាលទាន់!

**លោក សុន វុត៖**

**ឆ៖** បាទ ខ្ញុំនៅចំណុះកន្លែងកងពលនេះឯងបាទ កាន់ប្រធាន"គ" គេឲ្យកាន់ប្រធាន"គ" កង -- នៅកន្លែងកងពល។ អនុសេនាធំបាទៗ ហើយពេលខ្ញុំ គឺខ្ញុំក៏មិនសូវបាននៅជាប់ដែរកន្លែងកងពល គាត់ច្រើនឲ្យទៅធ្វើការតាមព្រំដែនបាទ។ នាំកងទ័ពទៅការពារព្រំដែនផង ចាក់ចម្រូង ដាក់មីន ដាក់ខ្នារ បាទ ធ្វើការសកម្មភាពតាមព្រំដែនបាទ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ អរគុណ។ ខ្ញុំចង់សួរកន្លែងហ្នឹងតែខ្លីទេ។ នៅព្រំដែនថាតើលោកធ្លាប់មានការវាយគ្នានៅព្រំដែនដែរទេ?

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់!

**លោក សុន វុត៖**

**ឆ៖** បាទ អង្កាល់ទៅសម័យឆ្នាំ៧៥ មុនដំបូង គឺបានចាប់ដៃជាមួយកងទ័ពវៀតណាមបាទ ធ្វើការកាលនោះបានដើរធ្វើការតាមព្រំដែន អត់មានបញ្ហាប្រទូសរ៉ាយជាមួយគ្នាទេ។ រឿងកាលសម័យឆ្នាំ៧៥ រហូតចូលដើមឆ្នាំ៧៦ គឺវាអាចមានបញ្ហាបន្តិចៗ ប៉ុន្តែវាមិនទាន់មានបញ្ហាខ្លាំងទេ។ ក្រោយមកទៀត ដើមឆ្នាំ៧៧ មានប្រទូសរ៉ាយគ្នា។ បាទ នេះបានដាក់ផែនការដាក់វាថា ដីគេនៅឯកោះញែកណាទៀត ជិតកោះញែក ហើយពួកខ្ញុំក៏ថា "អេ្ហ! ដីឯងអីណាកោះញែកទៀត។ ដីខ្ញុំនេះ ត្រឹមព្រំអូរ ព្រំដែនគឺអូរដាក់ដាំនេះ ជាសម្គាល់ផែនទីអូរដាក់ដាំរហូតនេះទៅទល់ រហូតខ្ញុំថាដឹងអីចឹង"។ គេថា "អត់ទេរបស់ខ្ញុំនៅខាងនោះទៀត គេថានៅនោះទៀត ប្រហែលជា៤គីឡូទៅទៀត"។ ទៅក៏ទាស់គ្នា ដែលអង្គការវាយការណ៍មកមេ គឺមេដែលសុខចិត្តទេ គាត់អត់សុខចិត្តទេ។ ហ្នឹងធ្លាប់ចាប់ដៃនៅត្រពាំងឈ្យូកបាទ។ មកម្តងប្រាំពីរនាក់ យើងប្រាំមួយ ប្រាំពីរនាក់ដូចគ្នាដែរ នៅដល់ក៏ត្រពាំងឈ្យូកនុំងមានទឹកអីស្រួលបួលដែរ ម្តប់ជួបគ្នាបាទ។ ដល់នេះ នៅឆ្នាំ៧៧ ហ្នឹងឯងបាទ។ ដល់នេះអង្គការគេប្តេជ្ញាឲ្យវ៉ៃ ឲ្យកម្ទេចហើយពួកខ្ញុំនេះឯងទៅត្រៀមចាំមុនបាទ។ ចាំមុនក៏កម្ទេចមែន។ ត្រៀមចាំមុនពួកវាមកប្រាំពីរនាក់ បាទ

ទៅក៏បានត្រៀមបាញ់គេមុន។ កាលនោះក៏ទាស់គ្នារហូតបាទ។ ទំនាស់គ្នាជាយដែនរហូត។ ឃើញមុខគ្នាគេវាក់ គេបានបាញ់មុនក៏បាញ់មុនទៅ យើងឃើញក្រោយ បាញ់ក្រោយបាទ។

[១៤:៣៨:០៤]

**ស៖** ខ្ញុំនៅពេលតិចតួចទេ ខ្ញុំចង់សួរបញ្ជាក់ចំណុចមួយចំនួន។ នៅក្នុងឯកសាររបស់លោកដែលមានលេខ E3/6760a នៅក្នុងទំព័រ១ដំបូងហ្នឹង ដូចគ្នា នៅក្នុងជាភាសាទាំងបីនុំង គឺទំព័រដំបូងដូចគ្នា គឺលោកបានប្រើពាក្យថា "បញ្ជូនខ្ញុំយកទៅដាក់មន្ទីរសន្តិសុខពិសេសក្បែរជើងភ្នំមួយដែលជាប់ដៃអូរល្ពៅស្ថិតក្នុងស្រុកកោះញែក"។ លោកអាចបញ្ជាក់បានទេ អម្បាញ់មិញខ្ញុំឮលោកបាននិយាយឆ្លើយទៅនឹងសហការីរបស់ខ្ញុំថាអូរច្បារ ថាតើកន្លែង -- លោកអាចបញ្ជាក់មើលថាតើវាជាអូរ អូរហ្នឹងឈ្មោះអី? ហើយអូរល្ពៅហ្នឹងជាកន្លែងណា លោកអាចបានទេ?

**ឆ៖** បាទ ខ្ញុំបញ្ជាក់ដែលខ្ញុំនិយាយទៅច្រឡំ។ ខ្ញុំច្រឡំអូរបាទ។ អត់មានល្ពៅទេ បាទ។ អូរច្បារបាទ។ អូរច្បារដែលគេដាក់ឃុំឃាំង ខ្ញុំជិតអូរច្បារដែរបាទ។ ខ្ញុំច្រឡំថាអូរល្ពៅបាទ។ អូរច្បារ។ ដល់យូរពេកទៅ ខ្ញុំវាភ្លេចភ្លាំងខ្លះ មិនបានចាំពីអូរ ថាអូរល្ពៅ -- អូរច្បារបាទ អូរច្បារ។

**ស៖** ខ្ញុំចង់បញ្ជាក់មួយទៀតផងដែរ នៅក្នុងឯកសារដដែលនោះ អំពីបញ្ហាដែលរៀបការដោយបង្ខំ ថាតើលោកត្រូវបានគេបង្ខំឲ្យរៀបការដែរឬទេ ហើយតើការបង្ខំនេះបានសម្រេចដែរឬទេ?

**ឆ៖** បាទ អង្កាល់នោះគឺអង្គការឲ្យរៀបការអ្នកមានន័ ថាមេៗឲ្យរៀបការ ដល់ពេលរៀបការគេឲ្យរៀបការ ប៉ុន្តែខ្ញុំក៏ត្រូវឈ្មោះរៀបការដែរ។ ប៉ុន្តែខ្ញុំចេះតវ៉ានៅអង្គការបាន ផុតពីនោះគេអត់តវ៉ាបានខ្ញុំតវ៉ាបាន បានគេ ថាអង្គការទៅចុះ! វាពីដើមមិញគេថាអង្គការ។ យើងអត់គោរពអង្គការចាត់តាំងយ៉ាងណាគឺត្រូវតាមអង្គការ ប៉ុន្តែខ្ញុំតវ៉ាជាមួយអង្គការបាន។ បាទគាត់អត់បង្ខំខ្ញុំដូចថាវាផុត ខ្ញុំនៅវាងក្មេងផងទៅ ដូចថាគេរៀបឲ្យរបប កាលនោះសម័យគេហៅថា មានរបប គឺគេត្រូវរៀប ដល់គេរៀបអាយុចាប់ពី៣០ណោះ មិនមែនរៀបតែអាយុ២៥, ២៦ បាទទេ។ កាលសម័យនោះគឺចាប់ពី៣០ឡើងបាទ នារីក៏ដូចគ្នាយ៉ាងអន់ក៏២៨ ទៅ ២៩ បានអាចយកគ្រួសារបាន។ បាទខ្ញុំវាងក្មេង ខ្ញុំតវ៉ាជាមួយអង្គការបាន។ គិតថាបើរើចោលក៏រើទៅ នឹកឃើញថាខ្ញុំមិនយក ខ្ញុំថាអ៊ីចេះ "ខ្ញុំនៅក្មេងណាស់ខ្ញុំមិនទាន់ចង់បានទេ"។ ខ្ញុំតវ៉ាអត់បានផុត ខ្ញុំបាទអត់មានត្រូវខ្ញុំបានទេ បានតែគេអ្នកផ្សេងបាទ យកគូមកចាប់ក៏វាខ្លះក៏សមទៅខ្លះមិនសមបាទ កាលជំនាន់នោះ។

[១៤:៤១:៣០]

**ស៖** តើលោកអាចបញ្ជាក់បានទេចំពោះអ្នកផ្សេងៗទៀតដែលបានរៀបការ លោកមានបានដឹងទេថាតើគាត់ហ្នឹងបានរៀបការដោយស្ម័គ្រចិត្តឬទេ អ្នកដែលផ្សេងទៀតដែលបានរៀបការហ្នឹង?

**ឆ៖** បាទ រៀបការហ្នឹងគឺថាគ្មានស្ម័គ្រចិត្តថានឹងស្រលាញ់គ្នាទេ គឺអត់ដឹង បើនិយាយរួមអត់ដឹងតែម្តង គឺថានៅភ្នំពេញមីមួយ មិត្តខ្លះក៏នៅសៀមរាបអីចឹងទៅ វាចាប់មកផ្គូ ដល់ពេលក៏ថា ប៉ុន្មានប្រាំពីរគូចុះក៏យកពីនោះមក ពីនេះមក ក៏ដកបញ្ចូលគ្នាទៅអ្នកណាត្រូវគូណា គូណាក៏មុខទល់គ្នាទៅបាទមានតែប៉ុណ្ណឹងឯង អត់មានការស្រលាញ់អីទេ។

**ស៖** ខ្ញុំៗចង់និយាយអំពីករណីដែលលោកបានឃើញផ្ទាល់នេះ ករណីហ្នឹងកើតឡើងនៅទីកន្លែងណាលោកអាចបញ្ជាក់បានទេ សូមឲ្យចម្លើយឲ្យខ្លី ដោយសារខ្ញុំអត់មានពេលច្រើនទៀតទេ។

**ឆ៖** បាទ នៅកន្លែងកោះញែកហ្នឹងបាទ កន្លែងស្រុកកោះញែកបាទ។

**ស៖** បាទ ចំណុចក្រោយហើយខ្ញុំសួរតែប៉ុន្មានសំណួរខ្លីៗទេ។ អំពីកាលដែលលោកត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំងហើយនោះ រយៈពេលឃុំឃាំង តើរយៈពេលប៉ុន្មានលោកអាចបានបញ្ជាក់បានទេ ពីឆ្នាំណាដល់ឆ្នាំណា?

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ៗ!

**លោក សុន វុត៖**

**ឆ៖** បាទ ខ្ញុំឃុំឃាំងនោះ បើគិតទៅវាយូរគ្រាន់ដែរ ប្រហែលជាចូលពាក់កណ្តាលខែ៧ ប្រហែលជាប្រាំ ប្រាំមួយខែ ប្រាំខែចុះ ជាប់ឃុំឃាំងជាប់ប្រាំមួយខែបាទ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ឆ្នាំណាដែរ ហើយពេលណាលោករួចខ្លួន លោកអាចបញ្ជាក់បានទេ?

**ឆ៖** ៧៧ នេះឯង ដែលខ្ញុំរួចបាទ បានផុតពីគុកដែលខ្ញុំបានរត់រួចបាទ ៧៧បាទ។

**ស៖** លោកមានប្រសាសន៍ថា៧៧ លោកមានអាចដឹងទេនៅពេល រយៈពេលប៉ុន្មានខែដែលលោករត់រួចខ្លួន ហើយបានមានវៀតណាមវាយចូលមក? អីចឹងចន្លោះពេលដែលលោករួចខ្លួនហើយនិងវៀតណាមវាយចូលមកហ្នឹងរយៈពេលប៉ុន្មានខែ?

**ឆ៖** បាទ មើលទៅវា បើគិតទៅវាពីជិតខែ៧ ដល់ខែ៨ វាចូលហៀបនឹង -- ៧៩ យួនចូលបាទ វាស្មើនឹងថាវាបានចូលមួយឆ្នាំ។ បាទ មួយឆ្នាំបានយួនចូល ដែលខ្ញុំនៅព្រៃបាទ។

**សៈ** ខ្ញុំចង់សួរសំណួរមួយទៀត។ នៅពេលដែលអំម្បាញ់មិញលោកឆ្លើយជាមួយលោក ឡោ ជុនធី អំពីថាមានមនុស្សស្រីត្រូវបានគេបង្ខាំងនៅមន្ទីរឃុំឃាំងហ្នឹង។ លោកអាចដឹងទេថា តើគេធ្វើអ្វីខ្លះចំពោះមនុស្សស្រីដែលនៅក្នុងមន្ទីរឃុំឃាំងដែលលោកនៅជិតនោះដែរ?

**ឆៈ** បាទ ខ្ញុំបាទក៏មិនបានដឹងរឿងច្បាស់ រឿងដែលគេធ្វើបាបយ៉ាងម៉េចៗ មូលហេតុម៉េច គឺខ្ញុំមិនអាចដឹងបាទ។ មិនដឹងថាវាទោសយ៉ាងម៉េច គឺខ្ញុំមិនដឹងដែរបាទ។ បានដឹងតែគុក នៅក្នុងគុកបានដឹងតែប៉ុណ្ណឹងបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីនិងប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី និងប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥ នាទី ដល់ម៉ោង ១៥:០៦ នាទី)*

[១៥:០៥:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុនផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះចេញសេចក្តីសម្រេចផ្ទាល់មាត់លើសំណើរសុំរបស់មេធាវីការពារក្តី នួន ជា សូមពន្យារពេលចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីពាក់ព័ន្ធទៅនឹងអង្គហេតុនៃមន្ទីរសន្តិសុខស-២១ នៅក្នុងអំឡុងពេលសវនាការថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ មេធាវីការពារក្តី នួន ជា ដោយមានការគាំទ្រពីមេធាវីការពារក្តី ខៀវ សំផន ផងដែរ នោះ បានស្នើសុំឲ្យអង្គជំនុំជម្រះពន្យារពេលចាប់ផ្តើមសវនាការស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹង

រដ្ឋប្បវេណីពាក់ព័ន្ធនឹងអង្គហេតុនៃមន្ទីរសន្តិសុខស-២១ រហូតដល់សាក្សីទាំងអស់ដែលនៅសេសសល់ពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិសុខភ្នំក្រោល និងអូរកន្សែងបានផ្តល់សក្ខីកម្មរួចរាល់ជាមុនសិន។ ហើយនៅក្នុងករណីណាក៏ដោយ គួររង់ចាំរហូតដល់ក្រោយថ្ងៃឈប់សម្រាកបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដើម្បីអាចឲ្យមេធាវីការពារក្តីមានពេលវេលាបន្ថែមក្នុងការត្រៀមរៀបចំសម្រាប់អង្គហេតុមន្ទីរសន្តិសុខស-២១ និងការបោសសម្អាតផ្ទៃក្នុង។ មេធាវីការពារក្តីអះអាងថា ការស្តាប់សក្ខីកម្មសាក្សីឆ្លាស់គ្នាចំពោះមន្ទីរសន្តិសុខផ្សេងៗគ្នាបាននាំឲ្យមានការលំបាកចំពោះការត្រៀមរៀបចំ ហើយថាអង្គហេតុស្តីពីមន្ទីរសន្តិសុខស-២១ និងការបោសសម្អាតផ្ទៃក្នុងមានសារៈសំខាន់យ៉ាងខ្លាំងចំពោះការការពារខ្លួនរបស់ជនជាប់ចោទ។ ការជ្រើសរើសម្យ៉ាងទៀត -- ជាការជ្រើសរើសម្យ៉ាងទៀត មេធាវីការពារក្តីស្នើឡើងថាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនអាចផ្តល់សក្ខីកម្មក្នុងសវនាការស្តីពីការថ្លែងទុក្ខសោក និងស្ថានភាពព្យសនកម្មដែលកម្រិតត្រឹមតែមន្ទីរសន្តិសុខភ្នំក្រោល និងអូរកន្សែងបាន មុនថ្ងៃឈប់សម្រាកបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ។

[១៥:០៨:០៣]

សហព្រះរាជអាជ្ញាដោយមានការគាំទ្រពីសហមេធាវីនាំមុខផងដែរនោះ ពុំបានជំទាស់ចំពោះការបញ្ចប់សក្ខីកម្មសាក្សីមន្ទីរសន្តិសុខភ្នំក្រោល និងអូរកន្សែងជាមុនសិន មុនពេលចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីនៃមន្ទីរសន្តិសុខស-២១ឡើយ។ ទោះបីជាយ៉ាងនេះក៏ដោយ សហព្រះរាជអាជ្ញានិងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា មិនគួរឲ្យមានការខាតបង់ថ្ងៃសវនាការនោះទេ ហើយថាគួរតែមានការស្តាប់សក្ខីកម្មសាក្សីនៅមន្ទីរសន្តិសុខស-២១ ប្រសិនបើចាំបាច់ដើម្បីបញ្ចៀសនូវការអាក់ខានសវនាការ។ ចំពោះហេតុផលដែលបានលើកឡើងដោយមេធាវីការពារក្តី អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំដោយផ្អែកលើករណីពិសេស ហើយអង្គជំនុំជម្រះនឹងមិនចាប់ផ្តើមសវនាការស្តាប់សក្ខី-កម្មសាក្សីដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងមន្ទីរសន្តិសុខស-២១ឡើយ រហូតដល់ក្រោយថ្ងៃឈប់សម្រាកថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។ ហើយអង្គជំនុំជម្រះកត់សម្គាល់ថាយ៉ាងច្រើនមានសាក្សីចំនួនពីររូបប៉ុណ្ណោះដែលត្រូវផ្តល់សក្ខីកម្មនៅក្នុងសប្តាហ៍ក្រោយនេះ ហើយអង្គជំនុំជម្រះយល់ឃើញថាថ្ងៃដែលនៅសេសសល់ទាំងប៉ុន្មានដែលអង្គជំនុំជម្រះមិនធ្វើសវនាការនោះគឺនឹងផ្តល់ឲ្យមេធាវីការពារក្តីនូវពេលវេលាបន្ថែមក្នុងការត្រៀមរៀបចំខ្លួន និងពិនិត្យលើការដាក់បង្ហាញឯកសារនាពេលថ្មីៗនេះរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលជាប្រភេទឯកសារដោះបន្ទុក ឯកសារ E319/43 ហើយអង្គជំនុំជម្រះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នឹងផ្តល់នូវព័ត៌មានបន្ថែមអំពីកាលបរិច្ឆេទសវនាការនៅពេលដែលអង្គជំនុំជម្រះទទួលបានការជូនដំណឹងពីពេលវេលាដែលសាក្សីពាក់ព័ន្ធអាចមកផ្តល់សក្ខីកម្មបាន។

បាទ តទៅនេះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសសួរដេញដោលចំពោះអ្នក -- ចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំឈ្មោះ ឌេល លីសាក់--

**ចៅក្រម ក្ងុឌា ហ្វេនស៍៖**

លោកអត់បាន--

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំនឹងសួរសំណួរខ្លះៗនៅរសៀលនេះ ក្នុងនាមឱ្យការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំចង់ត្រឡប់ទៅនិយាយអំពីពេលវេលាដែលលោកមកទទួលការហ្វឹកហ្វឺនផ្នែកខាងយោធានៅក្បែរភ្នំពេញនេះ តើអ្នកណាជាអ្នកបង្ហាត់បង្រៀនយុទ្ធសាស្ត្រផ្នែកយោធាមកលើលោកហ្នឹង? ហើយតើលោកមានបានចូលរួមវគ្គរៀនសូត្រនយោបាយអីជាមួយ សុន សេន ដែរទេ នៅពេលដែលលោកមករៀននៅភ្នំពេញ?

**លោក សុន វុត៖**

**ឆ៖** បាទ ដែលបានមករៀនភ្នំពេញនេះ គឺខ្ញុំមិនបានចាំឈ្មោះបានទេ ប៉ុន្តែ តាសុន សេន គាត់មកប្រហែលជាកន្លះខែអី ឬពីរអាទិត្យអីគាត់មកម្តងបាទ។

**ស៖** ខ្ញុំចង់សួរលោកនូវអ្វីដែលលោកបានឆ្លើយនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺឯកសារ E3/6760 លោកបានរៀបរាប់អំពីការណែនាំពី សុន សេន ហើយនិងការហ្វឹកហ្វឺនផ្នែកខាងយោធា។ លោកថា "ខ្ញុំខិតខំប្រឹងប្រែងដើម្បីទទួលជោគជ័យក្នុងការហ្វឹកហ្វឺននេះ។ <ពីព្រោះខ្ញុំមានអារម្មណ៍ថា> បើសិនណាជាខ្ញុំមិនប្រឹងប្រែងដើម្បីទទួលបានជោគជ័យនេះទេ ខ្ញុំ<អាច>នឹងត្រូវ<> បានគេសម្លាប់ចោលហើយ"។ ហេតុអ្វីបានជាលោកឆ្លើយថា លោកមានការភ័យខ្លាចគេសម្លាប់លោកចោល បើសិនណាជាលោកមិនបំពេញនូវវគ្គរៀនសូត្រនេះ ប្រឹងប្រែងរៀនសូត្រនេះឱ្យបានជោគជ័យទេ?

01239208





**ឆៈ** បាទ ខ្ញុំដែលការត្រង់ខ្លាច ខ្ញុំនឹកឃើញថា យើងមិនគោរព យើងមិនអនុវត្តទៅតាមផែនការផ្នែកយោធា ថាយើងនោះមិនស្រលាញ់អង្គការ ឬយើងក្បត់ពីអង្គការ យើងមិនយកចិត្តទុកដាក់ជាកងទ័ព ត្រូវយកចិត្តទុកដាក់ ហើយយើងត្រូវយកទៅការពារប្រទេសជាតិយើង បាទ។

[១៥:១២:៥៦]

**សៈ** ឥឡូវនេះ ខ្ញុំចង់ចូលទៅនិយាយអំឡុងពេលដែលលោកនៅឯមណ្ឌលគិរីជាមួយកងពល៩២០។ គេបានសួរលោកអំពីអង្គភាពរបស់លោក លោកថា លោកនៅក្នុងកង<អនុ>សេនាធំមួយដែលស្ថិតនៅចំណុះកងពល៩២០ផ្ទាល់តែម្តង។ បើខ្ញុំមិនច្រឡំទេ កងអនុសេនាធំរបស់លោក <មិនមែន>ជាផ្នែក<របស់>វរសេនាធំ ៩១, ៩២, ៩៣<ទេ> ហើយអង្គភាពរបស់លោកនេះ <មិនត្រូវបាន>ចាត់តាំងឲ្យស្ថិតនៅចំណុះវរ<សេនាធំ>ណាមួយដោយផ្ទាល់នោះទេ គឺវរសេនាធំលេខ៩១, ៩២, ៩៣ <តើត្រឹមត្រូវទេ>?

**ឆៈ** បាទ ខ្ញុំដែលនៅជាមួយចំណុះកងពលអ៊ីចឹង គឺអត់សំខាន់រឿងនៅជាមួយវរសេនាធំណាទេ គឺខ្ញុំដើរចល័តបានគ្រប់វរសេនាធំបាទ ទាំងបីវរសេនាធំ។

**សៈ** សុំទោស ដោយសារតែឥឡូវនេះ ខ្ញុំបានដាក់បញ្ចូលថ្មវិញហើយ ហើយស្តាប់ឮច្បាស់វិញហើយ។ នៅក្នុងកងអនុសេនាធំនេះ តើលោក<ធ្វើការ>នៅ<កន្លែងណា? តើលោកធ្វើការនៅមន្ទីរកងពល ដូចមន្ទីរកងពល>ដែល តាឈិន <>ធ្វើការ<>ហ្នឹង ឬក៏យ៉ាងណា? <បើមិនដូច្នោះទេ> តើគេចាត់តាំងលោកទៅ<>កន្លែងណាដែរ?

**ឆៈ** បាទ ដែលខ្ញុំរស់នៅគឺនៅជាមួយគាត់តែម្តង កន្លែងកងពលដែរបាទ។ ប៉ុន្តែពេលនេះ គាត់ឲ្យទៅធ្វើការនៅជាយដែន ចុះជាប់នៅតាមអង្គភាព តាមមុខសញ្ញាដែលតាមព្រំដែននិងវៀតណាមបាទ អូរពុល អូរដាក់ដាំ បាទៗ ឲ្យខ្ញុំដើរធ្វើការគ្រប់កន្លែង។ ជួនណាទៅកន្លែងនេះមួយអាទិត្យទៅ ខ្ញុំដកទៅ ហើយនាំទាហានបិតចម្រូង ចាក់ចម្រូង ជីកអន្លង់ ការពារព្រំដែន រហូតគ្រប់កន្លែង ខ្ញុំដើរធ្វើការបានបីចំណុច បាទ ដែលអង្គការប្រគល់ឲ្យ។

**សៈ** សូមអរគុណ។ តើមន្ទីរនៃកងពល៩២០ ដែល តាឈិន គាត់ទៅធ្វើការហ្នឹងនៅកន្លែងណាដែរមន្ទីរនុ៎ង?

**ឆៈ** បាទ នៅនឹងកោះញែកហ្នឹងឯង បាទ។

**សៈ** ខ្ញុំដឹងហើយថា លោកបានចំណាយពេលវេលាភាគច្រើនធ្វើការនៅតាមព្រំដែន។ ក៏ប៉ុន្តែតើ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកមកកាន់មន្ទីររបស់កងពលដែល តាឈិន គាត់ឈរជើងធ្វើការហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បាទ មិនសូវញឹកប៉ុន្មានទេ ជួនណាពីរអាទិត្យ ជួនណាកន្លះខែបាទ ជួនណាមួយខែបានមកម្តង។ គាត់ឲ្យមកបាទ ឲ្យប្រចាំនៅសមរភូមិ។

[១៥:១៦:៤២]

**ស៖** <>តើ<លោកដឹងទេ ថាតើ>មន្ទីររបស់កងពល៩២០ <>នៅកោះញែក<មានទីតាំងនៅកន្លែងណាដែរ?>។ ចុះតើលោកដឹងមន្ទីរតំបន់១០៥នៅកន្លែងណាដែរ គឺមន្ទីររបស់លេខាតំបន់ឈ្មោះឡាំង <ដែលគេហៅថា> ក-១៧ <និងមន្ទីររបស់>ប្រធានសេនាធិការ<យោធាតំបន់តា> សុភា? <> តើលោក<ស្គាល់មនុស្សពីរនាក់នេះទេ ហើយតើលោក>ដឹងថា មន្ទីររបស់<ពួកគេនៅ>កន្លែងណាដែរទេ?

**ឆ៖** បាទ ដែលមន្ទីរនោះគឺ ខ្ញុំមិនសូវច្បាស់ដែរ មន្ទីរ១០៥បាទ ខាង ឡាំង ឡុង បាទ វាមិនមែនខាងជនជាតិទេ ជនជាតិភាគតិចទេ បាទ ខ្ញុំមិនស្គាល់ច្បាស់ដែរ។

**ស៖** តើលោកដឹងថា តាសុភា ជាអ្នកណាដែរទេ? លោកធ្លាប់ដែលឃើញ ធ្លាប់ដែលបានជួបគាត់ទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលបានជួបគាត់ផង តាសុភា បាទ។

**ស៖** លោកបាននិយាយថា លោកត្រូវបានគេឃុំឃាំងខ្លួនអស់មួយរយៈ គេចងមុខលោក។ លោកបានរៀបរាប់ពីកន្លែងដែលគេឃុំខ្លួនលោក។ តើ<ដឹងពី>ទីតាំងដែលគេឃុំលោកនេះ<ទេ? តើទីតាំងនោះនៅកន្លែងណា បើធៀបទៅ>នឹងមន្ទីររបស់ តាឈិន គឺមន្ទីរកងពល៩២០<>? <តើលោកដឹងទេ? តើលោកអាចប្រាប់យើងបានទេ ថាតើ>គុកដែលឃុំឃាំងខ្លួនលោកនេះ <>ស្ថិតនៅកន្លែងណា <បើធៀប>ជាមួយមន្ទីរកងពល៩២០?

**ឆ៖** បាទ ដែលមន្ទីរនេះគឺ ដែលមកពី៨០១ទេដែលរៀបចំកន្លែងគុកនេះ។ បើ តាឈិន គាត់អត់បានរៀបចំទេ កន្លែងគុកដែលខ្ញុំជាប់នេះបាទ ទ័ពមកពី៨០១ ថ្មីដែលគេរៀបចំគុក ក៏ខ្ញុំមិនសូវច្បាស់ដែរបាទ។

**ស៖** ខ្ញុំយល់ហើយ <>ដែល<ថា> តាសាន <បានឡើង>ជាប្រធានកងពល៩២០<នោះ។> គាត់មកពីកងពល៨០១ ក៏ប៉ុន្តែក្រោយមកគាត់ក្លាយទៅជាលេខាកងពល៩២០។ តើខ្ញុំយល់បែបនេះត្រឹមត្រូវទេ?

**ឆ៖** បាទៗៗ យល់ត្រឹមត្រូវ បាទ។ គេដកពី៨០១ មកកាន់នៅកងពល៩២០ បាទ។

**ស៖** ហើយអ្វីដែលខ្ញុំ<>សួរលោកនេះ គឺមន្ទីរដែល តាឈិន ធ្លាប់ធ្វើការ។ ខ្ញុំដឹងថាគេចាប់ខ្លួនគាត់ហើយ ក៏ប៉ុន្តែ<ខ្ញុំចង់ដឹងថាតើ>មន្ទីរដែល តាឈិន ធ្លាប់ធ្វើការនោះ<នៅកន្លែងណា>។ តើគុក<>នៅកន្លែងណាបើធៀបទៅហ្នឹងមន្ទីរ<ចាស់>ដែល តាឈិន ធ្វើការ?

**ឆ៖** ដែលខ្ញុំជាប់គឺនៅខាងត្បូងកន្លែងមន្ទីរបាទ ជាប់អូរច្បារ ជិតអូរច្បារ ជិតអូរច្បារបាទ មានភ្នំជំទើរមួយវាមិនជាភ្នំអីទេ ប៉ុន្តែវាដីរាងខ្ពង់រាបអណ្តើកខ្ពស់បាទ ផ្លូវយើងមកជិតផ្លូវមកក្រចេះនេះឯង ផ្លូវមួយផ្លូវខ្សែខាងកើតផ្លូវបាទ។

[១៥:២១:០៨]

**ស៖** តើលោកចងចាំទេ<គុក>នៅខាងត្បូងនៃមន្ទីរកងពលហ្នឹង<>ចម្ងាយប៉ុន្មាន<ដែរ? តើវាឆ្ងាយប៉ុនណា? តើវានៅ>ជិតឬ<>? <តើលោកអាចប្រាប់យើងដោយប៉ាន់ស្មានចម្ងាយបានទេ?>

**ឆ៖** ប្រហែលជាកន្លះគីឡូបាទ។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី មានប្រយោជន៍ណាស់ចំណុចនេះ។ ឥឡូវនេះខ្ញុំចូលទៅសួរលោកអំពីព្រឹត្តិការណ៍ដែលគេចាប់ខ្លួន តាឈិន និងអ្នកដទៃទៀតមកពីកងពល៩២០។ តើលោកនៅចាំទេ ដំបូងឡើយលោកដឹងអ្វីខ្លះអំពី តាឈិន និងអនុលេខាធិការកងពល តាសយ ក៏ត្រូវបានគេចាប់ខ្លួន<>នោះ លោកដឹងអំពីការចាប់ខ្លួនអ្នកទាំងពីរនេះដែរទេ?

**ឆ៖** បាទ ខ្ញុំក៏មិនដឹងដែរបាទ។ ថាគេចាប់ទៅ ថាគាត់នោះក្បត់ពីអង្គការទៅខ្សែរយៈជាមួយយួន ហើយទៅខ្ញុំដឹងតែប៉ុណ្ណោះឯងបាទ។ ថាវា គេថាស្អប់របបសម័យអង្គការ ថាគេ -- គេថាគាត់ចោទប្រកាន់ថាគាត់ក្បត់ ប៉ុន្តែខ្ញុំមិនដឹងថារឿងគាត់ក្បត់មែនក៏មិនដឹង ខ្ញុំមិនដឹងដែរ ខ្ញុំខាងក្រោមដូចថាមិនទាន់ គាត់មិនទាន់បានប្រាប់ថា ហ៎! មិត្តឯងអីចេះៗ ទៅក្បត់តាមខ្ញុំអីចេះចុះ ចូលទៅយួនវើអង្គការវិញ ឮម៉េចៗ គឺខ្ញុំមិនដឹងដែរ ខ្ញុំអត់ដែលឮគាត់និយាយ មិនបានដឹងរឿងអីបន្តិចសោះ អត់ដែលសោះខ្ញុំ។ ឬគាត់ចោទប្រកាន់គាត់ក៏មិនដឹង ខ្ញុំក៏មិនដឹងដែរ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ តើមានរយៈពេលប៉ុន្មាន<ក្រោយ>ពេលគេចាប់ តាឈិន និង តាសយ ហើយ<គេ>ចាប់ខ្លួន<>លោក<នោះ? តើ>រយៈពេលប៉ុន្មាន<>ខែ<ឬរយៈពេលប៉ុន្មាន ក្រោយការចាប់ខ្លួនអ្នកទាំងពីរនេះ ដែលគេចាប់ខ្លួនលោកនោះ>?

**ឆ៖** បាទ ដែលចាប់នោះ ដូចចំនួនមួយខែ រយៈឆ្ងាយចំនួនមួយខែ មកដល់រូបខ្ញុំខាងក្រោមបាទ។

[១៥:២៣:៥៥]

**ស៖** ក្នុងអំឡុងពេលនោះ តើលោកបានដឹងថាមានគេចាប់កងទ័ព កងពល៩២០ ណាខ្លះដែរទេ? គិតពីចន្លោះពេលដែលគេចាប់ខ្លួន តាឈិន និងគេចាប់ខ្លួនលោក? តើ<លោកចាំទេថា តើ>នៅក្នុងចន្លោះពេលនេះ <ក៏>មានគេចាប់<អ្នកផ្សេងទៀត>ដែរ<>?

**ឆ៖** បាទ ដឹងបាទ។ មានចាប់ កាលនោះក៏ចាប់ មិត្តកុល, ហើយមិត្តណុន, ហើយមិត្តនែ៎ -- ភ្លេចឈ្មោះបាត់ យ៉េង មិត្តយ៉េងបាទ ខ្ញុំដឹងបាទ អ្នកចាប់បន្តៗមកទៀតបាទ។

**ស៖** <មនុស្ស>បីនាក់ដែលលោកទើបតែរៀបរាប់ឈ្មោះ មិត្តកុល, មិត្តណុន, មិត្តយ៉េង តើមិត្តទាំងបីនាក់នេះមានតួនាទីអ្វីដែរ? <តើពួកគេធ្វើការនៅកន្លែងណា?>

**ឆ៖** បាទ មិត្តកុល គឺវរសេនាតូច, មិត្តណុន កងអនុសេនាធំ, មិត្តយ៉េង គឺកងអនុសេនាធំ។ អស់។

**ស៖** ដើម្បីជួយ<លោកឱ្យ>បញ្ជាក់អំពីពេលវេលាដែលគេចាប់ខ្លួនលោកនេះ<> យើងមានកំណត់ត្រាពីមន្ទីរសន្តិសុខស-២១ ដែលបញ្ជាក់ថានៅពេលណាដែល តាឈិន និង តាសយ ត្រូវបានគេចាប់ខ្លួន។ លោកប្រធានគឺឯកសារ E3/342 គឺជាបញ្ជីអ្នកទោស<ស-២១ ដែលពិនិត្យដោយការិយាល័យសហព្រះរាជអាជ្ញា។ បញ្ជីនេះ>បញ្ជាក់ថាលេខាកងពល៩២០ ឈ្មោះ ម៉ែន ម៉េង ហៅ ឈិន បានចូលមក ស-២១ នៅថ្ងៃទី១៦ មីនា ឆ្នាំ៧៧ គាត់នៅលេខរៀងលេខ៥១១៨ ហើយ<អនុលេខាឈ្មោះ អ៊ាជឺ> ហៅ សយ <បាន>ចូលមក ស-២១ ថ្ងៃទី១៧ <កុម្ភៈ> ឆ្នាំ១៩៧៧។ គាត់នៅលេខរៀង១៩៦៦ នៃបញ្ជីអ្នកទោសនេះ។ ដូច្នេះ លេខានិងអនុលេខាកងពលត្រូវបានចាប់ខ្លួននៅម្តុំខែ<កុម្ភៈ ឬខែ>មីនា <> ឆ្នាំ៧៧។ តើលោកគិតថា គេចាប់ខ្លួន<លោក>នៅម្តុំខែមេសា <ឆ្នាំ១៩៧៧ទេ?> តើការចាប់ខ្លួនហ្នឹងគេចាប់ខ្លួននៅរដូវវស្សាឬ? <តើទាំងអស់នេះអាចជួយលោកឱ្យប្រាប់យើងអំពីការប៉ាន់ស្មានពេលវេលាជាក់លាក់ណាមួយបានទេ ឬក៏ថាវារំឭកឱ្យលោកនឹកឃើញឡើងវិញ ថាតើ>គេចាប់ខ្លួនលោក<នៅខែណាដែរ>?

[១៥:២៦:៣៧]

**ឆ៖** បាទ ដែលចាប់នោះក៏នៅក្នុងខែកត្តិក។ ខែកត្តិក ខែច្រូត មិនទាន់ស្រូវទុំអស់ទេ អង្កាល់ខែនោះវានៅបាទ។

**ស៖** តើវានៅក្នុងខែណានៃរដូវចម្រូតហ្នឹង <នៅកន្លែងដែលលោកនៅនោះ>?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ឆ៖** ១១ ខែ១១ៗ ទៅខែ១២ ដែលត្រូវច្រូត ចម្រូត។

**ស៖** ដូច្នេះ តើខ្ញុំយល់ត្រឹមត្រូវដែរទេថា វាអាចមានរយៈពេលពីរបីខែក្រោយពេលគេចាប់ខ្លួនតាឈិន ក៏គេចាប់ខ្លួនលោក។ អ៊ីចឹងគេចាប់ខ្លួនលោកនេះគឺថា ចាប់នៅដំណាច់ឆ្នាំហើយ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទៗ ត្រឹមត្រូវបាទ។

**ស៖** លោកបានបញ្ជាក់ និងរៀបរាប់អំពីមនុស្សបីនាក់ដែលមកចាប់ខ្លួនលោក ភ្ជង់អាវុធមកលើរូបលោក។ តើលោកស្គាល់ថាអ្នកទាំងបីនាក់ដែលមកចាប់ខ្លួនលោកនេះជាអ្នកណាដែរទេ?

**ឆ៖** បាទ ស្គាល់។ រឿងមកចាប់ខ្ញុំគឺឈ្មោះ មិត្តផេងៗ ហើយនិងមិត្តបៃ ហើយនិងមិត្តសយ។ សយ គេហៅសាយ ហ្នឹងសមមិត្ត សាយ។ មិត្តសាយ មួយដែលចាប់ខ្ញុំភ្ជង់កាំភ្លើងបីដើម គឺបីរូបនោះ គឺឈ្មោះ មិត្តផេង ហើយនិងសាយ, មិត្តបៃ។ បាទ អស់។

[១៥:២៩:៤៧]

**ស៖** ពីមុននោះលោកបានបញ្ជាក់ថា ម្នាក់ក្នុងចំណោមអ្នកទាំងបីនាក់ហ្នឹងគឺ សមមិត្តផេង ជាកងទ័ពនៅក្នុងកងពល៩២០។ ចុះសមមិត្តពីរនាក់ទៀត ក៏ជាកងទ័ពនៃកងពល៩២០ដែរទេ មុនបោសសម្អាត ឬក៏អ្នកពីរនាក់ផ្សេងទៀតនេះមកពីកងពល៨០១?

**ឆ៖** បាទ ដែលឲ្យមកចាប់នោះគឺក្នុងកងពល៩២០ចាស់បាទ នៅជុំខ្ញុំនោះឯង ប៉ុន្តែដល់មកពី៨០១ទៅ មេគេបញ្ជាយ៉ាងម៉េចទៅ ក៏ឲ្យមកចាប់ខ្ញុំក៏ មានគេពីរនាក់ដែរ ប៉ុន្តែខ្ញុំអត់ស្គាល់ឈ្មោះទេ ដែលគេបញ្ជាឲ្យកូនចៅ៩២០ចាប់ខ្ញុំបាទ។ បើប្រហែលជាកង មកកាន់កងអនុសេនាធំនោះឯង ដែលគេមកបញ្ជាឲ្យចាប់បាទ មកពី៨០១ ដែលចាប់ខ្ញុំបាទ។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី យើងបានស្តាប់សក្ខីកម្មកន្លងមកថា កម្មាភិបាលកងពល ៩២០ ជួនកាលនោះ គឺជាប់ពាក់ព័ន្ធទៅនឹងការចាប់ខ្លួនកម្មាភិបាលមកពីតំបន់១០៥។ សាក្សីម្នាក់<នៅក្នុងចម្លើយរបស់គាត់ផ្តល់>ជូនមជ្ឈមណ្ឌលឯកសារកម្ពុជាដូចតទៅ គឺឯកសារ E3/8651 នេះគឺជាកិច្ចសម្ភាសន៍របស់សាក្សីម្នាក់ដែលធ្លាប់ធ្វើការនៅមន្ទីក-១១ ជាមន្ទីរកងទ័ព<តំបន់> គឺឯកសារE3/8651, ខ្មែរ 00042261, អង់គ្លេស 01156493 គាត់បានឆ្លើយដូចតទៅ សូមដកស្រង់៖ “នៅពេល<ចាប់ខ្លួន>អ្នក<នៅខាង>កងពល <នោះគេប្រើកម្លាំង>តំបន់ឲ្យចាប់<> ហើយបើសិន<គេចាប់ខ្លួន>អ្នកតំបន់<នោះ>គេប្រើកម្លាំង<>កងពល<ជាអ្នក>ចាប់<>”។ តើលោកដឹងទេថាទោះបីជាកម្មាភិបាល

កងពល៩២០ក្តីដែលត្រូវបានចាត់តាំងឲ្យមកចាប់ខ្លួនកម្មាភិបាលពីតំបន់១០៥ ឬតើលោកដឹងថាមានកម្មាភិបាលណាមកពីតំបន់<ដែលជាប់ពាក់ព័ន្ធនឹងការដឹកនាំ>ការបោសសម្អាតកងទ័ពកងពល៩២០ដែរទេ <បន្ថែមទៅលើអ្នកមកពី>កងពល៨០១<នោះ>?

**ឆ៖** បាទ ដូចត្រង់នោះ គឺខ្ញុំមិនសូវបានយល់ មិនដឹងថាខាងណាផង ប៉ុន្តែដល់ខ្ញុំអត់ដឹងដែររឿងនេះ មិនដឹងថាតំបន់ មិនដឹងថាមកពី៨០១ ប៉ុន្តែគេបញ្ជូនមកក្តោបក្តាប់ពី៨០១មកកាន់កងពល៩២០ ក៏ខ្ញុំដឹង ប៉ុន្តែរឿងដែលថាតំបន់គេមកចាប់មកអី គេបញ្ជា គឺខ្ញុំអត់ដឹងដែរបាទ។ អត់ច្បាស់ ខ្ញុំអត់ដឹង អត់បានចងចាំរឿងត្រង់ចំណុចនោះបាទ។

[១៥:៣៣:៣១]

**ស៖** លោកបានឆ្លើយថា នៅក្នុងករណី តាឈិន ហើយអនុលេខាតំបន់ តាសយ គេហៅទៅ<> រៀនសូត្រនៅភ្នំពេញ។ ចំពោះយោធា កងពលដែលត្រូវបានចាប់ខ្លួនក្នុងការបោសសម្អាតនោះ តើលោក<>បានឮ<ទេ ថាតើគេបញ្ជូនអ្នកទាំងនោះទៅភ្នំពេញដោយរបៀបណា? តើលោកបានឮ> ឬក៏បានដឹង<>អ្វី<ខ្លះអំ>ពីការបញ្ជូន ឬការចាប់ខ្លួនអ្នកទាំងនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំក៏មិនដឹងដែរ ដឹងតែគេចាប់ទៅមិនដឹងថាគាត់របៀបម៉េច គាត់យ៉ាងណា ក៏ខ្ញុំមិនដឹងដែរបាទ ថាតែគេចាប់មកក៏ថាមករៀនមកសូត្រទៅ ដឹងតែប៉ុណ្ណោះឯងបាទ។

**ស៖** ខ្ញុំចង់សួរសំណួរលោកមួយចំនួនអំពីមនុស្សផ្សេងៗទៀតនៅក្នុងកងពល៩២០ ហើយនិងពីបញ្ហាដែលកើតឡើងចំពោះពួកគាត់ឆ្នាំ១៩៧៧។ លោក<បញ្ជាក់ថា មាន>កងវរសេនាធំបី គឺ៩១, ៩២ និង៩៣។ តើលោក<ចាំទេថា អ្នកណាជា>មេបញ្ជាការវរសេនាធំទាំងអស់ហ្នឹង<> ដែលស្ថិតនៅក្រោម តាឈិន<នោះ ហើយថាតើមានអ្វីកើតឡើងចំពោះពួកគេ> នៅក្នុងឆ្នាំ១៩៧៧នោះ?

**ឆ៖** បាទ ខ្ញុំក៏មិនបានស្គាល់អស់ដែរ វរសេនាធំ៩១ ខ្ញុំស្គាល់ ហើយនិង៩២ គឺបានស្គាល់ខ្លះ ប៉ុន្តែវាមិនស្គាល់បានទាំងអស់ ស្គាល់បានតែម្នាក់នៅ៩២ ហើយនិង៩១ វរសេនាធំបាទ។ មានឈ្មោះ យ៉ាត តែមិនដឹងថាគេដាក់ឈ្មោះយ៉ាងម៉េចទេ ប៉ុន្តែ យ៉ាត នៅ៩១។ សឿន នោះនៅ៩២ នៅកាន់វរសេនាធំ។ បាទ បានស្គាល់ប៉ុណ្ណោះឯង ខ្ញុំ។

**ស៖** លោកសាក្សី ខ្ញុំចង់អានជូនលោកស្តាប់នូវឯកសារមួយគឺជាឯកសារនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ លោក លោកស្រីចៅក្រម ឯកសារ E3/1199 បាទគឺ E3/1199។ <>ឯកសារ<នេះលោក>ដើមបណ្តឹងរដ្ឋប្បវេណី <គឺ>ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៧៧។ គឺចេញពី តាសាន ផ្ញើ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៅ សុន សេន ដែលមានរហស្សនាមថាបង៨៩។ វាក្យខណ្ឌទី២នៃសារទូរលេខនេះ តាសាន បានសរសេរដូចខាងក្រោមទៅ សុន សេន "ចំពោះកម្មាភិបាលដែល<>នៅ<សល់ ការផ្លាស់ប្តូរត្រូវបានគេមើលឃើញនៅក្នុងវរសេនាធំលេខ>៩២ ទាក់ទងទៅនឹងសមមិត្តសន ហើយនិងសមមិត្ត<អុន> ជាលេខាវរសេនាតូច នៅពេលដែលកម្មាភិបាល<យើងចុះទៅពង្រឹង>វរសេនាតូចនោះ<បន្ថែមទៀត។> ប៉ុន្តែមិនមានអ្វីខុសពីធម្មតាទេ ទាក់ទងទៅនឹងមហាជន"។ ហើយបន្ទាប់ពីរបាយការណ៍នេះ ពីតាសានទៅ សុន សេន នោះ មានចំណារផ្ទាល់ដៃដែល<សរសេរថា> "<ឲ្យ>ចាប់ខ្លួន<ពួកគេ">។ បុគ្គលនៅទីនេះ នៅវរសេនាធំ៩២ ដែលមានឈ្មោះថា សមមិត្តសន<> តើលោកស្គាល់គាត់<ទេ? តើគាត់>ជាលេខានៃវរសេនាធំ៩២ ដែរឬទេ?

[១៥:៣៨:០៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកសហមេធាវីជាតិមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ដោយសារថា ការអានឈ្មោះជាភាសាខ្មែរ មានការល្អៀងបន្តិច គឺឈ្មោះទី១ ដែលនៅក្នុងចំណុចទី២ ដែលតំណាងសហព្រះរាជអាជ្ញាបានអាន គឺឈ្មោះ សមមិត្តសន និងឈ្មោះ ទី២ សមមិត្តអុន។ សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើលោកសាក្សីស្គាល់ សន និង អុន ដែរឬទេ នៅក្នុងវរសេនាធំ៩២? ក្នុងករណីដែលលោកស្គាល់ តើ<ពួកគេជាអ្នកណា>?

**លោក សុន វុត៖**

**ឆ៖** បាទ ដែលខ្ញុំបានដឹងនោះ គឺឈ្មោះ សឿន ប្រធានបាទ។ ៩២ មាន សឿន –តាសឿនៗ– បាទ។ ឈ្មោះ សឿន ៩២ វរសេនាធំ បាទ។ ដូចមិនមាន សន, សឿន បាទ ស្គាល់ សឿន។ ឈ្មោះ សឿន ប្រហែលច្រឡំឈ្មោះម៉េច ឈ្មោះសឿន បាទ វរសេនាធំ ៩២។

**ស៖** តើគាត់ជាលេខានៃវរសេនាធំ៩២ ឬ?

**ឆ៖** គាត់ប្រធានវរសេនាធំតែម្តង មេតែម្តងបាទ សឿន បាទ ៩២។

**ស៖** អស់លោក លោកស្រី ចៅក្រមដើម្បីកំណត់ត្រាតុលាការ កាលបរិច្ឆេទនៃសារទូរលេខ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែលផ្ញើជូន សុន សេន នោះគឺថ្ងៃទី០៦ មេសា ឆ្នាំ១៩៧៧។ នៅថ្ងៃទី១១ មេសា ឆ្នាំ១៩៧៧ <លេខាវរ-សេនាធំ៩២ ឈ្មោះ ហែម> សន នេះ<>ចូលមកដល់ស-២១ គឺនៅក្នុងបញ្ជីអ្នកទោសដែលត្រូវបានកម្ទេចនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៧ គឺលេខ៣៥ គឺថាឯកសារ <E3/2285> ERN<ជាភាសាខ្មែរ> 00009083 <ដល់ 85>, អង់គ្លេស 00873168<>។ លោកសាក្សី ដឹងដែរឬទេ នៅពេលដែល តាឈិន និង តាសយ បាត់ខ្លួន តើប្រពន្ធៗរបស់គាត់ហើយនិងសាច់ញាតិរបស់គាត់ហ្នឹងមានជួបបញ្ហាអ្វីដែរទេ បន្ទាប់ពីអ្នកទាំងពីរនោះត្រូវបានចាប់ខ្លួន ឬក៏បាត់ខ្លួននោះ?

**ឆ៖** បាទ ខាងប្រពន្ធគាត់ក៏គាត់តាំងតែបាត់ប្តីទៅ វាគាត់បានយំ បានស្រែកដែលថា ប្តីគាត់មិនមានក្បត់ទេពីអង្គការ ម៉េចក៏អង្គការចាប់ប្តីខ្ញុំយកទៅ។ គាត់មានការសោកស្តាយ ប៉ុណ្ណោះហើយបាទ។

[១៥:៤១:៤៣]

**ស៖** តើលោកដឹង<ទេ>ថា ក្រោយមកនៅក្នុងឆ្នាំ១៩៧៧នោះ <>មានអ្វីកើតឡើងចំពោះពួកគេទេ?

**ឆ៖** បាទ ដែលនោះក៏ខ្ញុំមិនបានដឹងដែរ បែកបាក់ មិនដឹងរបៀបគាត់មានការលំបាកម៉េចគឺគាត់យ៉ាងណាៗ គឺខ្ញុំអត់ដឹងដែរ ខ្ញុំនៅតែមុខដែរ មិនទាន់បានមកក្រោយទេកាលនោះ បាទ។

**ស៖** សំណួរមួយចុងក្រោយអំពីប្រពន្ធពួកគាត់។ តើលោកនៅចាំ<ឈ្មោះ>ប្រពន្ធរបស់ តាឈិន ឬក៏ប្រពន្ធរបស់ តាសយ ដែរឬទេ? តើលោក<ស្គាល់ពួកគេទេ? តើលោក>នៅចាំឈ្មោះ<ពួក>គាត់ទេ?

**ឆ៖** បាទ អត់ចាំទេ ខ្ញុំអត់បានចាំទេ កាលនោះប្រពន្ធគាត់ជា មិនដឹងជាឈ្មោះស្អីផងកាលនោះបាទ ហៅច្រើនឈ្មោះផង ខ្ញុំអត់ចាំ។ ខ្លះគេហៅ យេន, ខ្លះគេហៅ សន។ បើខ្ញុំមិនដឹងថាឈ្មោះគាត់យ៉ាងណាមួយ។ វាឮតែឈ្មោះខុសគ្នាប្លែក ចម្លែកផ្សេង បាទ។ កាលខ្ញុំ -- កាលសម័យនោះគឺ ឈ្មោះគេច្រើនតែផ្លាស់ឈ្មោះ។ ថ្មី គេផ្លាស់ឈ្មោះច្រើន អ្នកផ្លាស់បាទ រឿងឈ្មោះ វាមិនមែនឈ្មោះពិតក៏មានដែរបាទ។

**ស៖** ខ្ញុំ ឥឡូវនេះចង់ចូលទៅសំណួរមួយចំនួនអំពីរយៈពេលដែលគេឃុំខ្លួនលោក។ ហើយជាដំបូង សូមលោកបំភ្លឺជូនតុលាការ តើគេឃុំខ្លួនលោកហ្នឹង <>អស់រយៈពេលប្រាំមួយខែ ឬក៏ការឃុំខ្លួនហ្នឹងគឺរយៈពេលមួយឆ្នាំ? យើងមិនច្បាស់អំពីអ្វីដែលលោកបានឆ្លើយពីមុន។ <តើលោកអាចបញ្ជាក់បានទេ បើ>គេចាប់ខ្លួនលោកចុងឆ្នាំ១៩៧៧ តើគេឃុំខ្លួនលោកហ្នឹងរយៈពេលប៉ុន្មាន ប៉ុនណា?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ដែលឃុំខ្លួននោះប្រហែលជាបីខែ បាទបីខែៗ បីខែ ១០ថ្ងៃបាទ ឃុំខ្លួន។

**ស៖** អ្នកទោសផ្សេងៗទៀត នៅពេលដែលគេឃុំខ្លួនលោកនៅទីនោះ តើអ្នកទោសផ្សេងទៀតហ្នឹង<ជានរ>ណា? <តើពួកគេក៏>ជាយោធាមកពីកងពល៩២០<ដែរ> ឬក៏គេចាប់មកពីអង្គភាពណាផ្សេង<>?

**ឆ៖** ក្នុងនោះក៏ខ្ញុំមិនបានដឹងដែរ ព្រោះវានៅក្នុងគុក។ ដែលខ្ញុំចូលទៅ ក៏គេចងមុខទៅ ក៏ខ្ញុំអត់ដឹង ដល់នៅក្នុងគុក ក៏វាមើលមិនស្គាល់ វាបាំងជញ្ជាំង បាំងមួយខណ្ឌៗទៅ អត់មើលគ្នាឃើញទេ។ ស្គាល់តែខ្ញុំដែលនៅជាមួយខ្ញុំ បានខ្ញុំ -- ដែលរួចមកនឹងខ្ញុំ នេះបានខ្ញុំស្គាល់បាទ។

[១៥:៤៥:១៧]

**ស៖** តើលោកនៅចាំមានអ្នកយាមប៉ុន្មាននាក់ទេដែលយាមនៅក្នុងគុកនេះ?

**ឆ៖** អ្នកយាមឃើញមកតែបីនាក់បាទ ជួនណាក៏បួននាក់ ជួនណាក៏បីនាក់ យាមបាទ មិនបានច្រើនទេ។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណីលោកបានរៀបរាប់អំពីទីកន្លែងដែលគេឃុំខ្លួនលោក ហើយខ្ញុំ<ចង់អានឲ្យលោកស្ដាប់នូវ>សេចក្ដីរៀបរាប់ ដែលកម្មាភិបាលជាយោធាតំបន់ដែលធ្វើការនៅភ្នំក្រោល។ លោក លោកស្រីចៅក្រមឯកសារ E3/7705 – E3/7705, ខ្មែរERN 00236724, អង់គ្លេស 00239506, បារាំង00276987។ បាទ គឺកម្មាភិបាល<ធ្វើការនៅ>ភ្នំក្រោល<រៀបរាប់ពីគុកនៅទីនោះ> "គុកនៅភ្នំក្រោលគេធ្វើពីឈើមូលដូចជាទ្រុងជ្រូក ដំបូលប្រក់ស្បូវ<>"។ បាទ ស្ដាប់ការរៀបរាប់នេះ <>លោកដើមបណ្ដឹងរដ្ឋប្បវេណី<តើវា>ដូច<គុក>ដែល<គេឃុំឃាំង>លោក<>នោះដែរឬទេ?

**ឆ៖** ដែលៗ គុកខាងណា--

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិកទ័រ កូប៉េ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនប្រាកដអំពីរបៀប<>រៀបរាប់នេះ <>ជាការរៀបរាប់លម្អិតនោះទេ គឺនិយាយអំពីអគារដែលហាក់ដូចជា អាចជាអគារណាមួយនៅក្នុងតំបន់នោះ។ ខ្ញុំមិនប្រាកដថាហេតុអ្វី<បាន>ជាការរៀបរាប់<អាចជាទម្រង់មួយ ដែលជួយរំឭក>ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីទទួល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្គាល់ថាការរៀបរាប់នេះអំពីគុកនោះនុះ។

[១៥:៤៧:៥៨]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នេះហើយជាគោលបំណងនៃការសួររបស់ខ្ញុំដើម្បីឱ្យឃើញ<នោះ។ ខ្ញុំគិត>ថា <នេះជាការរៀបរាប់សមរម្យច្បាស់លាស់ អំពីអគារមួយ ហើយខ្ញុំគ្រាន់តែចង់ដឹងថា> តើការរៀបរាប់ហ្នឹង <ដូចគ្នានឹងអគារដែលគេឃុំឃាំងគាត់ឬទេ>។ លោកដើមបណ្ដឹងរដ្ឋប្បវេណី បុរសម្នាក់នេះ គឺរៀបរាប់ពីគុកនៅភ្នំក្រោល គាត់ថាគេធ្វើមកពីគល់ឈើ ដូចជា ទ្រុងជ្រូក ដំបូលប្រក់ស្បូវ។ តើការស្ដាប់រៀបរាប់នេះគឺវាស្រដៀង ឬដូចទៅនឹងអគារដែលគេឃុំខ្លួនលោកនៅទីនោះ នៅកាលនោះដែរឬទេ?

**លោក សុន វុត៖**

**ឆ៖** បាទ ដែលឃុំខ្លួនខ្ញុំគឺរបងចម្រឹងៗឈើធំៗបាទ ហើយជីក ហើយចម្លុះគ្នា ហើយតម្រៀបគ្នាគេវើរបារ ប៉ុន្តែស្បូវបាំងមួយកំណាត់ គឺប្រក់ស្លឹកប្រចេងមួយកំណាត់ ដូចខ្ញុំជម្រាបប្រាប់មុនដែរបាទនេះដែលខ្ញុំជាប់នោះណាបាទ។

**ស៖** ហើយលោករៀបរាប់ថាមានអគារមួយចំនួននៅក្នុងគុកនោះ តើមានរបង ឬក៏ជញ្ជាំងហ៊ុមព័ទ្ធអគារទាំងអស់នោះដែរឬទេ? គឺអគារដែលគេឃុំខ្លួនលោកហើយនិងកន្លែងគេសួរចម្លើយ។ <លោកនិយាយថា មានអគារមួយ ដែលគេប្រមូលកងសន្តិសុខដាក់នៅទីនោះ។> តើមានរបងជុំវិញបរិវេណគុកហ្នឹងដែរឬទេ?

**ឆ៖** អត់មានទេរឿងរបងជុំវិញគឺធ្វើធម្មតា ហើយកន្លែងសួរចម្លើយ ក៏កន្លែងខ្ទមសម្រាកចងអង្រឹងដេកចំនួនគ្នាបី បួននាក់តែប៉ុណ្ណឹងទេបាទ។ អត់មានរបងហ៊ុមអគារអីទេ គឺធ្វើនឹងឈើធម្មតា ប្រក់យើងធម្មតា របស់ធ្វើមិនយក ជាយូរ ជាទុកយូរអង្វែងទេតាមខ្ញុំមើលទៅ វាគុកនេះវាដាក់ដើម្បីថា អ្នកណាខុសនេះ ដូចថាមួយភ្លែតៗក៏មិនដឹងដែរ ខ្ញុំក៏មិនដឹងដែររឿងជាប់ ឃើញតែខ្នោះក៏ចូលទៅ ឃើញតែចម្រឹងរបងប៉ុនៗណេះទៅបញ្ឈរជីកនៅដីឡើងក៏បគ្នាដូចយើងសង់របង ជម្រៅជ្រៅវើមេរបារធំៗ មិនឱ្យយើងគាស់បាន។ បើតាមធ្វើនោះមើលទៅមិនមែនជាគុកអីសម្រាប់មួយជីវិតដាក់យូរអង្វែង តាមខ្ញុំមើលទៅវាមិនមែន គ្រាន់តែចាប់ដូចថាបន្ទាន់ ឬមួយម៉េចក៏មិនដឹងដែរ។ ដាក់បណ្ដោះអាសន្នសិនឱ្យតែបានអ្នកទោសអីក៏មិនដឹងដែរ ប៉ុន្តែថាឱ្យធ្វើជាប់ដូចជាណែនណាន់មែនក៏វាអត់មានទៀត។ បើណែនណាន់ ខ្ញុំរើមិនរួចផងទេដឹងតាមើលទៅ។

[១៥:៥០:០០]

**ស៖** តើលោកនៅចាំឬទេថា តើមានអាងទឹកនៅក្នុង<បរិវេណ>គុកហ្នឹងដែរឬទេ?

**ឆ៖** អត់មានទេអាងទឹក មានអូរ។ អូរវាមិនសូវធំទេ អូរតូច ប៉ុន្តែវាទឹក វាមិនងាយដាច់ មានដោយបនៗវា បើខែប្រាំងវាដាច់ វានៅតាមអន្លង់វាបាទ។

**ស៖** តើលោកបានដឹងដែរឬទេនៅពេលដែលលោកធ្វើការនៅ<បរិវេណ>នោះ មុនពេលដែលគេឃុំខ្លួនលោក។ តើលោកស្គាល់ទំនប់មួយដែល<>គេសាងសង់នៅភ្នំក្រោល<ទេ?> តើលោកនៅចាំទេ?

**ឆ៖** បាទ ចាំត្រង់ថាភ្នំក្រោល ប៉ុន្តែខ្ញុំមិនដែលសូវបានទៅដែរភ្នំក្រោល។ ខ្ញុំមិនសូវបានទៅកន្លែងភ្នំក្រោល ខ្ញុំច្រើនតែគេឱ្យទៅនៅប្រចាំការនៅមុខសមរភូមិមុខ។

**ស៖** តើគុកដែលគេឃុំខ្លួនលោកនោះនៅជិតភ្នំក្រោល ឬក៏នៅជិតភ្នំ ឬក៏នៅជិតកូនភ្នំណាមួយ<>?

**ឆ៖** ដែលដាក់ខ្ញុំនោះ គឺនៅខាងត្បូងអត់មានជិតភ្នំក្រោលទេ ត្បូងកន្លែងមន្ទីរកងពល ចម្ងាយប្រហែលជា៥០០ម៉ែត្រពីមន្ទីរកងពល ថាកន្លះគីឡូ ប៉ុន្តែនោះធ្វើដូចថា ខ្ញុំថាធ្វើគុកនេះធ្វើជាមិនមែនធ្វើបានយូរទេ គុកនេះគឺដើម្បីថាបណ្ដោះអាសន្នដាក់ គឺអ្នកមានទោសមួយភ្លែត គេយកវ៉ៃចោលភ្លាមៗក៏ៗមិនដឹងដែរ ខ្ញុំគឺចិត្តខ្លួនខ្ញុំទេ បើគុកវាមិនមែន ធ្វើគុកមួយៗទាល់តែធ្វើយកល្អ បាននេះ បើអត់មានសូវល្អប៉ុន្មានទេ ល្មមថាអាចវាយរងគ្រាន់តែដាក់មួយពេល ឬមួយខែ ពីរ បីខែអីប៉ុណ្ណោះទេ បើតាមមើល ខ្ញុំមើលប្រយោលតាមគុកបាទ។

[១៥:៥៣:៣៣]

**ស៖** សូមអរគុណ។ បាទ នេះជាចម្លើយមានប្រយោជន៍ណាស់លោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំចង់សួរសំណួរមួយចំនួនអំពី<ការ>សួរចម្លើយលោក។ លោកនិយាយអំពីការសួរចម្លើយ ហើយគេប្រើចរន្តអគ្គិសនីឆក់ ហើយនិងគេវាយដំផងដែរ។ តើ<>មានមនុស្សប៉ុន្មាននាក់សួរចម្លើយលោកៗដើមបណ្ដឹងរដ្ឋប្បវេណី?

**ឆ៖** មានគ្នាដែលសួរចម្លើយខ្ញុំជួនណាក៏មានបីនាក់ ជួនណាក៏មានបួននាក់។ សួរចម្លើយគឺមានវាឆក់ ខ្ញុំវាឆក់បានពីរដង។ ឆក់បានពីរដង វាផ្អាកឆក់ៗ ទៅខ្ញុំវាវាងសន្លប់ទៅ វាមិនបានចម្លើយ ដល់មិនបានចម្លើយគេឈប់ឆក់ គេវ៉ៃៗ ម៉ាល្មមអ៊ីចឹងទៅ ម៉ាអន់ ម៉ាឈឺទៅ វាទ្រោមទៅ យើងអាចឆ្លើយបាន។

ប៉ុន្តែខ្ញុំមិនដឹងមានពាក្យអីនឹងឆ្លើយ ខ្ញុំដាច់ពិត ខ្ញុំអត់ឆ្លើយ អត់មានឆ្លើយថាខ្ញុំអ៊ីចេះអ៊ីចុះ គឺអត់មាន ព្រោះខ្ញុំអត់មានមូលហេតុអីហ្នឹងថា ក្បត់ពីអង្គការអន្តាក់អន្តិច។ បាទ ខ្ញុំវានឹកឃើញ វាអន់ចិត្តខ្លួនខ្ញុំ វាតូចចិត្តខ្លួនខ្ញុំ បានខ្ញុំគួរតែឈឺចាប់ដែរ វានឹកឃើញពិចារណាទៅវាខុសរឿង អានេះអត់មានត្រូវរឿងអន្តាក់អន្តិចទេ ចោទប្រកាន់វាអត់មានសម។

**ស៖** តើគេសួរចម្លើយលោកប៉ុន្មានដង? <តើ>មានរយៈពេលប៉ុន្មានថ្ងៃ <និង>ប៉ុន្មានដងដែលគេយកលោកទៅសួរចម្លើយ?

**ឆ៖** បាទ ដែលចាប់ខ្ញុំទៅចំនួនពីរ បី បួនប្រាំថ្ងៃ មួយអាទិត្យនោះ គឺក្នុងមួយថ្ងៃគេសួរពីរដង ជួនថ្ងៃណាគេសួរចម្លើយបីដង ជួនថ្ងៃណាឃើញគេសួរចម្លើយតែម្តងទេបាទ។ សួរឱ្យខ្ញុំឆ្លើយ ព្រោះខ្ញុំមិនដឹងឆ្លើយរបៀបម៉េចទៅកើត ខ្ញុំអត់ឆ្លើយ។ បើមិត្តឯងវ៉ៃខ្ញុំចោលក៏សុខចិត្តតែងាប់ ខ្ញុំនឹកឃើញតែប៉ុណ្ណឹងឯង ខ្ញុំមានដឹងថាឆ្លើយក្បត់អង្គការ មិនដែលមានពាក្យសម្តីថាអ្វីទៅក្បត់ទេ ខ្ញុំធ្វើការបម្រើតាំងពីតែតូចមក គឺស្មោះត្រង់ ដល់ស្មោះត្រង់ដើម្បីជាតិ ថាដើម្បីការពារប្រទេសជាតិតែប៉ុណ្ណឹងទេបាទ។

**ស៖** អ្នកដែលសួរចម្លើយលោក តើអ្នកទាំងហ្នឹងគឺជាអ្នកយាមដែលធ្វើការនៅគុក ឬក៏អ្នកផ្សេងដែលមកពីខាងក្រៅគុកដើម្បីមកសួរចម្លើយលោកនោះ?

[១៥:៥៦:២៧]

**ឆ៖** បាទ អ្នកក្នុងគុក វាអ្នកបញ្ចេញ ប៉ុន្តែវាសួរផង ហើយមានមកពី៨០១ គេសួរបាទ មកពីតាបង តាសារឿន កងពល៨០១ – តា០៥ គេហៅថាតា០៥បាទ។ មិនដឹងថាមេបញ្ជាមក មិនដឹងថាគេប្រើអំណាចខុសពីមេ ក៏ខ្ញុំមិនដឹងដែរបាទ។

**ស៖** លោកនិយាយថាគេឆក់ខ្សែភ្លើងលោក។ សូមលោករៀបរាប់ជូនតុលាការឱ្យបានលម្អិតបន្តិចតាមអ្វីដែលលោកចងចាំ។ តើគេឆក់ខ្សែភ្លើងដូចម្តេច? ថាតើគេប្រើឧបករណ៍អ្វីដើម្បីឆក់ខ្សែភ្លើងពេលសួរចម្លើយនោះ?

**ឆ៖** បាទ ដែលខ្ញុំដែលឆក់ខ្ញុំ ៗបានដឹងខ្លួនគឺអាគុយ មិនឆក់នឹងម៉ាស៊ីនអីទេ គឺនឹងអាគុយបាទ។ អាគុយយើងនោះប្រហែលជាអាគុយ១០០អំពែ ឬអាគុយ៧០អំពែប៉ុណ្ណោះឯងបាទ។ មិនមានម៉ាស៊ីនអីនឹងធំសម្រាប់សាគួរ ថាឆក់ ឬគុកនេះ មិនសម្រាប់ថាធ្វើទុក្ខបានយូរ ក៏ដូចជាបានខ្ញុំថាវាមិនមែនថាយូរគុកនេះដើម្បីគុកចល័ត តាមខ្ញុំមើល របៀបទៅចល័តទៅតាមសភាពការណ៍ដែលសម្លាប់មនុស្សមានតែប៉ុណ្ណឹង តាមខ្ញុំមើលទៅ។

**ស៖** ហើយខ្ញុំនឹងត្រឡប់មកបញ្ហានេះម្តងទៀត។ តើគេសួរចម្លើយលោកតែមួយថ្ងៃ ឬក៏ការសួរចម្លើយហ្នឹងបន្តពីមួយថ្ងៃទៅមួយថ្ងៃច្រើនថ្ងៃ? ក្នុងករណីដែលគេសួរបន្តនោះ ថា<តើ>រយៈ<ពេលប៉ុន្មាន>ដែលគេឆក់ខ្សែភ្លើង វាយដំ ហើយនិងសួរចម្លើយហ្នឹង<>?

**ឆ៖** បាទ ដែលឆក់នោះ គឺវាសួរចម្លើយគឺយូរដែរបាទ។ ជួនណាថ្ងៃណានោះ មួយថ្ងៃម្តងទៅ ជួនថ្ងៃណាគឺម្តង ជួនថ្ងៃណានោះគឺពីរដង ជួនថ្ងៃណានោះវាបានខានខ្លះបាទ វាមិនបានរាល់ថ្ងៃរហូតទេ មានបន្ទូរខ្លះបាទ អត់មានបានសួរចម្លើយរាល់ថ្ងៃទេ។ ជួនណាវាបទបញ្ជាមកពីមេ វាប្រាប់ខ្ញុំថា "មេឲ្យបញ្ជាអ្អែងនេះឲ្យឆ្លើយ បើហ្អែងមិនឆ្លើយអ្អែងត្រូវតែងាប់ បាទ បើអ្អែងឆ្លើយអង្គការអត់សម្លាប់អ្អែងចោលទេ គេថាអ៊ីចឹង"។ ខ្ញុំក៏វាមិនមានពាក្យអីនឹងខ្ញុំឆ្លើយផង ក៏ខ្ញុំអត់ឆ្លើយពិត បើគេវៃសុខចិត្តតែងាប់តែប៉ុណ្ណឹងឯងខ្ញុំ នឹកឃើញតែប៉ុណ្ណោះឯង។ គេមានរឿងអីទៅឯណារួច បើដៃជាប់ចំណង ជាប់ច្រវាក់គេ យើងរត់ក៏រត់មិនរួចបាទ។ នឹកឃើញក្នុងចិត្ត បើខ្ញុំកុំអីគេចទាន់ មិនដឹងថាអង្គការនោះវាបញ្ជាឲ្យវៃ មិនដឹងថាបុគ្គលនោះវាធ្វើតាមល្មើសច្បាប់ខ្លួនវាក៏មិនដឹង ខ្ញុំមិនមានបានថាចោទប្រកាន់ដូចថាអង្គការទាំងអស់ទេ ប៉ុន្តែគ្រាន់ថា ខ្លាចបុគ្គលវាធ្វើដោយបុគ្គលក៏មិនដឹង។ ម្ល៉ោះហើយវាថា នៅតែមួយថ្ងៃទៀតទេ ខ្ញុំត្រូវស្លាប់បាត់។ គេសួរចម្លើយប្រាប់ខ្ញុំថាអ៊ីចឹងឯង។ ថ្ងៃនោះគឺខ្ញុំបានចេញរួចផងមើល៍ ដូចថាគុណរបស់ខ្ញុំទៅចុះ សំណាងល្អ ថាទឹកដោះម្តាយថ្លៃផងទៅចុះ។ បាទ មនុស្សខ្ញុំវាត្រង់ៗ វាអត់មានក្បត់ពីអង្គការអន្តាក់អន្តិច ខ្ញុំត្រង់បានរស់។ បានខ្ញុំរហូតមកដល់បច្ចុប្បន្ន ខ្ញុំនឹកឃើញថាឈឺចាប់ ក្នុងរបបនោះ បាទ របបនោះក៏វាមិនមែនថាវាចោទប្រកាន់អីទេ ប៉ុនថាអារឿងនេះ គឺក្នុងការដែលដឹកនាំ ក៏វាតែងតែមានខូចឥទ្ធិពលអ្នកដឹកនាំ។ អ្នកដឹកនាំមិនបានបញ្ជាក៏យើងជាគ្រប់គ្រងជាប្រទេសជាតិ ក៏យើងអាចទទួលខុសត្រូវអត់មានថាមិនទទួលទេ បាទ ត្រូវតែទទួលខុសត្រូវ យើងត្រូវគេតាមដានប្រជាជន ឬកងទ័ពត្រូវដឹងមានឈឺ មានគ្រុន មានរងារ មានសួរសុខទុក្ខ អត់ស៊ី អត់ គេមាន ក៏យើងនាយករដ្ឋមន្ត្រី ក៏យើងអាចដឹងគ្រប់គ្រងប្រជាជនបាន។ ដោយសារយើងមិនដឹង នេះហើយយើងដឹកនាំប្រទេសជាតិវាកើតជា អត់បានរីកចម្រើន អត់បានដូចគោលបំណង។ នេះបានថាវាមិនត្រឹមត្រូវបាទ។ ខ្ញុំមិនជឿថា អ្នកធំមិនដឹង។ មួយប្រទេសកម្ពុជាអាចតែដឹងខ្លះ។ ខ្ញុំធ្វើការក៏ខ្ញុំអាចដឹងដែរ បើខ្ញុំធ្វើធំក៏ខ្ញុំអាចថាអញធ្វើក្បត់គេរបៀបម៉េចៗពីប្រជាជន ឮពីកងទ័ពក៏អាចដឹងខ្លួនឯងដែរ បាទ។

ខ្ញុំនឹកឃើញពិចារណា ខ្ញុំឈឺចាប់។ ដល់ឯងបម្រើកងទ័ព ជួយជាតិដើម្បីការពារប្រទេសជាតិ ដល់ឪពុកម្តាយ បងប្អូនគេសម្លាប់ចោលអស់ តើខ្ញុំវាឈឺចាប់ នោះខ្ញុំវាចិត្តល្អណាស់ ឬមួយយ៉ាងណា។

ទៅអស់លោកណាដែលចិត្ត បានថាបើចិត្តមិនល្អ វាអាក្រក់ដូចតែគ្នា។ តែបើយើងទៅសម្លាប់បងប្អូនដូចជាកាន់កាប់ ខ្លួនឯងធ្វើជាមេអីចឹងបើគេសម្លាប់ខឹងទេ? ខឹងដូចគ្នា។ អានេះហើយខ្ញុំធ្វើជាកងទ័ពបម្រើកងទ័ពហើយ ខ្ញុំគេសម្លាប់ម៉ែឪចោល តើឲ្យអ្នកណាដែលចិត្តល្អបាន? ទោះបីតែយើងអ្នកដឹកនាំផ្ទាល់ក៏យើងមិនចិត្តល្អ ត្រូវតែសងសឹក។

**ប្រធានអង្គជំនុំ៖**

បាទៗ ប៉ុណ្ណឹងសិន ដើមបណ្ដឹងរដ្ឋប្បវេណី ហើយលោកមានឱកាសច្រើននៅចុងក្រោយថ្ងៃស្អែកនៅពេលសវនាការចុងក្រោយ លោកអាចមានធ្វើសេចក្ដីថ្លែងរៀបរាប់អំពីបញ្ហាទាំងអស់ហ្នឹងបានហើយណ៎ះ! លោករង់ចាំស្ដាប់ការតាំងសំណួរដេញដោលបន្តទៅទៀត ទំនងមានរយៈពេលតិចតួចទេ។

[១៦:០២:៥០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ ខ្ញុំសួរសំណួរប្រហែលមួយ ឬពីរទៀតទេទៅដើមបណ្ដឹងរដ្ឋ-ប្បវេណី បាទ។ លោកបានបញ្ជាក់ថា គេឆក់ខ្សែភ្លើងលោក ហើយក៏គេវាយដំលោកដែរនៅពេលដែលគេសួរចម្លើយលោកនោះ។ សូមលោកនិយាយឲ្យបានច្បាស់លាស់ រៀបរាប់ឲ្យបានច្បាស់លាស់ថាតើគេវ៉ៃលោកហ្នឹងដោយរបៀបណា? គេប្រើដំបងអ្វីដើម្បីវាយលោកជាដើម ...។ល។

**ឆ៖** បាទ ដែលវ៉ៃខ្ញុំនោះ គឺដំបងយើងគឺវាធំដែលបាទ ធំប៉ុនកដៃ កំភួនដៃនេះ គេវ៉ៃបាទ វ៉ៃល្មមតែយើងពីរបីដំបង ក៏វាបាត់ស្មារតីដឹងខ្លួន វាសន្លប់ ខ្ញុំសន្លប់ វាវ៉ៃម្ដងសន្លប់ ពីរដងក៏សន្លប់ សន្លប់តែវាមិនបានយូរ វាចាប់កន្ត្រាក់ វាសួរចម្លើយទៀត ក៏អាចដឹងខ្លួនមួយភ្លែតទៅវិញទៅបាទ។ បើខ្ញុំមិនឆ្លើយទៅវាវ៉ៃផ្ដាច់ទៀត វាវ៉ៃយកងាប់ អញដាក់អ្នែងយកងាប់ វាថា។ មិនបានឆ្លើយហីទៅ វ៉ៃឯងឲ្យងាប់តែម្ដង។ ខ្ញុំក៏អត់ដឹងដែរ ក៏វាវ៉ៃខ្លាំងទៅ វាចូលអាបាត់បង់សតិវិញ្ញាណ ក៏សន្លប់មិនបានដឹងអី នឹងឆ្លើយនិយាយកើតវាអស់។ ដំបងធំៗបាទ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបញ្ចប់ត្រឹមនេះ ពេលនេះសិនបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ប្រគល់ឯកសារមួយជូនដើមបណ្តឹងរដ្ឋប្បវេណីដែលខ្ញុំចង់សួរនៅថ្ងៃស្អែកគឺឯកសារ E3/8648 ដែលជាបញ្ជីទាហានកងពល៩២០ ដែលគេបញ្ជាក់ថា ត្រូវបានដោះលែងពីស-២១។ ដូច្នេះលោកប្រធាន សូមមេត្តាអនុញ្ញាតប្រគល់ឯកសារហ្នឹងជូនដើមបណ្តឹងរដ្ឋប្បវេណី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត សូមយកឯកសារពីចៅក្រមជូនដើមបណ្តឹងរដ្ឋប្បវេណី។

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកចៅក្រម ឡាវែន៍ <និង>ខ្ញុំ<មានគំនិតដូចគ្នា ព្រោះថា> នេះក៏ជាសំណើរបស់ខ្ញុំដែរលោកចៅក្រម ក៏ប៉ុន្តែមានឈ្មោះមនុស្សដល់រាប់រយនាក់ឯណោះនៅលើបញ្ជីឈ្មោះនេះ។ ដូច្នេះ ខ្ញុំកំពុងតែគិតថា តើវាយ៉ាងដូចម្តេចដែរ ថាតើគួរផ្តល់ឯកសារនេះទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅពេលនេះឥឡូវឬយ៉ាងណា ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីអានឈ្មោះមនុស្សទាំងរាប់រយនាក់នេះ? ហើយនិងត្រឡប់មកឆ្លើយបញ្ហាទាំងនេះនៅថ្ងៃស្អែក។ ដោយសារថា មានឈ្មោះច្រើនមែនទែន ហើយមនុស្សរាប់រយនាក់នេះមានតួនាទីផ្សេងៗគ្នា។ អ៊ីចឹង ថាតើដើមបណ្តឹងរដ្ឋប្បវេណីនេះ គួរនឹងអាចផ្តល់ឱកាសឲ្យគាត់អានឯកសារនេះ ឬក៏យ៉ាងណានោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ។

[១៦:០៦:៣៦]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានការជំទាស់ទៅនឹងការពិនិត្យមើលឯកសារនេះភ្លាមៗដើម្បីសួរនៅថ្ងៃស្អែកនោះទេ។ ខ្ញុំចង់បន្ថែមព័ត៌មានមួយដែលលោក កូប៉េ នេះ កំពុងតែខ្វាយខ្វល់រឿងនេះ។ យើងកំពុងពិនិត្យមើលបញ្ជីឈ្មោះដ៏ច្រើននេះ ហើយ<វាជាប់ពាក់ព័ន្ធនឹងការសម្ភាសន៍មួយចំនួនដែលធ្វើឡើងដោយ>មជ្ឈមណ្ឌលឯកសារកម្ពុជា <ជាមួយអ្នក>ដែល<គិតថា>ត្រូវបានគេដោះលែង។ <តាមពិតអ្នកទាំងអស់នេះមិនត្រូវបានដោះលែងទេ ប៉ុន្តែពួកគេ>ជាច្រើនត្រូវគេបញ្ជូនត្រឡប់មកស-២១ វិញ ដើម្បីសម្លាប់ចោល។ <>មានឯកសារ<បន្ថែម>ច្រើនណាស់ពាក់ព័ន្ធទៅនឹង<ក្រុម>មនុស្សទាំងអស់នេះ <ដែល>អង្គជំនុំជម្រះ<ត្រូវ>ជ្រាបអំពីរឿងនេះ។ <ខ្ញុំមានផែនការសួរទាក់ទងទៅនឹង

មន្ទីរសន្តិសុខស-២១ ព្រោះ>នៅត្រង់ចំណុចនេះគឺថាមានឯកសារច្រើនមែន។ <ប៉ុន្តែលោកត្រូវតែដឹង> ថាមានឯកសារបន្ថែមពាក់ព័ន្ធទៅនឹងមនុស្សទាំងនេះច្រើនណាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

វាក៏ជាកម្មវត្ថុមួយនៃការស៊ើបអង្កេតដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ រហូតដល់ចេញកូនសៀវភៅមួយ ដែលយើង<បានដាក់ជាឯកសារហើយ។> ខ្ញុំយល់ថា កូនសៀវភៅនេះត្រូវបានទទួលយកមកដាក់ក្នុងសំណុំរឿងជាភស្តុតាងហើយ។ ខ្ញុំមិនដឹងថាភស្តុតាងមួយណាដែលសហព្រះរាជអាជ្ញារងយោងនេះ ក៏ប៉ុន្តែខ្ញុំ<រីករាយដោយបានឮអំពីរឿងនេះ។ យើងបានធ្វើការស្រាវជ្រាវដោយផ្ទាល់ខ្លួន>។ អ៊ីចឹងខ្ញុំក៏ស្វែងរកឈ្មោះមនុស្សមួយចំនួនដែរ។ ទោះយ៉ាងណាក៏ដោយ ខ្ញុំគិតថាវាមានសារប្រយោជន៍ជាងក្នុងការផ្ដល់ឯកសារនេះទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ហើយគាត់ពិនិត្យមើលឈ្មោះទាំងអស់នេះជាមុន នឹងឆ្លើយនៅព្រឹកស្អែក។

**សួរបន្តដោយប្រធានអង្គជំនុំ៖**

បាទ ហើយ -- បាទ ល្អណាស់ ហើយទោះបីជាយ៉ាងណា យើងប្រឹងប្រែងលទ្ធភាពក្នុងការផ្ដល់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ដែលគាត់ជាមនុស្សនៅអតីតជាកងទ័ពនៅកងពល៩២០ ដែលជាកងពលមួយក៏មានបញ្ហាពាក់ព័ន្ធនឹងឯកសារចំពោះ។

**ស៖** ប៉ុន្តែយើងទទួលព័ត៌មានថា លោក -- លោកដើមបណ្ដឹងរដ្ឋប្បវេណី លោក វុត តើលោកចេះអក្សរទេ?

[១៦:០៨:៥៨]

**លោក សុន វុត៖**

**ឆ៖** ខ្ញុំអត់ស្គាល់ចេះទេ ទាន។

**ស៖** ពាក្យមិនស្គាល់ចេះហ្នឹង តើលោកអានបានទេ ឯកសារនោះ? លោកអាចចេះអានឈ្មោះអីបាននៅក្នុងឯកសារនុ៎ងទេ?

**ឆ៖** យ៉ាប់ថា ខ្ញុំងងឹតភ្នែកផង ក៏វាអត់ចាចេះ វាអានវាមិនត្រូវទៀតទាន។ វាយ៉ាប់រឿងអានហ្នឹងឯងខ្ញុំ បាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ប្រសិនថាបើមិនមានការយល់ទាស់ទេ លោកមេធាវី ឡោ ជុនធី អាចអាន ដើម្បីឲ្យដើមបណ្ដឹងរដ្ឋប្បវេណីនេះស្ដាប់បាន លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ដោយគាត់ជាភាគីដើមបណ្ដឹងរដ្ឋប្បវេណី ដូចជាអត់មានបញ្ហាអីទេណ៎ា។ អ៊ីចឹងយើងចាត់ចែង អ៊ីចឹងចុះ ដើម្បីឲ្យបានលឿនទៅមុខបាន ហើយឆ្លៀតពេលណា អាហ្នឹងស្រេចលោកទេណ៎ះ!

បាទ ហើយសវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ច ដំណើរការសវនាការសម្រាប់ថ្ងៃត្រឹមនេះសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី៣១ ខែមីនា ឆ្នាំ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក សុន វុត សវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក សុន វុត វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់ត្រឡប់មកផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកឲ្យបានមុនម៉ោង -- នៅវេលាម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១០ នាទី)*